សាំង ម៉ាក់សាង

# កោះត្រាល់ឬភូស៊ុកថ្មី? ជាដែនដីរបស់ខ្មែរ... ត្រូវប្រគល់ឱ្យខ្មែរវិញ

គេហដ្ឋានបោះពុម្ពផ្សាយអប្សរា
បោះពុម្ពលើកទី២
ខែមករា ឆ្នាំ២០០០
ម៉ុងរេអាល់, កេបិក

ការផ្សាយរបស់សារពត៌មាន «អង្គរបុរី»
គ.ស.២០០៥ ព.ស.២៥៤៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

## លោក គួច~ប្រសិទ្ធិ

ម្ចាស់រោងពុម្ព «អប្សរា» នៅទីក្រុងម៉ុងរេអាល់, កេបិក
ប្រទេសកាណាដា
ដែលបានធ្វើអំណោយសំណៅសៀវភៅ
«កូសាំងស៊ីនជាដែនដីរបស់ខ្មែរ... ត្រូវប្រគល់ឲ្យខ្មែរវិញ»
និពន្ធដោយលោក សាំង-ម៉ាក់សាង
មកសារពត៌មាន «អង្គរបូរី» បោះផ្សាយជាសាធារណៈ
ដើម្បីទុកជាឯកសារ និងជាវត្ថុដាស់អង្រួនស្មារតីកុលបុត្រ
និងកុលធិតាខ្មែរគ្រប់ៗរូប ឲ្យរលឹកនឹកចងចាំជានិច្ចដល់ទឹក
ដីនៃសម័យមហានគរ ដែលបានរិចរិលរួមតូចទៅៗ ដោយ
សារសត្រូវខាងកើត និងខាងលិច រំលោភឈ្លានពានហើយ
កេងប្រវ័ញ្ចយកទៅធ្វើជាទ្រព្យភិនខ្លួន និងដោយសារតណ្ហា
ការស៊ីជោរ ឆ្កួតវង្វេងខ្លួនឯង នៃពួកមេដឹកនាំខ្មែរខ្លះៗ ។

សូមមនុញ្ញផលដ៏ប្រសើរនេះ
នាំមកនូវសុភមង្គលនិងវិបុលសុខ ដល់លោកនិងគ្រួសារ

លី-ឌៀប
ចាងហ្វាងសារពត៌មានអង្គរបូរី



## លោក សាំខ~ម៉ាក់សាខ

ជាសមាជិកបច្ចុប្បន្ននៃសមាគមអ្នកនិពន្ធខ្មែរ
ខ្ញុំជឿថា អ្នកដែលមិនបំរើសត្រូវ និងដែលចង់ឲ្យដីមាតុភូមិ
និងជាតិសាសន៍ខ្លួនគង់វង្ស ពិតជាពុំដាក់ទោសលើរូបខ្ញុំ ដែលគ្រាន់
តែប្រើសេរីភាពការពារមូលហេតុដ៏ត្រឹមត្រូវរបស់ជនរួមឈាមរបស់ខ្ញុំ
នៅកម្ពុជាក្រោម ក្នុងការធ្វើឲ្យគេទទួលស្គាល់សិទ្ធិជនរួមឈាមនេះ
ថាបានធ្វើឲ្យសៅហ្មងដល់មិត្តភាពខ្មែរ-យួនឡើយ ។

# សូមឧទ្ទិស
# ស្នាដៃនេះចំពោះ

---

★ វិញ្ញាណក្ខន្ធម្ដាយខ្ញុំ ដែលបានពពោះ បង្កើតនិងចិញ្ចឹមខ្ញុំឲ្យរស់បានជាមនុស្ស ស្រឡាញ់មនុស្សជាតិ ស្រឡាញ់ជាតិ ស្រឡាញ់ដីយ៉ាងប្ដូរផ្ដាច់ ។

★ ឪពុកខ្ញុំ សព្វថ្ងៃតស៊ូរស់កណ្ដាលហ្វូងស្រមោចឃ្មួន ព្រោះតែស្រឡាញ់ដីកេរ្តិ៍ ដែលបានឲ្យកំណើតដល់ខ្ញុំ និងផ្ដល់ឲ្យខ្ញុំនូវអ្វីៗគ្រប់យ៉ាង ដែលអ្នកស្នេហាជាតិ អ្នកជា មាន ។

ខ្ញុំសូមអរគុណលោកទាំងទ្វេនេះដោយស្មោះស្ម័គ្របំផុត ចំពោះអំណោយឈាមមួយដំណក់របស់លោក ដែលជា (ម៉ូឡេគីល) បង្កើតរូបខ្ញុំ ដោយលក្ខណៈមិនរលប់រលត់មួយ គឺមិនចេះ(ទ្រ)មនុស្សណា សាសន៍ណា ។

★ បងប្រុស និងប្អូនស្រីខ្ញុំ ដែលសុទ្ធតែបានបូជាសេចក្ដីសុខផ្ទាល់ខ្លួន ដើម្បីបំរើមូលហេតុដ៏ត្រឹមត្រូវរបស់ជាតិ គឺបានចូលក្នុងជួរកងទ័ព ចាប់អាវុធកំចាត់ឃ្មួន ដើម្បីការពារដីនិងសុខមាលភាពនៃជនរួមឈាមរបស់ខ្ញុំ ។

# សូមគោរព

## ដោយស្មោះ និងដោយភក្ដីបំផុតចំពោះ ៖

★ ខ្មែរក្រោមដែលស្លាប់ ស្លាប់ដើម្បីជាតិសាសន៍ និងជនរួមឈាមរបស់ខ្លួន នឹងនៅគង់វង្ស និងដែលហ៊ានទាមទារសិទ្ធិរបស់ខ្លួនជាម្ចាស់ដី ដែលខ្លួនរស់លើសព្វថ្ងៃនេះ ។

★ អស់លោកអ្នកប្រាជ្ញ ប្រវត្តិវិទូ អ្នកនិពន្ធ អ្នកស្រាវជ្រាវបរទេសនិងរួមលោហិតគ្រប់រូប ព្រមទាំងអស់លោកទាំងឡាយណា ដែលបានខិតខំបង្ហាញមតិសាធារណៈសកលឲ្យដឹងថា ដីកម្ពុជាក្រោមឬកូសាំងស៊ីន ជាដែនដីរបស់ខ្មែរឥតប្រកែកបាន ដែលខ្មែរនៅតែជាម្ចាស់ដែនដីនេះត្រឹមត្រូវតាមច្បាប់ជាដរាប ។

❑ ❑

❑

# លិខិតចំហចំពោះជនរួមឈាមនៅកម្ពុជាក្រោម

ជនរួមឈាមជាទីស្នេហាទាំងឡាយ !

មហានគរបានចុះខ្សោយអនុភាព តាំងពីមានផ្ដើមចំបាំងជាមួយសៀមមកម្ល៉េះ។ ប៉ុន្តែមហានគររបស់យើងទើបតែត្រូវវិនាសបែកខ្ញែកដីអស់ជាបន្តបន្ទាប់ ក្រោយពីមានអន្តរាគមន៍របស់យួនមកក្នុងកិច្ចការខ្មែរជាលើកដំបូង នៅក្នុងសតវត្សរ៍ទី១៧ ។ ជាការពិតណាស់ ការបាត់បង់អនុភាព រហូតដល់ការបាត់បង់ដីអស់មួយភាគយ៉ាងធំបំផុតនេះ បណ្ដាលមកពីស្ដេច និងសន្តតិវង្សស្ដេចភាគច្រើន ហើយនិងនាម៉ឺនក្បត់ខ្លះ ដែលឈ្លោះគ្នាដណ្ដើមរាជសម្បត្តិ រួចទៅពឹងបរទេស ។

ក៏ប៉ុន្តែ ដីយើងដ៏ធំបំផុត ដែលបងប្អូនកំពុងរស់នៅលើដោយរងកម្មបំផុតនោះ គឺ«កម្ពុជាក្រោម»នេះ ទើបតែនឹងបាត់បង់ទៅនៅឆ្នាំ១៩៤៩ ដោយស្នាដៃបារាំង អ្នកអាណាព្យាបាលរបស់យើងតែម្ដង ។ តាំងពីនោះមក ការតស៊ូរបស់បងប្អូនចេះតែមានដំណើរ មានសន្ទុះខ្លាំងក្លា និងមានមូលដ្ឋានរឹងប៉ឹងឡើងៗជាលំដាប់ដែរ ។

រដ្ឋការយួន តាំងពីខ្មោចប្រធានាធិបតីង៉ោ-ឌិនយៀមរហូតមក.................បានអនុវត្តគំរោងការបំបាត់ពូជខ្មែរពីដីរបស់យើង ដោយប្រើវិធានការព្រៃផ្សៃបំផុត អមនុស្សធម៌បំផុត ដែលជាតិសាសន៍មានអារ្យធម៌ ស្អប់ខ្ពើមមិនដែលឃើញ ។ វាធ្វើទារុណកម្មលើរូបកាយ វារំលោភលើស្ត្រីភេទ វាចាប់យកទៅដាក់ក្នុងជង្រុកស្រូវដុតទាំងរស់ វាហៅយន្តហោះនិងទ័ពរបស់វាឲ្យទៅទម្លាក់កំទេច ដុតបំផ្លាញភូមិស្រុក ផ្ទះសំបែង ទ្រព្យសម្បត្តិរបស់បងប្អូន តាមរយៈនៃសង្គ្រាមដែលវាហៅថា រំដោះជាតិវៀតណាម ។ យួនយៀកណាមកុងវ៉ា ក៏ដូចជាយួនយៀកកុង គឺសុទ្ធជាយួន សុទ្ធតែជាពេជ្ឈឃាដប្រវត្តិសាស្ត្រចំពោះបងប្អូន ។

រដ្ឋការយួនឥតព្រមទទួលស្គាល់សិទ្ធិខ្មែរក្រោម ឥតព្រមផ្ដល់លក្ខន្តិក:ជនជាតិភាគតិច ឲ្យបងប្អូនទេ ។ ចុះជនជាតិភាគតិចឯទៀត ម្ដេចក៏វាព្រមប្រគល់ឲ្យ ? គ្មានអ្វីក្រៅពីចោរប្លន់នេះភ័យខ្លាចជនរួមឈាមរបស់យើងដ៏ច្រើនលើសលប់ ទាមទារដីពីវាវិញនោះទេ ។

ជនរួមជាតិជាទីស្នេហា !

យើងមានការឈឺចាប់បំផុត ចំពោះអំពើបំបាត់ពូជសាសន៍ ដែលយួនប្រព្រឹត្តមកលើជាតិរបស់យើងនៅទីនេះ ។

យើងសូមគាំទ្រគ្រប់ការតស៊ូការទាមទាររបស់បងប្អូនទាំងស្រុង ហើយយើងសូមដាក់ទោសអស់ជនទាំងឡាយណា ដែលប៉ុនប៉ងបង្អាក់ពង្វាង ឬធ្វើឲ្យការតស៊ូការទាមទារទាំងនោះបរាជ័យ ។

យើងពិតជាមានសិទ្ធិត្រឹមត្រូវតាមផ្លូវច្បាប់ ទាមទារឲ្យស្គាល់សិទ្ធិរបស់យើង

និងប្រគល់ដីកម្ពុជាក្រោមមកឲ្យយើង ។
ពួកចោរប្លន់ ពួកចក្រពត្តិមានទីបញ្ចប់មួយ គឺការវិនាសអន្តរធាន ។ ការតស៊ូមិនស្លាប់ទេ (**Mort pour la patrie, c'est s'immortaliser pour une belle mort**) ។ មិនខ្វះទេអ្នកដើរតាមក្រោយយើង! (**Le Flambeau demeure toujours vivant !**) យើងត្រូវឈ្នះ ។

ភ្នំពេញ កម្ពុជាកណ្តាល, ថ្ងៃ ១៨ មករា ១៩៧៣
( ហត្ថលេខា )
**សាំង~ម៉ាក់សាង**

# ចំពោះសន្តិភាពឥណ្ឌូចិន

គេនិយាយថា ឥណ្ឌូចិននឹងបានសន្តិភាពភ្លាម បើកាលណាហើយបក្សដែលគាំទ្រសង្គ្រាមនៅទីនេះ ដកទ័ពនិងបញ្ឈប់អន្តរាគមន៍របស់ខ្លួន គឺថាអាមេរិកចេញពីឥណ្ឌូចិន យួនខាងជើងចេញពីដីខ្មែរ លាវ និងយួនខាងត្បូង ហើយទទួលស្គាល់ថាយួនមានពីរដដែល ។

យួនកំពុងតែរួមគ្នាបោកប្រាស់មហាអំណាចលោកសេរី និងលោកសង្គមនិយម ឲ្យបំរើមូលហេតុឧក្រិដ្ឋមហាចោររបស់ពួកវា ។

បរាជ័យនៃការអនុវត្តន៍កិច្ចព្រមព្រៀងប៉ារីសថ្ងៃ២៧ មករា ១៩៧៣ ល្មមធ្វើឲ្យអាមេរិកាំងនិងសកលលោកយល់ច្បាស់ហើយ អំពីបំណាងនិងពុតដ៏ថោកទាបរបស់យួន ។

មានតែប្រើដំណោះស្រាយយោធាប៉ុណ្ណោះ ទើបបញ្ហាឥណ្ឌូចិនរកច្រកចេញឃើញ ។

សន្តិភាពឥណ្ឌូចិននឹងកើតភ្លាម ក្រោមអណ្តាតភ្លើងចុងក្រោយនៃគ្រាប់បែកបរមាណូលើយួនរលត់ ក្រោយពីដីកម្ពុជាត្រូវបានគេប្រគល់ឲ្យខ្មែរវិញ !!...

# ការមិនត្រូវច្រឡំ
# រវាងពាក្យកូសាំងស៊ីន និងកម្ពុជាក្រោម

ពាក្យ <កូសាំងស៊ីន> បានទទួលការប្រែប្រួលច្រើនលើកច្រើនគ្រាណាស់ ទៅតាមកំណត់ពេលនិងកាលៈទេសៈ ដែលយើងមានកាតព្វកិច្ចត្រូវឲ្យមានបរិច្ឆេទប្រវត្តិសាស្ត្រ (Localisation historique) ប្រាកដមួយ មុននឹងចូលទៅដល់ជំរៅនៃសំណើររបស់យើង ។ ពាក្យនេះបានផ្លាស់កន្លែងយ៉ាងលឿន ពីទិសខាងជើងឆ្ពោះមកខាងត្បូង ដោយនាំមកជាមួយផង នូវជនជាតិយួនក្នុងសង្គ្រាមវាតព្រំដែន ជាទំលាប់ប្រចាំសតវត្សរបស់វា ចាប់ពីព្រំដែនខាងត្បូងនៃប្រទេសចិនរហូតទៅដល់នឹងជ្រោយកាម៉ៅ ។

ដំបូងឡើយ ពាក្យ <កូសាំងស៊ីន> ដែលមាននិរុត្តិសាស្ត្រឬឫសពាក្យនាំឲ្យជ-ជែកតវ៉ាយ៉ាងខ្លាំងនៅឡើយនោះ ត្រូវបានយួនហៅឈ្មោះ ដីតុងកឹង (យៀកណាមខាងជើង) តែមួយប៉ុណ្ណោះ ។ បន្ទាប់មក គឺចាប់ពីសតវត្សរ៍ទី១៦នៃគ្រឹស្តសករាជ ពួកអឺរ៉ុបបានយកទៅប្រើដើម្បីឲ្យហៅដីដែលក្សត្រក្រុងវ៉េ នៃសន្តតិវង្សង្វៀងត្រួតត្រា គឺថាប្រទេសអណ្ណាមកណ្តាល ហើយនិងដែនដីសណ្តរដូណាយ និងទន្លេមេ-គង្គដែលយួនប្លន់ពីខ្មែរ (យៀកណាមខាងត្បូងបច្ចុប្បន្ន) ។ ទីបញ្ចប់ ក្រោយពីពួកបារាំងយកដូណាយ និងទន្លេមេគង្គខាងក្រោមបាន (ឆ្នាំ១៨៥៨-៦០) ពាក្យ<កូសាំងស៊ីន>នេះ ត្រូវបារាំងយកទៅដាក់ឈ្មោះឲ្យហៅ <កូសាំងស៊ីនទំនាប> (Basse Cochinchine) ឬ<កូសាំងស៊ីនបារាំង (Cochinchine française) គឺយៀកណាមសព្វថ្ងៃ ជំនួស<កូសាំងស៊ីនលើ> (Haute Cochinchine) ឬកូសាំងស៊ីនអណ្ណាម គឺវៀតណាមកណ្តាល ដែលទើបនឹងធ្លាក់ក្រោមអាណាព្យាបាលបារាំង កាលពីឆ្នាំ១៨៨៥វិញ ។

ពួកចាមដែលចុះអាប់ឱននៅសតវត្សទី៩ នៃគ្រឹស្តសករាជនោះ ត្រូវពួកយួនប្រល័យវិនាសស្ទើរគ្មានសល់ពូជ ហើយវាយរុញច្រានឥតឈប់ឈរ តាមបណ្តោយសមុទ្រ តាំងពីខាងជើងទៅខាងត្បូង (តាមសមុទ្រចិន) ។ មកដល់សតវត្សទី១៥នៃគ្រឹស្តសករាជ ពួកចាមបានទទួលបរាជ័យជាទីបញ្ចប់វិនាសប្រទេសអស់ រហូតសល់ខេត្តសាមលពីរ ជាចំណុះស្តេចក្រុងវ៉េប៉ុណ្ណោះ គឺខេត្តផានរី (Phanri) និងផាន់រ៉ាំង (Phanrang) ។

ក្រោយពីលេបនគរចំប៉ារួច ពួកយួនបានបំបោលការរុករានរបស់វា មកដណ្តើមយកដែនដីដូណាយ និងវាលទំនាបទន្លេមេគង្គរបស់ខ្មែរទៀត ។ មកដល់សតវត្សទី១៨ ដោយមានអំពើរួមក្បត់ពីចក្រពត្តិបារាំងផង យួនបានដណ្តើមបានពីខ្មែរ នូវ

វាលទំនាបនៃទន្លេមេគង្គ ។ ខេត្តខ្មែរទាំងឡាយនៅកម្ពុជាក្រោម (ដែលបារាំងហៅថាកូសាំងស៊ីនទំនាប ឬកូសាំងស៊ីនបារាំង) ត្រូវធ្លាក់ជាបន្តបន្ទាប់គ្នាទៅក្នុងកណ្តាប់ដៃយួន ៖ ខេត្តបារៀ ក្នុងឆ្នាំ១៦៥៨, ព្រៃនគរ (យ៉ាឌិន) ឆ្នាំ១៦៩៨, ខេត្តមីថរ និងវិញឡុង ឆ្នាំ១៧៣១, ខេត្តស្រុកត្រាំង នៅឆ្នាំ១៧៥៧ ។

គឺតាមរបៀបប្លន់ ដោយដណ្តើមដី និងបន្លំឈ្មោះដែលមានបារាំងជាអាណាព្យាបាលខ្មែរ រួមខុសត្រូវនេះផងនោះហើយ ដែលយួនចោរប្លន់អន្តរជាតិ បានបង្កើតប្រទេសរបស់វា គឺរបស់ដែលវាហៅថា យៀកណាមខាងត្បូងនេះឯង ។

សំរាប់ខ្មែរអ្នកជានិងខ្មែរជាតិនិយម ចំបាំងរវាងយួននិងយួន គឺជាចំបាំបញ្ចូលដីខ្មែរកម្ពុជាក្រោម ទៅរួមនឹងដីកូសាំងស៊ីន ឬយៀកណាមខាងជើង ។ ការបញ្ចូលដីខ្មែរទៅក្នុងដីយួនបែបនេះ មិនអាចនឹងធ្វើទៅកើតឡើយ ដរាបណាខ្មែរនៅមានឈ្មោះលើពិភពលោក ដរាបណាយួនមិនទាន់អារកខ្មែរអស់នៅឡើយទេនោះ ។

មតិអន្តរជាតិគួរដឹងពីពុតយួន ហើយឈប់ឲ្យយួនបោកប្រាស់ទៀតទៅ !

ដីខ្មែរត្រូវតែប្រគល់ឲ្យខ្មែរវិញ... ការនេះទោះបីថាពិភពលោកមានសីលធម៍យ៉ាងស្តួចស្តើងក្តី ក៏វាត្រូវតែយល់អីចឹងដែរ !!!

❏ ❏

❏


តាំងពីដើមគ្រិស្តសករាជមក ដល់សតវត្សទី១៩ ដែនដីកម្ពុជាក្រោម ឬ កូសាំងស៊ីនជាទឹកដីខ្មែរ
សមុទ្រចិន
PALILO

# ផ្នែកទី១

# ឧត្តិករណ៍ផ្សេងៗបញ្ជាក់ថា កម្ពុជាក្រោម ឬ កូសាំងស៊ីន ជាទឹកដីរបស់ខ្មែរ

# ជំពូក១

# ទល្អិករណ៍ផ្នែកលើ សិល្បៈ និង អារ្យធម៌

នៅក្នុងសតវត្សទី៩ ប្រទេសកម្ពុជាបានចេញផុតពីអាណាធិបតេយ្យ និងរំដោះរួចពីនឹមជ្វា ។ ព្រះបាទជ័យវរ្ម័នទី២បានបង្កើតរាជាណាចក្រកម្ពុជាឡើង ដោយព្រះអង្គបានបង្រួបបង្រួមនគរចេន-ឡាដីគោក និងចេន-ឡាដែនទឹក ឲ្យបានឯកភាពជាប្រទេសមួយដូចដើមវិញ ។ គឺចាប់ពីពេលនោះហើយ ដែលភាពរុងរឿងចិញ្ចាចរបស់ខ្មែរផ្ដើមឡើង ។

ស្របពេលគ្នានឹងការបង្រួបបង្រួមប្រទេសឲ្យមានឯកភាពឡើងវិញ សិល្បៈរបស់ខ្មែរក៏បានតាក់តែងខ្លួនជាថ្មីឡើងដែរ ។ មហិទ្ធិរិទ្ធរបស់ខ្មែរបានឡើងដល់កំពូល ក្នុងសម័យព្រះបាទសុរិយាវរ្ម័នទី២ កសាងអង្គរវត្ត ។ ព្រះសុរិយាវរ្ម័នទី២ថែមទាំងបានពង្រីកនគរ ដឹកនាំចំបាំងតទល់នឹងពួកដៃវៀត ប្រកបដោយជោគជ័យទៀតផង ។ សក្ខីកម្មនៃមហិទ្ធិរិទ្ធបានបញ្ជាក់ឡើងដោយចំបាំងពង្រីកនគរនេះបានម៉្យាង និងដោយការកសាងប្រាសាទនោះម៉្យាងទៀត ។ គឺដូច្នេះហើយទើបស្ទើរតែនៅគ្រប់តំបន់នៃអតីតរាជាណាចក្រកម្ពុជា គេប្រទះឃើញតែប្រាសាទ រមនីយដ្ឋាននានាដែលខ្លះមានសោភ័ណភាពគួរគយគន់ ស្រដៀងគ្នានឹងប្រាសាទខ្លះក្នុងបណ្ដាប្រា-សាទសម័យអង្គរដែរ ។

កម្ពុជាក្រោម ដោយហេតុថាដែនដីនេះ ជាដីសំបូរដោយភោគទ្រព្យធម្មជាតិ និងជាអាណាចក្រចាស់មួយរបស់ខ្មែរ ក៏បរិបូណ៌ដោយប្រាសាទរមណីយដ្ឋាន បូជនីយដ្ឋាន ដែលមានលំអលក្ខណៈមិនចាញ់ឬខុសពីស្ថាបត្យកម្មរបស់ខ្មែរនៅនាកម្ពុជាកណ្ដាលនេះប៉ុន្មានឡើយ ។ បើគេដើរកាត់កម្ពុជាក្រោមដ៏ធំធេង នោះគេនឹងឃើញតែប្រាសាទ ឃើញតែសីលាចារឹក ឃើញតែបដិមាករ ឃើញតែបូជនីយដ្ឋានរបស់ខ្មែរ ។

ប្រវត្តិវិទូដ៏ល្បីៗជាច្រើនបានឲ្យសេចក្ដីសន្និដ្ឋានថា កូសាំងស៊ីនគឺពិតជាអាណាខេត្តចាស់មួយរបស់កម្ពុជាដែនសមុទ្រ (Cambodge maritime) ។

កំណើតជាខ្មែរ ជាខ្មែរក្រោម (ដែលឥឡូវត្រូវគេបំភ្លៃហៅថា យួនមានដើមកំ-ណើតខ្មែរ) មានសាសនា វប្បធម៌ អារ្យធម៌ និងទំនៀមទំលាប់ដូចយើងកម្ពុជាក-

ណ្ដាលនេះដែរ ។

ដើម្បីជាសក្ខីភាពដល់និក្ខេបបទ «កូសាំងស៊ីនជាដែនដីរបស់ខ្មែរ...ត្រូវប្រគល់ឲ្យខ្មែរវិញ» យើងនឹងនាំអស់លោកមិត្តអ្នកអាន ឲ្យពិនិត្យជាមួយយើងនូវតឹកតាងនានាដូចតទៅ ៖

# ១
# សក្ការៈវត្ថុនៅកូសាំងស៊ីន

នៅពាសពេញដែនដីកម្ពុជាក្រោម ឬ កូសាំងស៊ីន យើងបានជួបប្រទះ ជួនកាលបដិមាករព្រះពុទ្ធ ជួនកាលរូបព្រះសិវៈ ជួនកាលទៀត សិលាចារឹកស្ដីពីរឿងស្ដេច ឬចែងពីរឿងរាមកេរ្តិ៍ ។ ជាពិសេស យើងឃើញអារាមព្រះសង្ឃខ្មែរ នៅគ្រប់ច្រកល្ហកនៃដែនដីកូសាំងស៊ីននេះតែម្ដង ។

ដោយពុំមានលទ្ធភាពគ្រប់គ្រាន់ បណ្ដាលមកពីកង្វះឯកសារ យើងសូមលើកយកតែកន្លែងខ្លះ ដែលមានសក្ការៈវត្ថុរបស់ខ្មែរមកបង្ហាញ ។

<u>នៅខាងជើងកៅ-ឡាញ់</u> ៖ មានព្រះពុទ្ធរូបសម័យអង្គរមួយព្រះអង្គធ្វើអំពីឈើ

<u>នៅក្នុងតំបន់ត្រាវិញ និងបាក់លីវ</u> ៖ គេសង្កេតឃើញព្រះវិហារផ្នែកខាងព្រះពុទ្ធសាសនា ជាក្រុមៗ វត្តអារាមទាំងឡាយ ហើយនិងចារឹកថ្មពីរកន្លែងផង ។

<u>នៅខាងក្រោមទន្លេបាសាក់បន្តិច</u> ៖ គឺក្នុងតំបន់មួយចម្ងាយ១០គីឡូម៉ែត្រខាងជើងសុកត្រាំង នៅក្នុងតំបន់នោះ គេឃើញមានកន្លែងតាំងបូរាណវត្ថុជាងម្ភៃកន្លែង និងចម្លាក់សម័យមុនអង្គរមួយផង ។

<u>នៅនួយ-សំ</u> ៖ នៅទីនោះ យើងប្រទះឃើញទេវរូបព្រះសិវៈមួយព្រះអង្គ និងព្រះសុរង្គស្ដេចគំលង់ ដែលយើងធ្លាប់ប្រទះឃើញនៅអង្គរវត្តមួយព្រះអង្គផង ។

<u>នៅចន្លោះនួយ-សំ</u> ៖ ប៉ែកខាងត្បូងភ្នំខ្មៅបាថេ នៅក្នុងតំបន់ទាំងនេះ យើងឃើញមានចារឹកថ្មបី ដែលសុទ្ធតែចែងអំពីប្រវត្តិរបស់ស្ដេច ជាហេតុធ្វើឲ្យយើងសន្និដ្ឋានបានថា តំបន់នេះជា «អគ្រឹង» របស់សន្តតិវង្សមហាក្សត្រកម្ពុជាជំនាន់ដើម

<u>នៅកងថឺ</u> ៖ ក្នុងតំបន់នេះ យើងឃើញរូបព្រះសិរៈដ៏ល្អប្រណិតមួយព្រះអង្គធ្វើពីទង់ដែង (Bronze) ។

<u>នៅជុំវិញបៀងហ្វា</u> ៖ នៅក្នុងតំបន់នេះ យើងឃើញរូបរបស់ព្រះលក្សណ៍មួយព្រះអង្គ ដែលជាហេតុធ្វើឲ្យយើងយល់ថា រឿងរាមកេរ្តិ៍របស់ខ្មែរ បានសាយភាយទៅក្នុងតំបន់នៃអាណាចក្រខ្មែរផ្នែកខាងក្រោមនេះដែរ ។

<u>នៅខាងត្បូងត្រាវិញ</u> ៖ នៅក្នុងតំបន់នេះ គេឃើញព្រះពុទ្ធរូបជាច្រើនព្រះអង្គ

ដូចជានៅក្នុងតំបន់បាក់លីវ ដែលសំបូរទៅដោយវត្តអារាមនិងព្រះវិហារផ្នែកខាងព្រះពុទ្ធសាសនាដូច្នោះដែរ ។

នៅជ្រោយសាំងហ្សាក ៖ ក្នុងតំបន់នេះ គេឃើញព្រះពុទ្ធរូបមួយព្រះអង្គដែរ ។

សេចក្ដីសន្និដ្ឋាន ៖ យោលទៅលើតឹកតាងទាំងឡាយ ទាក់ទងនឹងសិល្បៈវត្ថុនិងសីលាចារឹកនានា ដែលបានរៀបរាប់រួចមកហើយ យើងអាចធ្វើសេចក្ដីសន្និដ្ឋានបានថា កូសាំងស៊ីន គឺពិតជាអាណាខេត្តចាស់មួយរបស់កម្ពុជាដែនសមុទ្រ (Cambodge maritime) ។

❑

# ២

# ខ្មែរកូសាំងស៊ីន

ក្រោមចំណងជើងថា «ខ្មែរកូសាំងស៊ីន» លោកបារូ (Barrault) បាននិយាយយ៉ាងច្បាស់អំពីស្ថានភាពអារ្យធម៌ និងប្រជាជននៅកម្ពុជាក្រោមដែលមានលក្ខណៈនិងសញ្ជាតិខ្មែរយ៉ាងពិតឥតប្រកែកបាន ។ ដើម្បីជាសក្ខីកម្មចំពោះទល្អិករណ៍របស់ខ្លួន លោកបារូបាននិយាយដទៃអំពីភូមិសាស្ត្រ សង្គមសាស្ត្រ សេដ្ឋកិច្ច នយោបាយ និងជាតិពិន្ទុនៃកូសាំងស៊ីន នូវអារ្យធម៌ វប្បធម៌ សិល្បៈដ៏សំបូរផ្សេងៗ ដែលមានទ្រង់ទ្រាយនិងរចនាបទ បេះបិទគ្នានឹងសិល្បៈអង្គរ នៅនាកម្ពុជាកណ្ដាលនេះ ។ សិល្បៈស្ថាបត្យកម្មទាំងឡាយដែលបញ្ជាក់នូវលក្ខណៈខ្មែរសំខាន់ៗ មានដូចតទៅនេះ ។

នៅ កាម៉ៅ ចម្ងាយពីប្រាំទៅប្រាំមួយគីឡូម៉ែត្រពីព្រៃនគរ ៖ ក្នុងតំបន់នេះ យើងប្រទះឃើញកំពែងចាស់ៗ ដែលបាក់បែកទៅហើយ គំនរឥដ្ឋហើយនិងទេវរូបនានា ផ្នែកព្រហ្មណនិយមជិះដំរី (សូមអានសៀវភៅរបស់លោក អៃម៉ូនីយេ (Aymonier) ទំព័រ១៣៦ ភាគទី១ និងសៀវភៅរបស់លោកបារូ ទំព័រ១៨) ។

នៅបៀងហ្វា ៖ ក្នុងតំបន់នេះ វត្ថុសិល្បៈបញ្ជាក់អំពីវប្បធម៌ខ្មែរសំខាន់ជាងគេ គឺទេវរូបមួយព្រះអង្គ មានក្បាលដំរី ហើយមានអក្សរចារឹកជាភាសាខ្មែរជាប់ពីលើនោះផង ។

នៅសាដែក ៖ បើគេចូលទៅក្នុងតំបន់សាដែក គេនឹងបានឃើញព្រះវិហារដ៏ល្អមួយ មានទ្រង់ទ្រាយបីដូចជាថៃវ ដ៏ប្រកបទៅដោយបន្ទប់ប្រាំ ។

ចន្លោះ ត្រាំងបាង និង តាយនិញ ៖ នៅចន្លោះតំបន់ត្រាំងបាងនិងតាយនិញ

ដែលជាខេត្តមួយជាប់នឹងខេត្តស្វាយរៀងបច្ចុប្បន្ន យើងឃើញបូរីរបស់ខ្មែរដ៏ធំមួ-យ ដែលសល់មកដល់សព្វថ្ងៃនេះ ។

នៅ ចិនព្រៃ និង ម៉ូកាយ ៖ នៅក្នុងតំបន់ទាំងពីរនេះ គេឃើញមានសំណល់ល្អាងចាស់ៗ ពំនូកដីខ្ពស់ៗ មានទ្រង់ទ្រាយទៅតាមប្លង់នៃស្ថាបត្យកម្មបូរាណ ដែ-លជាកត្តាមួយអាចឲ្យសន្និដ្ឋានបានថាជាគ្រឹះប្រាសាទ ឬព្រះវិហារផ្សេងៗ ។

នៅ ត្រាវិញ ៖ តំបន់ត្រាវិញ មានវត្តជាទីសក្ការៈមួយវិសេសជាងគេ ហៅថាព្រះត្រពាំង ដែលជាទីសក្ការៈនិងជិតទៅដោយរឿងព្រេងអស្ចារ្យដូចជា បារាយណ៍ទឹកថ្លា នៅអង្គរវត្តដែរ ។ តាមន័យ ព្រះត្រពាំងគឺត្រពាំងស័ក្តិសិទ្ធិជាទីគោរពរបស់អ្នកស្រុកនៅទីនោះ ដូចដែលអ្នកស្រុកសៀមរាបគោរពស្រះស្រង់ ឬបារាយណ៍ទឹកថ្លាដូច្នោះដែរ ។

នៅក្នុងខេត្ត សុកត្រាំង និង ត្រាវិញ ៖ ខេត្តទាំងពីរនេះសំបូរវត្តសិល្បៈរបស់ខ្មែរ និងព្រះពុទ្ធរូបច្រើនណាស់ ។ នៅក្នុងអារាមទាំងនោះ គេឃើញមានរឿងនិទានរឿងល្បើកផ្សេងៗ ឆ្លាក់នៅតាមជញ្ជាំងនិងថែវ និយាយរៀបរាប់អំពីប្រវត្តិសាស្ត្រខ្មែរ ។

នៅ រ៉ាច់យ៉ា ៖ នៅក្នុងខេត្តនេះ កន្លែងបូជនីយេសដ៏សំខាន់ជាងគេ គឺវត្តរបស់ខ្មែរមួយ ដែលមានលំអលើសវត្តនានា ។ វត្តនៅខេត្តរ៉ាច់យ៉ា តាំងនៅចម្ងាយពីទីក្រុងខាងលើនេះតែមួយគីឡូម៉ែត្រប៉ុណ្ណោះ តាមផ្លូវចេញពីរ៉ាច់យ៉ាទៅហាទៀង ។

នៅក្នុងខេត្ត ចូដុក ៖ នៅក្នុងខេត្តនេះ យើងឃើញមានវត្តរបស់ខ្មែរជាង៥០ ស្ថិតនៅពាសពេញតែខេត្តក្នុងតំបន់នានាដែលខ្មែររស់នៅ ។

សេចក្តីសន្និដ្ឋាន ៖ ក្រោយពីបានពិនិត្យគ្រប់ទិដ្ឋភាព ទាំងផ្នែកជាតិពិន្ទុ សង្គមកិច្ច អារ្យធម៌ សិល្បៈ សាសនា ។ល។ លោកបារូបានធ្វើសេចក្តីសន្និដ្ឋានថា កូសាំងស៊ីនពិតជាដីរបស់ខ្មែរមែន ។ លោកបានបញ្ជាក់ជាពិសេសថា ដីនេះនៅជាដីរបស់ខ្មែររហូតមកដល់សម័យមួយជិតៗនេះឯង ។

សេចក្តីបញ្ជាក់របស់លោកបារូ ដែលថាកូសាំងស៊ីនជាដីរបស់ខ្មែររហូតមកដ-ល់សម័យជិតៗនេះ គឺជាការល្អត្រឹមត្រូវណាស់ ពីព្រោះអាណានិគមនិយមបារាំងដែលជាអាណាព្យាបាលរបស់ខ្មែរ ក្នុងសម័យបារាំងត្រួតឥណ្ឌូចិន ទើបនឹងបានផ្ទេរដែនដីទៅឲ្យយួនខាងត្បូង នៅឆ្នាំ១៩៤៩មុននេះសោះ ដោយបារាំងបានធ្វើរំលោភច្បាប់អន្តរជាតិ និងច្បាប់អាណាព្យាបាល ។

គួរកត់សំគាល់ថា គណប្រតិភូខ្មែរក្នុងសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ស្តីពីឥណ្ឌូចិន បានតវ៉ាឲ្យសន្និសិទអន្តរជាតិនេះ ផ្តល់ឲ្យខ្មែរនូវសិទ្ធិទាំងឡាយនៅលើកម្ពុជាក្រោម(ដែលបារាំងហៅថាកូសាំងស៊ីន) ដូចជាអធិបតេយ្យភាពនៅលើដីនេះជាដើម

ព្រមទាំងរក្សាសិទ្ធិតវ៉ាយកដីនេះទៀតផង ។ គួរកត់សំគាល់ដូចគ្នានេះដែរថា យួនខាងត្បូងក៏បានទទួលស្គាល់ការពិតទាំងនេះដែរ ។

❑

# ៣

# ប្រាសាទទាំងឡាយរបស់ខ្មែរនៅ កូសាំងស៊ីន (កម្ពុជាក្រោម)

កំណត់សំគាល់ ៖ ក្នុងរឿងទាក់ទងពីកិច្ចពិពណ៌នាអំពីប្រាសាទរបស់ខ្មែរនៅកម្ពុជាក្រោម សូមអ្នកនាងនិងអស់លោកអ្នកអានអញ្ជើញអានសៀវភៅរបស់លោកអឺ.លុយណេត៍ដឺបាហ្សុងគៀរ ភាគទី៣ ទំព័រ៨៨១ (E. Lunet de Bajonquière) ។

កម្ពុជាក្រោម ឬកូសាំងស៊ីន ដោយហេតុថាជាដីរបស់ខ្មែរ ក៏សំបូរដោយប្រាសាទនិងសិល្បៈ ដែលមានទេពកោសល្យខ្ពង់ខ្ពស់ ស្រដៀងគ្នានឹងសិល្បៈនៃប្រាសាទទាំងឡាយនៅកម្ពុជាកណ្តាលនេះដែរ ។ ប្រាសាទសំខាន់ៗនៅកម្ពុជាក្រោម ឬកូសាំងស៊ីន ពិតមែនតែពុំអាចប្រៀបផ្ទឹមទៅនឹងសិល្បៈអង្គរបានក្តី ក៏គង់មានលក្ខណៈរួមគ្នាដែរ ។ ប្រាសាទនានាទាំងនោះ មាននៅរាយប៉ាយស្ទើរតែពេញដែនដីកូសាំងស៊ីន ប្រាសាទទាំងនោះគឺ ៖

ប៉មចុត-មាត់ ឬបាបូ (Tour de Chot Mat ou Ba Bo) ៖ ប្រាសាទនេះ សង់អំពីឥដ្ឋសម័យដើម មានពីរជាន់ រាងដូចជាប៉ម ឬសើន ។ ក្បាច់រចនាពុំសូវសំបូរទេ គឺគ្រាន់តែជាប៉មមួយដែលមានសណ្ឋានដូចប្រាសាទតូចៗខ្លះនៅក្នុងនគរធំ ។

ភ្នំតាយនិញ ៖ នៅក្នុងខេត្តតាយនិញ មានភ្នំមួយហៅថាភ្នំជើងបាដែង ដែលយួនប្រែក្លាយឈ្មោះហៅថា នួយបាដែង ។ នៅលើភ្នំនេះ មានវត្តអារាមជាទីសក្ការៈបូជាមួយផ្នែកខាងព្រះពុទ្ធសាសនារបស់ខ្មែរ ។ ភ្នំជើងបាដាំងនេះ ជាភ្នំមួយកើតមានតាំងពីច្រើនពាន់ឆ្នាំណាស់មកហើយ គឺតាំងពីសម័យដែលមហាអំណាចខមបានត្រួតត្រាដែនដីសុវណ្ណភូមិម្លេះ ។ តាមសួរស័ព្ទរបស់ភាសាខម បាដែងមានន័យថាស្នាមព្រះបាទ គឺថាភ្នំជើងបាដែង ជាភ្នំដែលមានស្នាមព្រះបាទព្រះពុទ្ធជាន់នៅពីលើនោះ ។ គួរកត់សំគាល់ថា ក្នុងសាសនាខម គេពុំមានគោរពព្រះអាទិទេពជាក់លាក់ទេ ក៏ប៉ុន្តែក្នុងអតីតកាលបានដំណាលថា ព្រះពុទ្ធបានទ្រង់និមន្តមកកាន់ដែនដីសុវណ្ណភូមិនេះ ។ ដើម្បីជាកិច្ចគោរពចំពោះព្រះពុទ្ធ ជនជាតិខមជាម្ចាស់នគរបានថែរក្សា ហើយគោរពកន្លែងដែលមានស្នាមព្រះបាទនោះ ជាទីសក្ការៈបូជាតែម្តងទៅ ។

សព្វថ្ងៃនេះ ពួកយួនបានប្រើប្រាស់ភ្នំនេះជាកិច្ចបោកប្រាស់ទាំងផ្នែកសាសនាក៏ដូចជាផ្នែកនយោបាយ ចំពោះអ្នកដែលមានជំនឿផ្សេងៗ ។ ពួកយួនបានរំលោភចូលទៅកាន់កាប់ព្រះវិហារភ្នំជើងបាដែង ហើយដាក់សាសនាកៅដាយនៅទីនោះ ។ សង្ក្រាជកៅដាយបានបោកប្រាស់សាវ័ករបស់ខ្លួនថា ខ្លួនជាតំណាងព្រះម្ចាស់សួគ៌ដើម្បីមកប្រមែប្រមូល និងរៀបចំមនុស្សឲ្យរស់រួមគ្នាក្នុងសង្គមតែមួយ តាមទ្រឹស្តីយេស៊ូគ្រីស្តដែលចែងថា មនុស្សជាបងប្អូនបង្កើតនឹងគ្នា (គឺថាចេញមកពីអាដាំនិងនាងអែវ ជាឪពុកម្តាយតែមួយដូចគ្នា) ។

ពួកកៅដាយ មិនត្រឹមតែធ្វើអាជីវកម្មខាងជំនឿលើខ្មែរនៅតាយនិញ (រោងដំរី) នៃកូសាំងស៊ីនប៉ុណ្ណោះទេ ពួកវាថែមទាំងបានដឹកនាំសាសនាកៅដាយ ក្លែងបន្លំទៅមកដល់កម្ពុជាកណ្តាលឯនេះផង ។ សព្វថ្ងៃមានខ្មែរច្រើនណាស់ ដែលបានបំរើមូលហេតុយួនដោយមិនដឹងខ្លួន ព្រោះតែជឿទៅលើសាសនាកៅដាយនេះ ។ បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានវិហារកៅដាយចំនួន៣៥ស្រេចទៅហើយ វិហារធំជាងគេគឺវិហារស្ថិតនៅក្នុងក្រុងភ្នំពេញនេះតែម្តង មួយនៅចំការមន មួយទៀតនៅស្ទឹងមានជ័យ ក្បែរបន្ទាយជូនក្បួនដឹកនាំនិងអភិបាល ។

ព្រៃប្រាសាទ ឬ បាសាទ ៖ ប្រាសាទនោះមានទ្រង់ទ្រាយជាវិហារតូចមួយសង់អំពីឥដ្ឋ ។ ក្នុងប្រាសាទនោះមានទេវរូប ព្រះវិស្ណុមួយព្រះអង្គ ដែលបាក់បែកខ្លះទៅហើយ ។

តាយនិញ ៖ នៅក្នុងខេត្តតាយនិញឬខេត្តរោងដំរី ក្រៅអំពីវត្តភ្នំជើងបាដែងដែលជាវត្តខាងព្រះពុទ្ធសាសនា ហើយត្រូវយួនរឹបអូសយកទៅធ្វើជាកន្លែងតាំងសាសនាផ្សេងៗដូចជាសាសនាគ្រីស្ត ប្រូតេស្តង់...ចេញ គេប្រទះឃើញលឹង្គព្រះឥស្វរធ្វើអំពីថ្មសំលៀងមួយយ៉ាងធំ មុខលឹង្គមួយកំណាត់ បដិមាករទេពធីតាមួយព្រះអង្គ ដើមដៃទេវរូបមួយកំណាត់ បដិមាករប្រាសាទអាសាករាជមួយ បដិមាករព្រះសិវមួយព្រះអង្គ ដែលមានបល្ល័ង្កទ្រផង រូបមនុស្សប្រុសមួយ បដិមាករព្រះវិស្ណុតូចមួយព្រះអង្គ រូបមនុស្សមួយក្រុមមានគ្នាបីនាក់ ហើយនិងប្រដាប់ប្រដាចង្ក្រានជើងឆ្កាំងនិងប្រដាប់ប្រដាផ្សេងដទៃទៀត ។

ចម្លាក់នៅ ត្រាន់ឌៀន (Tranh Dien) ៖ នៅតំបន់ត្រាន់ឌៀន មានវត្តមួយកសាងឡើងលើកន្លែងប្រាសាទចាស់មួយ ។ ដទៃពីនេះ គេឃើញមានបដិមាករបាក់បែកខ្លះ ដែលសព្វថ្ងៃនេះអ្នកស្រុកនៅទីនោះបានជួសជុលប៉ះប៉ុនខ្លះៗ ។

បុងបីន (Bung Binh) ៖ នៅលើច្រាំងម្ខាងនៃព្រែកព្រៃនគរ យើងឃើញមានសំណល់ព្រះវិហារ <ប្រាសាទ?> មួយដែលទើបនឹងបាក់វេក ។

ទៀងថាន់ ប៉ែកខាងកើត (Tien Thanh-Est) ៖ នៅក្នុងកន្លែងនេះ យើងឃើញ

ស្ពានព្រះបាទតូចមួយ ធ្វើអំពីឥដ្ឋដែលទើបនឹងត្រូវគេវាយរំលំហើយគាស់ចោល ។ នៅកន្លែងដដែលនោះ គឺមានតួប្រាសាទតែម្តង មានព្រះបដិមាករ ព្រះសិរ:មួយព្រះអង្គសល់នៅឡើយ ។

ទៀងថាន់ ប៉ែកខាងលិខ (Tien Thanh Ouest) ៖ នៅកន្លែងនេះគេឃើញកូនភ្នំមួយ ដែលមានសុទ្ធតែបំណែកកំទេចកំទីថ្ម ឥដ្ឋយ៉ាងច្រើន ដែលមានហេតុមួយបញ្ជាក់ឲ្យដឹងថា កន្លែងនោះជាកន្លែងមួយ ដែលគេបានកសាងប្រាសាទធ្វើអំពីឥដ្ឋ។

ភឿកថាន់ (Phuoc-Thanh) ៖ កន្លែងនេះដូចជានៅទៀងថាន់ប៉ែកខាងលិចដែរ មានភ្នំតូចមួយ បញ្ជាក់ឲ្យដឹងថាជាកន្លែងប្រាសាទ ។

ឡុកហ៊ុង ប៉ែកខាងត្បូង (Loc Hung Sud) ៖ នៅកន្លែងនេះ យើងឃើញមានដីទួលដ៏សាមញ្ញមួយតែប៉ុណ្ណោះ ។

ឡុកហ៊ុង ប៉ែកខាងជើង (Loc Hung Nord) ៖ កន្លែងនេះយើងសង្កេតឃើញមានឥដ្ឋធំៗដែលមានស្លៃរំជិត មានសភាពដូចជាថ្មរលីង ហើយយ៉ាងច្រើន ដែលជាហេតុមួយអាចឲ្យយើងសន្និដ្ឋានថា កន្លែងនេះពិតជាទីតាំងរបស់ប្រាសាទ ។

អានវ៉ា (An Hoa) ៖ នៅតំបន់អានវ៉ា សំណល់ដែលអាចបញ្ជាក់អំពីសិល្ប:របស់ខ្មែរបាន គឺមានដំបូកដីខ្ពស់មួយ ស្រះមួយ និងផ្ទាំងថ្មបាយក្រៀមផ្សេងៗទៀត ។

ភឿកហ៊ុង (Phuoc Hung) ៖ នៅកន្លែងនេះ សក្ខីកម្មបញ្ជាក់អំពីស្ថាបត្យកម្មនិងសិល្ប:របស់ខ្មែរមានដូចតទៅ ៖ ល្អាងយ៉ាងធំមួយ រូបរាងប្រាសាទមួយកសាងក្នុងដី មេទ្វារប្រាសាទយ៉ាងធំមួយ បដិមាករវិស្ណុតូចមួយព្រះអង្គ លិង្គព្រះឥសូរមួយ

រុងដូ ប៉ែកខាងត្បូង (Runh Dau Sud) ៖ កន្លែងនេះមានស្នាមប្រាសាទច្បាស់ជាងគេ ដោយហេតុថាយើងសង្កេតឃើញសំណល់ប្រាសាទតូចមួយ ហើយនិងបដិមាករបាក់បែកពីរបីព្រះអង្គ ។

រុងដូ ប៉ែកខាងជើង (Runh Do Nord) ៖ ដូចរុងដូប៉ែកខាងត្បូងដែរ រុងដូប៉ែកខាងជើងក៏ជាទីតាំងចាស់នៃប្រាសាទមួយដែលទើបនឹងបែកបាក់ ។ ហេតុបានជាហ៊ាននិយាយដូច្នេះ ពីព្រោះឃើញមានគ្រឹះប្រាសាទមួយសល់នៅទីនោះនៅឡើយ ព្រមទាំងមានបដិមាករបាក់បែកខ្លះៗថែមទៀតផង ។

ភឿកមី (Phuoc Mi) ៖ តំបន់នេះមានប្រាសាទមួយដែលទំនៀមទំលាប់បានអះអាងបញ្ជាក់អត្ថិភាពរបស់វា ។

សិលាចារឹកនៅព្រៃនគរ ៖ នៅកណ្តាលក្រុងព្រៃនគរ ដែលជាទីក្រុងធំមួយរបស់កម្ពុជាដែនសមុទ្រ (ទីក្រុងយួនខាងត្បូងសព្វថ្ងៃ) គេឃើញមានសសរស្តម្ភពីរដែលមានសុទ្ធតែចារឹកជាភាសាខ្មែរ និងសំណល់សិល្ប:នានាទៀតរបស់ខ្មែរ ។ សីលាចារឹកទាំងពីរនោះតាំងនៅក្រុងច្រឺឡឹង ដែលជាសង្កាត់មួយនៃព្រៃនគរ ។

ថាប់មុីយប្រាំល្វែង (Thap Muoi Pram Loveng) ៖ នៅតំបន់នេះ ស្លាបត្យកម្មខ្មែរមានពិតប្រាកដឥតប្រកែកបានឡើយ ដោយសារមានតួប្រាសាទមួយនៅសល់នៅឡើយ រហូតមកដល់សព្វថ្ងៃ ។ អ្នកស្រុកនៅទីនោះ ហៅប្រាសាទនេះថា «ប្រាសាទប្រាំល្វែង» ។

សីលាចារឹកថាប់មុីយ ៖ នៅថាប់មុីយ គេបានប្រទះសសរស្តម្ភ៥ ដែលសុទ្ធតែមានចារឹកអក្សរខ្មែរនៅលើសសរទាំងនោះរៀងៗខ្លួន ។ ក្នុងសសរស្តម្ភនីមួយៗ គេឃើញមានអក្សរចារឹកប្រហែល២០បន្ទាត់ ។

សីលាចារឹកនៅភូហ៊ុយ (Inscription de Phu Huu) ៖ នៅភូហ៊ុយ វត្ថុដ៏សំខាន់បំផុត បញ្ជាក់អត្ថិភាពសិល្បៈនិងវប្បធម៌ខ្មែរនៅទីនោះ គឺចារឹកថ្មមួយដែលសរសេរដោយភាសាសំស្ក្រឹតពីរបន្ទាត់ និងភាសាខ្មែរដប់បន្ទាត់ ។

ភ្នំបាថេ (Phnom Ba Thé) ៖ នៅភ្នំបាថេ វត្ថុដែលជាសក្ខីកម្មសិល្បៈរបស់ខ្មែរឥតប្រកែកបាន គឺការដែលឃើញមានសំណល់ប្រាសាទមួយនិងចារឹកថ្មពីររួមផង។

វិញតេ (Vinh Thé) ៖ នៅវិញតេ យើងឃើញមានសំណល់អារ្យធម៌ខ្មែរច្រើនបង្គួរណាស់ គឺមានសំណល់នៃព្រះវិហារបាក់បែកយ៉ាងច្រើនកន្លែង លឹង្គព្រះឥសូរមួយថ្មសំលៀងផ្សេងៗ ដែលមានអាយុតាំងពីយុគថ្មសំលៀង ហើយនិងសសរស្តម្ភបីទៀត ដែលខ្លះបានបាក់បែកខ្លះទៅហើយ និងខ្លះទៀតរលប់ដោយមានទាំងអក្សរចារឹកនៅឡើយសំ ចម្ងាយ៧គីឡូម៉ែត្រ ពីចូដុកថែមទៀតផង ។

សីលាចារឹកវត្តថ្លែង Ϊnscription de Vat Thleng) ៖ នៅវត្តថ្លែង គេប្រទះឃើញចារឹកមួយនៅថ្មីទែង ឥតទាន់មានរលុបអ្វីបន្តិចឡើយ ហើយដែលមានចារឹកអក្សរដល់ទៅ២៧បន្ទាត់ឯណោះ ។

ថាប់ប្រឡង (Thap Pra Long) ៖ នៅខេត្តសុកត្រាំង មានប្រាសាទធ្វើអំពីឥដ្ឋមួយ ដែលបាក់បែកអស់ទៅហើយ ហៅថាប្រាសាទថាប់ប្រឡង ។

ទាអុីហូ (Tea I Ho) ៖ ក្នុងតំបន់នេះ យើងឃើញប្រាសាទមួយសល់នៅឡើយ ប្រាសាទនោះកសាងអំពីឥដ្ឋ ហើយមានទេវរូបព្រះវិស្ណុតាំងនៅក្នុងនោះមួយព្រះអង្គផង ។

❑ ❑

❑

# ជំពូក២

# ទល្លិករណីផ្នែកលើ អត្ថបទ និង ផែនទី

១- <u>ការសំអាងលើផ្នែកអត្ថបទ</u> ៖

លោក ប៉ុល្លីយ៉ូតី (Polliot) បានសរសេរ (ហើយការនេះ ទោះមកដល់សព្វថ្ងៃនេះហើយក្តី ក៏ពុំមានលក្ខណៈផ្ទុយនឹងការអះអាងរបស់អ្នកប្រាជ្ញឡើយ) ថាកូសាំងស៊ីនក្រោម (Basse Cochinchine) ឬកូសាំងស៊ីនបារាំង ឬប្រទេសព្រៃនគរ ជាដែនដីពីដើមរបស់ព្រះរាជាណាចក្រហ្វូណន (កម្ពុជា) ។ ក្នុងករណីនេះ សូមអញ្ជើញអានសៀវភៅរបស់លោក ស.ប៊ូសូតី ស្តីពីព្រៃនគរ ត្រង់ទំព័រទី៧ (J. Bouchot, Saigon, page 7) ។

តាមឯកសារទាំងឡាយ ទោះជាភាសាខ្មែរក្តី និងជាភាសាអណ្ណាមក្តី យើងបានស្រាវជ្រាវឃើញថា នៅឆ្នាំ១៦២៣ ព្រះចៅប្រទេសអណ្ណាមបានបញ្ជូនគណៈប្រតិភូមួយ មកគាល់ព្រះចៅប្រទេសកម្ពុជានៅរាជធានីឧដុង្គ ដែលមានបេសកកម្មថ្លែងសេចក្តីសរសើររបស់ព្រះចៅអណ្ណាម ចំពោះព្រះចៅក្រុងកម្ពុជា ហើយទូលសុំពីព្រះចៅកម្ពុជានូវ «ព្រះរាជបញ្ញត្តិតាំងកុងត្វាអណ្ណាម នៅក្នុងផ្នែកខាងត្បូងបំផុតនៃប្រទេសកម្ពុជា (ព្រៃនគរ)» ។ ព្រៃនគរដែលយួនហៅថាសៃហ្គនោះ ជាចំណុចចាស់ដ៏សំខាន់បំផុតមួយនៃវិស័យពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា នៅក្នុងប៉ែកខាងត្បូង (ស.ប៊ូសូតី, ព្រៃនគរ, ទំព័រទី១២) ។

«ការដែលជាក់ស្តែងបំផុត គឺនៅត្រង់ការដែលថា នៅក្នុងឆ្នាំ១៦៥៤ ប្រជារាស្ត្រកូសាំងស៊ីនយ៉ាងច្រើន ដែលមានតាំងពីមនុស្សអារ៉ាសៃ មនុស្សរត់ចោលកងទ័ព ពួកចោរប្លន់ ឬមនុស្សជំពូកដទៃផ្សេងទៀត បានចូលមកប្រទេសកម្ពុជា រួចចូលទ្បុកឡុំជាមួយប្រជារាស្ត្រស្រែចំការ រួចហើយក៏តាំងនៅក្នុងប្រទេសនេះតែម្តង ដោយក្តាប់ជាពិសេសនូវវិស័យកសិកម្ម ។ ពួកមនុស្សទាំងនោះគឺផ្តុំគ្នា ជាពិសេសនៅម៉ូ-ស៊យ (Mo Xoai) ក្នុងខេត្តបារៀ និងដូនណាយ ក្នុងខេត្តបៀងហ្វា ។ ដូច្នេះ ប្រទេសកម្ពុជាប៉ែកខាងត្បូងនេះ បានត្រឡប់បន្តិចម្តងៗ ទៅជាប្រទេសអណ្ណាមខ្លាំងជាងជាប្រទេសកម្ពុជា» (សូមអានមេរៀនប្រវត្តិសាស្ត្រយួន សៀវភៅទី២ ក្បាលទី៥ ទំ

ព័រ១៣៥-១៣៦ របស់លោកគី Cours d'histoire annamite Vol. II, Tome V. Ky, page 135-136) ។

នៅឆ្នាំ១៦៧៥ «រដ្ឋាភិបាលអណ្ណាមប្រគល់ឲ្យប្រទេសកម្ពុជា ក្រោយពីសន្តិភាព នូវក្រុងព្រៃនគរ ខេត្តបារៀ ហៀងហ្វា ព្រមទាំងខេត្តនានាផ្សេងទៀតមិតនៅតាមព្រំដែន» ដែលខ្លួនបានរុករានក្នុងឱកាសវិបរិតផ្ទៃក្នុងរបស់ខ្មែរ ។ (សូមអានសៀវភៅរបស់លោក ស.ប៊ូសូតី, ព្រៃនគរ, ទំព័រ១៦ និងលោកម៉ៀរ៉ា (Moura) ទំព័រ៦៤) ។

នៅក្នុងមេរៀនប្រវត្តិសាស្ត្រអណ្ណាម ត្រង់ទំព័រទី១៣៥ដដែល លោកគីបានសរសេរថា ៖ «ចៅហ្វាយខេត្តខ្មែរម្នាក់នៅក្នុងដែនដីប៉ែកខាងត្បូងនៃប្រទេសកម្ពុជា ដែលទទួលបន្ទុកយ៉ាងពិតឥតប្រកែកបានខាងការពារការជ្រៀតចូលនៃប្រជារាស្ត្រអណ្ណាមមកក្នុងប្រទេសកម្ពុជា បានប្រាប់ស្តេចប្រទេសខាងត្បូង (យួន?!) ថា ព្រះចៅអង្គចាន់ ទ្រង់បង្គាប់ឲ្យប្រើកម្លាំងទ័ព ដើម្បីទប់ទល់ពួកអណ្ណាមទាំងនោះ ដែលកំពុងតែប្លន់ លួច និងធ្វើទុក្ខបុកម្នេញ ព្រមទាំងសម្លាប់ប្រជាជនខ្មែរ...» ។

សូម្បីតែសៀវភៅរបស់គាត់ឈ្មោះ យ៉ាឌិនទិងជី (Gia Dinh Tung Chi) ក្នុងរវាងឆ្នាំ១៨៣០ ក៏បានទទួលស្គាល់យ៉ាងស្មោះបំផុត (parfaitement) ថា «ដែនដីទាំងអស់នៃខេត្តម៉ូស៊ុយ និងដូនណាយ (យួនហៅថា Mo-Xoai et Dong-Nai) ត្រូវបានពួកយួនអណ្ណាមអាវ៉ាសែកាន់កាប់» ដែរ ហើយយួនអណ្ណាមអាវ៉ាសែទាំងនោះបានទាំងចូលទៅរស់នៅលាយឡំជាមួយអ្នកស្រុកកម្ពុជាថែមទៀតផង ។ លោក ត្រាំងហួយឌឹក បានបន្ថែមទៀតថា ពួកនោះក្តាប់វិស័យកសិកម្ម ។ «ខ្មែរ ដែលខ្លាចសន្តតិវង្សអណ្ណាមពេកទៅ ឥតហ៊ានប្រឆាំងនឹងរបៀបធ្វើអាណានិគម និងការកាន់កាប់ដីដែលជារបស់ខ្លួននេះសោះឡើយ» នេះជាឃ្លាមួយរបស់ ស.ប៊ូសូតី (J. Bouchot) ទំព័រទី១៥ ។

២- <u>ភស្តុតាងផ្អែកលើផែនទី</u> ៖

បន្ថែមលើភស្តុតាងទាំងឡាយនៃអត្ថបទ យើងត្រូវរាប់បញ្ចូលផងដែរ នូវភស្តុតាងផែនទីដែលគេអាចគូរឡើងនៅក្នុងសម័យនានានៃប្រវត្តិសាស្ត្ររបស់ប្រទេសឥណ្ឌូចិន ។

១/ <u>ផែនទីឥណ្ឌូចិននៅសតវត្សទី៧និងទី៨</u> ៖

តាមផែនទីទាំងនេះ យើងបានមើលឃើញយ៉ាងច្បាស់លាស់បំផុត អំពីទីតាំងរបស់ប្រទេសកម្ពុជា ដោយនិយាយធៀបប្រៀបទៅនឹងប្រទេសជិតខាងរបស់ខ្លួន គឺប្រទេសសៀម ប្រទេសលាវ ប្រទេសអណ្ណាម និងនគរចំប៉ា ។ ក្នុងសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជា ត្រង់ទំព័រទី១១ (Histoire du Cambodge, Madrolle) លោកម៉ាដ្រុល្ល បានសរសេរដូច្នេះថា «ផ្នែកដែនដីដែលបារាំងហៅថាកូសាំងស៊ីន

បារាំងនោះ គឺជាដែនដីរួមនៅក្នុងព្រំដែនព្រះរាជាណាចក្រកម្ពុជា ហើយគឺជាផ្នែកទាំងស្រុងមួយនៃបូរណភាពទឹកដីរបស់ខ្មែរ (គឺថាជាដីខ្មែរទាំងស្រុង)» ។

២/ ផែនទីឥណ្ឌូចិនមួយទៀតគូរនៅឆ្នាំ១៥៩៣ ៖

ចំនួន៧០០ឆ្នាំក្រោយមក គឺនៅក្នុងឆ្នាំ១៥៩៣ ផែនទីឥណ្ឌូចិនមួយទៀតដែលគេបានគូរជាថ្មី ឥតមានកែប្រែគំនូស (Tracés) របស់ដែលគូរនៅសតវត្សទី៧សោះទេ ។ កូសាំងស៊ីនក្រោម ដែលកើតឡើងដោយដីដុះ និងល្បប់ទន្លេមេគង្គ ជាទីតាំងបន្តនៃប្រទេសកម្ពុជានៅលើដីដុះជាធម្មជាតិ (Contenuation géologique) នៃប្រទេសគោកធ្លក (នាមប្រទេសផុសពីសមុទ្រ ដោយមានដើមធ្លកដុះនៅពីលើផង) ។

ក្នុងរឿងនេះ សូមមើលផែនទីនៅក្នុងសៀវភៅ «ប្រវត្តិសាស្ត្រដីអាណានិគមរបស់បារាំង» ទំព័រទី៣២៥ ក្បាលទី៥ (Carte de l'Indochine, India Orientalis de l'Atlas Urtelius 1593 Histoire des Colonies françaises Vol. V, page 325) ។

៣/ ផែនទីឥណ្ឌូចិនគូរនៅឆ្នាំ១៦៣៤ ៖

ចំនួន៣០ឆ្នាំក្រោយមកទៀត គេបានគូរផែនទីមួយទៀតដែរ ដែលបានបង្ហាញយ៉ាងច្បាស់ថា «កូសាំងស៊ីនបច្ចុប្បន្នដែលជាដែនដីប៉ែកសមុទ្ររបស់ប្រទេសកម្ពុ-ជានៅតែជាដីទាំងមូលរួមទាំងក្នុងប្រទេសកម្ពុជា ។ ប្រទេសនេះ(កម្ពុជា) សន្ធឹងតែម្នាក់ឯងគត់ រហូតទៅដល់សមុទ្រ ដែលជាព្រំដែនខាងត្បូង និងអគ្នេយ៍របស់ប្រទេសនេះ» (Histoire des Colonies françaises Vol. V, page 325 Carte India Orientalis extraite de l'Atlas Morentor, 1628) ។

៤/ ផែនទីរបស់លោកគ្រូរ៉ូដ ឆ្នាំ១៦៥០ ៖

នៅក្នុងផែនទីខាងលើនេះ លោកគ្រូរ៉ូដ (Père Rodes) បានចង្អុលយ៉ាងទៀងទាត់បំផុត អំពីកន្លែងប្រទេស «កូសាំងស៊ីន» គឺអណ្ណាមបច្ចុប្បន្ន ដោយប្រៀបធៀបទៅនឹងព្រះរាជាណាចក្រចំប៉ានិងព្រះរាជាណាចក្រកម្ពុជា ថាគ្រាន់តែជាខេត្ត ឬប្រទេសអណ្ណាមមួយដែលសន្ធឹងពីព្រំដែនចិនប៉ែកខាងលិច ចុះមកទល់ព្រំប្រទល់ខាងជើងរបស់ប្រទេសចំប៉ា (១) ប្រវត្តិសាស្ត្រដីអាណានិគមរបស់បារាំង ក្បាលទី៥ ទំព័រទី៣៣១ (Histoire des Colonies françaises Vol. V, page 331) ។

៥/ ផែនទីមហាអាស៊ីបូព៌ា ៖

ផែនទីមហាអាស៊ីបូព៌ា(ដែលសំគាល់តំបន់សមុទ្រប៉ែកខាងត្បូង) គូរនៅសម័-យបារាំងរុករានអាស៊ី បានដាក់ព្រំដែនយ៉ាងច្បាស់លាស់បំផុត ឲ្យរាជាណាចក្រតុង

(១) *សូមអញ្ជើញអានសៀវភៅ «យួនរំាតដីពីកូសាំងស៊ីនមកកម្ពុជាក្រោម» របស់លោក ជុកសាំង និងលោកទេព-គីរក្ស ។*

កឹង រាជាណាចក្រកូសាំងស៊ីន (ប្រទេសអាណ្ណាម) ហើយនិងការចូលទៅពាក់ពីលើនគរចំប៉ា (ដំណើ្តមចំប៉ា) នៃពួកយួន ។ ផែនទីនេះបានទាំងបង្ហាញយ៉ាងច្បាស់ពីប្រទេសកម្ពុជា ដែលសន្ធឹងចាប់តាំងពីព្រំប្រទល់នៃប្រទេសលាវ រហូតទៅដល់សមុទ្រ (តាមខ្សែទន្លេមេគង្គ) ដោយក្រសោបកូសាំងស៊ីនបារាំងទាំងមូល ដែលជាផ្នែកទាំងស្រុងមួយរបស់ព្រះរាជាណាចក្រខ្មែរ ។

៦/ ផែនទីឥណ្ឌូចិនរបស់ រ៉ូបែរ គូរក្នុងឆ្នាំ១៧១៧ ៖

ផែនទីមួយទៀត ដែលគូរដោយរ៉ូបែរ (Robert) ក្នុងឆ្នាំ១៧១៧ នៅក្នុងសៀវភៅ (ឥណ្ឌូចិន ៖ L'Indochine) ទំព័រ១១៧ ក្បាលទី១បានផ្តល់ឯកសារថ្មីមួយទៀតថា កូសាំងស៊ីនជាផែនដីរបស់កម្ពុជា ។

៧/ ផែនទីរបស់លោក ឌៀរវិល ឆ្នាំ១៧៥៥ ៖

ពេលខាងក្រោយបន្តិចមក គឺមុនសន្ធិសញ្ញាក្រុងវែរសៃ ឆ្នាំ១៧៨៧ (Traîté de Versailles de 1787) ដែលចុះហត្ថលេខារវាង អេវើកដាឌ្រង់ (Evêque d'Adran) ជាជំណាងប្រទេសអណ្ណាមនិងប្រទេសបារាំង ហើយដែលតាមសន្ធិសញ្ញានេះ អេវើកដាឌ្រង់ បាននាំនាយទាហានបារាំងមួយក្រុមចូលមកវាយយកកូសាំងស៊ីនក្រោម (កូសាំងស៊ីនទំនាប) បានបង្ហាញយ៉ាងច្បាស់ថា កូសាំងស៊ីនក្រោមឬកម្ពុជាក្រោម ជាដីទាំងស្រុងរបស់ប្រទេសកម្ពុជា (សៀវភៅឥណ្ឌូចិនក្បាលទី១ ទំព័រ១៣៥ (L'idochine, tome I, page 135) ។

៨/ ផែនទីខេត្តកូសាំងស៊ីនក្រោម ឬកម្ពុជាក្រោម ៖

នៅក្នុងរឿងផែនទីខេត្តកូសាំងស៊ីនក្រោមនេះ យើងមានតាតព្វកិច្ចត្រូវតែធ្វើសេចក្តីកត់សំគាល់សំខាន់ៗដូចខាងក្រោមនេះ ។ យើងសូមបញ្ជាក់ថា ផែនទីនេះដកស្រង់ចេញពីផែនទីរបស់លោក ប៉ាល់លុយ ក្នុងសៀវភៅ «ប្រវត្តិវាតដីនៃកូសាំងស៊ីន ឆ្នាំ១៨៦៤ ៖ Histoire de l'expédition de Cochichine 1864 ។ ក្នុងករណីនេះ សូនអានសៀវភៅ Histoire des Colonies françaises Vol. V, page 386 ដែលយើងបានគូសបង្ហាញជាហូរហែពីខាងលើ) ។

ក- ផែនទីនេះ ជាស្នាដៃរបស់ជនជាតិបារាំងឈ្មោះ ម៉ារាំង វិដាឡាំង និង ហារ៉ង ( Marin, Vidalin et Harand) ដែលសុទ្ធសឹងជា ភូឈ្មួយវិស្វករជលសាស្ត្រនៃកងនាវាចរបារាំង ។ ផែនទីនេះត្រូវបានអស់លោកទាំងបីនេះគូរនៅឆ្នាំ១៨៨១ និង១៨៨២ ដើម្បីភ្ជាប់នៅក្នុងសំណុំរឿងសន្ធិសញ្ញាថ្ងៃ៥មិថុនា១៨៨២ ចុះហត្ថលេខារវាងប្រទេសបារាំងនិងប្រទេសអណ្ណាម ស្តីពីដែនដី «នគរសៃកុង» (Pays de Saigon) ។ សន្ធិសញ្ញានេះ បារាំងបានបង្ខំឲ្យប្រទេសអណ្ណាមចុះហត្ថលេខា ដើម្បីខ្លួនលួចយកដីខ្មែរ ពីព្រោះក្រុងព្រៃនគរទើបនឹងធ្លាក់ទៅក្នុងដៃយួនក្នុងឆ្នាំ១៨៨២ប៉ុ

ណ្ណោះ ។ សន្ធិសញ្ញានេះ គឺជាជំហានទី១ ដែលបញ្ជាក់អំពីការរុករានដោយកម្លាំងទ័ពរបស់បារាំងទៅលើឥណ្ឌូចិន ។

ខ- អាស្រ័យតាមផែនទីខាងលើនេះ យើងបានឃើញជាលើកដំបូងបំផុត នូវឈ្មោះជាភាសាយួនហៅខេត្តខ្មែរ នៅក្នុងដែនដីប៉ែកសមុទ្រ ដូចជាថា បៀងហ្វា យ៉ាឌិន ឌិនទួង វិញឡុង អានយ៉ាង ហាទៀង ជាជំនួសឈ្មោះរបស់ខ្មែរថា កំពង់ស្រកាត្រី ព្រៃនគរ មេ-ស លង់ហោរ មាត់ជ្រូក ពាម(មួងខាំ) ជាដើម ។

គោលបំណងជាសារវ័ន្តរបស់បារាំង នៅក្នុងការគូរផែនទីនេះគឺ ៖ «បង្កើតអាណានិគមមួយ នៅក្នុងកូសាំងស៊ីនក្រោម» ។ ពួកបារាំងទាំងបីនាក់នេះ ដោយមានការស្ទាក់ស្ទើរក្នុងចិត្តនៅឡើយ បានផ្តើមកំណត់ដែនដីសណ្តរនៃស្ទឹង(កម្ពុជា) ដោយបំបែកជាពីរតំបន់ពីរដាច់ពីគ្នា ហៅថា «ខេត្តខាងកើត» និង «ខេត្តខាងលិច» ។ «ខេត្តខាងកើត» ដែលពួកគេនោះឲ្យហៅថា (ខេត្តបារាំង) មានរួមខេត្តបៀងហ្វា យ៉ាឌិន ឌិនទួង ត្រូវបារាំងកាន់កាប់ ។

គ- ចំណែកខាងព្រំដែនខាងជើងនិងខាងលិច នៃខេត្តព្រៃនគរ និងព្រំដែនទាំងអស់ដែលបារាំងគូស (ដូចជាព្រំដែនខេត្តតានិញ តាន់អាន ចូដុក ហាទៀង) ដើម្បីកំណត់ព្រំដែនសមុទ្ររបស់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងគោលបំណងដណ្តើមខេត្តទាំងនោះ បារាំងបានបង្ខំឲ្យព្រះបាទនរោត្តម តាមសន្ធិសញ្ញាថ្ងៃ១១សីហា១៨-ដាក់ប្រទេសខ្មែរក្រោមអាណាព្យាបាលរបស់បារាំង ឲ្យដាក់ខេត្តទាំងនេះក្នុងការកាន់កាប់របស់បារាំង ចាប់ពីឆ្នាំ១៨៧០ទៅ ។ គឺឧត្តមនាវីឡាហ្គ្រង់ឌីយ៉ែរ (Amiral Lagrandière) តែម្តងដែលបានកាន់កាប់ «ខេត្តខាងលិច» នៅឆ្នាំ១៨៦៧ ។

ឃ- នៅឆ្នាំ១៨៧៤ ក្រោយពីបានគូរផែនទីហៅថា «ខេត្តកូសាំងស៊ីនក្រោម» រួចមក ប្រទេសបារាំងបានបង្ខំឲ្យប្រទេសអណ្ណាមទទួលស្គាល់អធិប្បតេយ្យភាពរបស់ខ្លួន ទៅលើដីខ្មែរទាំងនោះ ក្នុងព្រំប្រទល់នានា គូសដោយសេចក្តីសំរេចកំណត់ព្រំដែនរវាងប្រទេសកម្ពុជានិងកូសាំងស៊ីន ដែលឧត្តមនាវីឡាហ្គ្រង់ឌីយ៉ែរ បានបង្ខំឲ្យព្រះបាទនរោត្តមចុះព្រះហត្ថលេខានៅឆ្នាំ១៧៧០ ។

❑ ❑

❑

# ជំពូក៣
# ភ័ស្តុតាងផ្នែកប្រវត្តិសាស្ត្រ

កូសាំងស៊ីនដែលត្រូវធ្លាក់ទៅជាដីអាណានិគមរបស់បារាំង នៅក្នុងភាគទី២នៃសតវត្សទី១៩នោះ, គឺចាប់ពីថ្ងៃ៥មិថុនា១៨៦២ រហូតដល់ខែមិនា១៩៥៤ នៅជាដីរបស់ខ្មែររហូត ។

ដីខ្មែរផ្នែកនេះ ដើមឡើយមាន៦ខេត្តគឺ ៖

ក/ <u>អាណាខេត្តទាំងឡាយនៅប៉ែកខាងកើត</u> ៖

| <u>ឈ្មោះរបស់ខ្មែរ</u> | <u>ឈ្មោះយួនកែប្រែ</u> |
|---|---|
| ១- កំពប់ស្រកាត្រី | បៀងហ្វា |
| ២- ព្រៃនគរ | យ៉ាឌិន |
| ៣- មេ-ស | ឌិនទួង |

ខ/ <u>អាណាខេត្តទាំងឡាយនៅប៉ែកខាងលិច</u> ៖

| <u>ឈ្មោះរបស់ខ្មែរ</u> | <u>ឈ្មោះយួនកែប្រែ</u> |
|---|---|
| ១- លង់-ហោ | វិញឡុង |
| ២- មាត់ជ្រូក | អានយ៉ាង |
| ៣- ពាម ឬមួងឫស្សី | ហាទៀង |

ផ្នែករដ្ឋបាលនានាក្នុងខេត្តទាំងនេះ សុទ្ធសឹងជាស្នាដៃរបស់បារាំងទាំងអស់ សោតឯព្រំប្រទល់រវាងអតីតព្រះរាជាណាចក្រកម្ពុជានិងកូសាំងស៊ីន ក៏ជាស្នាដៃសន្ធិសញ្ញាធ្វើឡើងដោយកម្លាំងបាយរបស់បារាំងដែរ ។

## វគ្គទី១
## ការចូលកាន់កាប់នៃយួនអណ្ណាម
## នូវខេត្តខ្មែរប៉ែកខាងត្បូង

ការចូលជ្រៀតជ្រែកនៃពួកយួនអណ្ណាមមកលើដីខ្មែរ បានកើតមានជាលើកដំបូងបង្អស់ នៅក្នុងរជ្ជកាលព្រះបាទជេដ្ឋាទី២ ដែលគេនិយមហៅរត់មាត់ជាងគេថាព្រះ

ជ័យចេស្ដា ។ ក្សត្រអង្គនេះ ក្រោយពីត្រឡប់មកពីប្រទេសសៀមភ្លាម បានរៀបអភិសេកនៅឆ្នាំ១៦១៨ ជាមួយក្សត្រីយ៍យួនមួយអង្គឈ្មោះជូ (Chua) នៃរាជវង្សង្វៀង ។ ការចូលមកក្នុងសន្ដតិវង្សខ្មែរនៃក្សត្រីយ៍យួននេះ បានហុចឱកាសចំហឲ្យយួនអណ្ណាមលូកដៃជ្រៀតជ្រែកមកយ៉ាងស្រួលបំផុតទៅក្នុងកិច្ចការរបស់ខ្មែរ ។ គឺដោយសារតែក្សត្រីយ៍ជូនេះហើយ ទើបបានជាគណប្រតិភូទូតអណ្ណាមមួយ បានទទួលពីព្រះបាទជ័យជេដ្ឋាទី២ នៅឆ្នាំ១៦២៣ នូវសេចក្ដីអនុញ្ញាតឲ្យបង្កើតកុងត្វាជំនួញ នៅព៉ៃកខាងត្បូងបំផុតនៃព្រះរាជាណាចក្រខ្មែរ ព្រមទាំងទទួលសិទ្ធិឲ្យរួចពន្ធគយនិងរង្គាករនៅព្រៃនគរទៀតផង (សូមអានសៀវភៅ «ព្រះរាជាណាចក្រកម្ពុជា» និពន្ធដោយលោកម៉ូរ៉ា ក្បាលទី២ (Le Royaume du Cambodge par Moura, Tome II, Paris Emest Leroux Editeur-1883) និង «មហាអាណាចក្រខ្មែរ» របស់លោកម៉ាស្ប៉ឺរ៉ូ (L'Empire Khmer par G. G. Maspero - Imprimerie du Protectorat 1904) ។

ព្រះបាទជ័យជេដ្ឋាទី២បានចូលសុវណ្ណកោដ្ឋនៅឆ្នាំ១៦២៥ ក្នុងព្រះជន្មាយុ៥២ព្រះវស្សា ។ ព្រះអង្គបានបង្កើតជាមួយមហាក្សត្រីយ៍យួននូវព្រះរាជបុត្រីមួយកាត់ព្រះអង្គ ដែលក្រោយមកបានជាមហេសីរបស់ព្រះបាទបទុមវង្សាធិរាជាមាធិបតី ។

ស្ដេចអង្គនេះបានលើកក្សត្រីយ៍កូនកាត់នេះ ជាមហាក្សត្រីយានី ដោយមានគោរម្យងារថា ព្រះភាសាវតីព្រះវររាជក្សត្រី ។ ព្រះបាទបទុមវង្សនិងមហាឧបរាជបានសុគតនៅឆ្នាំ១៦៣៧នៅក្រុងឧដុង្គ ដោយព្រះអង្គម្ចាស់ចន្ទ ជាអនុជព្រះបាទជ័យជេដ្ឋាទី២ធ្វើគត ។ ព្រះអង្គម្ចាស់នេះបានឡើងគ្រងរាជ្យ ហើយតាំងព្រះនាមដោយព្រះអង្គឯងថាព្រះបាទសម្ដេចព្រះរាមាធិបតី ។ ក្សត្រានេះមានព្រះរាជបុត្រ៣ព្រះអង្គ គឺព្រះអង្គនី ព្រះវរឧទ័យ និងព្រះអង្គអែម ។

ពេលនោះមានវិបត្តិយ៉ាងខ្លាំងនៅក្នុងនគរ ដោយសារជម្លោះនៅក្នុងរាជវង្ស ។ឆ្លៀតឱកាសកលយុគនោះ ព្រះរាជបុទ្រទាំងបីរបស់ព្រះបាទសម្ដេចព្រះរាមាធិបតីបានរត់គៀសព្រះអង្គទៅជ្រកកោននៅជំណាក់ក្សត្រីយ៍អណ្ណាម មេម៉ាយពីព្រះបាទជ័យជេដ្ឋាទី២នៅប្រទេសយួន ហើយសុំឲ្យក្សត្រីយ៍អង្គនេះ ធ្វើ«មេអណ្ដើក»សុំអន្តរាគមន៍ស្ដេចអណ្ណាម ។ ពេលនោះ ព្រះចៅប្រទេសអណ្ណាមបានបញ្ជូនកងទ័ពមួយស្ថិតក្រោមបញ្ជាការឧត្តមសេនីយ៍អុងជៀងធូ (Ong Chieng Thu) ចូលមកក្នុងរាជាណាចក្រកម្ពុជា ។ នៅក្នុងការប្រយុទ្ធ ព្រះអង្គអែមបានទទួលមរណភាព ចំណែកឯព្រះចៅប្រទេសកម្ពុជាត្រូវយួនចាប់បាន ហើយបញ្ជូនទៅកាន់ព្រះរាជវាំងយួនអណ្ណាម ។ ព្រះចៅប្រទេសខ្មែរបានសុគតនៅទីនោះតែម្ដង ។ ស្របគ្នានឹងការចុះថយ (លង់ទ្រនេស) នៃប្រទេសកម្ពុជា នៅប្រទេសអណ្ណាមឯណោះ សន្តតិវង្សង្វៀងបា

នឡើងកាន់កាប់អំណាចរាជការពេញទំហឹង ហើយបានពង្រឹងឥទ្ធិពលយួនយ៉ាងខ្លាំងក្លាបំផុតជារៀងរាល់ថ្ងៃ ។ ក្រោយពីបានរលាស់រួចពីអាណាព្យាបាលរបស់រដ្ឋាភិបាលកែ-ចូ (Ke-Cho) ឬតុងកុង (Tong-Kong) ហើយក្រោយពីវាយយកបាននគរចំប៉ា (នគរចាម)រួច ស្ដេចត្រកូលង្វៀង បានងាកមកលេបដីព្រះរាជាណាចក្រកម្ពុជាម្ដងវិញ ។ វិបត្តិផ្ទៃក្នុងទាំងឡាយរបស់ខ្មែរ បានផ្ដល់ឬបង្កើតឱកាសនិងលេសគ្រប់បែបយ៉ាង ឲ្យពួកស្ដេចយួនត្រកូលង្វៀង អនុវត្តគំរោងលេបដីរបស់ខ្មែរ ។

ក្រោយពីច្បាំងគ្នាស្លាប់វិនាសហិនហោច ព្រោះតែជម្លោះរវាងរាជវង្សនិងរឿងបល្ល័ង្ករាជ្យមក ព្រះអង្គនន់ មហាឧបរាជប្រទេសខ្មែរ បានរត់ភៀសខ្លួនចូលទៅដីយួន រួចកេណ្ឌចិននៅនគរចំប៉ាបានចំនួន១ម៉ឺននាក់ មកច្បាំងនឹងប្រទេសខ្មែរទៀត ។ មហាឧបរាជនន់ បានលើកទ័ពចិនទាំង១ម៉ឺននាក់នេះ ឆ្ពោះទៅបាសាក់ (សុកទ្រាំង) និងខេត្តព្រះត្រពាំង (យួនហៅត្រាវិញ) រួចមកកាន់កាប់ខេត្តទាំងពីរនេះទាំងស្រុង ។ ក្នុងរឿងនេះ គួរកត់សំគាល់ថា ចម្បាំងរវាងចិន «រត់ចោលស្រុក» ដែលមានព្រះអង្គនន់ជាមេនេះ ហើយនិងប្រទេសខ្មែរគឺជាជម្លោះរាជវង្សយ៉ាងពិតប្រាកដ ។ ជម្លោះនេះនាំឲ្យយួនយកខេត្តសុកទ្រាំង និងព្រះត្រពាំងបានដោយងាយបំផុត ហើយការវាយយកខេត្តទាំងពីរនេះសោត គឺព្រះអង្គម្ចាស់ខ្មែរជាអ្នកធ្វើ ពុំមែនប្រឆាំងនឹងយួនតែត្រឡប់ជាប្រឆាំងនឹងព្រះអង្គសូរ ដែលជាស្ដេចត្រឹមត្រូវរបស់ខ្មែរទៅវិញ ។ គឺជាចំបាំងរវាងខ្មែរនិងខ្មែរ យកដីទៅឲ្យយួន ។ ព្រះអង្គសូរបានឡើងសោយរាជសម្បត្តិ១៨ឆ្នាំ ទើបបានទទួលរាជាភិសេកជាមហាក្សត្រខ្មែរពេញលក្ខណៈច្បាប់ ដោយមានគោរម្យងារថា សម្ដេចព្រះជ័យជេដ្ឋាបរមសុរដ្ឋរាជាធិរាជរាមា នៅឆ្នាំ១៥៨៩ ។ នៅក្នុងឆ្នាំដដែលនេះ មហាឧបរាជ ក្រោយពីបានទទួលទ័ពយួនជាជំនួយ២០,០០០នាក់ទៀត បានលើកព្យុហយាត្រាសំដៅមកកាន់ភ្នំពេញ ។ នៅពេលនោះ ឧបរាជនន់ បានទទួលបរាជ័យទៀត ។ ពួកយួនអណ្ណាមក៏បោះបង់លែងជួយព្រះអង្គ តាំងពីពេលនោះតែម្ដងទៅ ។ ទ័ពយួនដែលសល់ពីងាប់ មិនចូលទៅកាន់ប្រទេសអណ្ណាមវិញទេ ត្រឡប់ជាចូលទៅតាំងទីនៅកូសាំងស៊ីន ដែលជាហេតុរឹតតែធ្វើឲ្យកម្លាំងយួននៅទីនោះ រីកធំធាត់ឡើងៗថែមទៀត ។

នៅឆ្នាំ១៦៩៩ មន្ត្រីខ្មែរម្នាក់ឈ្មោះឧកញ៉ានរិន្ទអែម បានគ្រោងធ្វើរដ្ឋប្រហាររំលំរាជបល្ល័ង្ក ។ ឧកញ៉ានរិន្ទអែមបានទទួលទ័ពយួន២០,០០០នាក់ដែរ ដើម្បីអនុវត្តអំពើក្បត់នេះ លើកចេញពីកូសាំងស៊ីនឡើងចូលទៅដល់ទន្លេសាប ។ ក្រោយពីទទួលបរាជ័យដោយទ័ពព្រះបាទជ័យជេដ្ឋា ឬព្រះអង្គសូរ ពួកយួនទាំង២០,០០០នាក់នោះ បានរត់ទៅជ្រកកោន ហើយតាំងទីនៅក្នុងខេត្តកំពប់ស្រកាត្រី (បៀងហ្វា) បារៀ និងព្រៃនគរ ដែលមានយួនជាចៅហ្វាយខេត្តស្រេចទៅហើយ ។

មន្ត្រីយួនទាំងនោះ ពុំមែនត្រូវទទួលការតែងតាំងជំនួសមន្ត្រីខ្មែរសោះឡើយ ។ ការនេះអាចឲ្យនិយាយបានថា ការតែងតាំងមន្ត្រីចៅហ្វាយខេត្តទាំងនោះ ជាការតែងតាំងមិនត្រឹមត្រូវតាមច្បាប់ ឬនិយាយម៉្យាងទៀតថា ជាការបោះឆ្នោតរវាងពួកយួនដោយធ្វើមិនឲ្យខ្មែរដឹង ពីព្រោះពេលនោះយួនបានធ្វើឫកពារជាអ្នកមានកិត្តិយសខ្ពស់ និងថ្នាក់ខាងសង្គមកិច្ចល្អ គួរឲ្យគេជ្រើសរើសជាចៅហ្វាយបាន ។ ហេតុការណ៍ថ្មីៗទាំងឡាយកើតមានឡើង ពីរបីថ្ងៃក្រោយទិវា៩មិនា១៩៤៥ នៅក្នុងអាណាខេត្តទាំងឡាយនៃព្រះរាជាណាចក្រ ដែលមានជាពិសេសនៅចូដុក គឺជាភស្តុតាងនៃការលបតាំងនេះហើយ ។

នៅឆ្នាំ១៧១៦ ក្រោយពីបានច្បាំងគ្នាជាយូរមក ព្រោះរឿងរាជបល្ល័ង្ក ព្រះស្រីធម្មារាជា (ស្ដេចភៀសខ្លួន roi fugitif) បានដាក់ផែនការវាយប្រទេសកម្ពុជា ឲ្យព្រះចៅសៀមពិនិត្យនិងយល់ព្រម ប៉ុន្តែក្សត្រាសោយរាជ្យ គឺព្រះអង្គអែម (ដែលជាក្សត្រដណ្ដើមរាជសម្បត្តិ) បានកេណ្ឌ (យួនបាតផ្សារ) ដែលបានច្បាំងតទល់ព្រះអង្គទងនោះ ទៅទប់ទល់ទ័ពរបស់ព្រះស្រីធម្មារាជានិងទ័ពសៀម ។ នៅក្នុងឆ្នាំ១៧១៩ និង១៧២២ ស្ដេចសៀមបានបញ្ជូនទ័ពមកវាយប្រទេសកម្ពុជាម្ដងទៀត ដោយចូលមកវាយខេត្តពាម (ហាទៀង) ។ ស្ដេចដណ្ដើមអំណាចដោយមានចិនម្នាក់ ឈ្មោះម៉ាក់គុយ ជាមេទ័ព បានរៀបចំចំបាំងការពារខេត្តពាមជាបន្ទាន់ ពេលនោះខ្មែរបានច្បាំងឈ្នះសៀមម្ដងទៀត ។ ប៉ុន្តែនៅពេលនោះ ទ័ពសៀមដែលមានស្ដេចបះបោរ និងព្រះអង្គទងជាអ្នកដឹកនាំ បានធ្វើដំណើរតាមជើងគោក ចូលរហូតមកដល់ក្រុងឧដុង្គ រាជធានីចាស់។ ប៉ុន្តែក្នុងវិវាទរាជសម្បត្តិនោះ ក្សត្រដណ្ដើមរាជ្យបានសំរុះសំរួលត្រាតែក្សត្របះបោរនិងពួកទ័ពសៀមត្រឡប់ចូលទៅក្នុងដីសៀមវិញអស់ ។

នៅឆ្នាំ១៧២២ ព្រះសត្ថាបានឡើងគ្រប់គ្រងរាជសម្បត្តិ ក្រោយពីសម្ដេចព្រះកែវហ្វា (ក្សត្រដណ្ដើមរាជ្យ) ដាក់រាជសម្បត្តិ ។ នៅក្នុងរជ្ជកាលព្រះសត្ថា ក្នុងឆ្នាំ១៧៣០ មានលាវម្នាក់នៅភូមិប្រសូតខេត្តបាភ្នំ បានអួតអាងថាខ្លួនមានសិលអាគមពូកែក្រៃលែង ហើយសុំធានាខ្លួនទៅសម្លាប់យួន ដែលច្បាំងរុករានទន្ទ្រានគរខ្មែរ ។ លាវនោះបានកេណ្ឌទ័ពបានយ៉ាងច្រើននាំជាព្យុហយាត្រា(១) ទៅច្បាំងរហូតដល់ក្នុងអណ្ណាម ប៉ុន្តែទ័ពខ្មែរស្ថិតក្រោមបញ្ជាមេទ័ពជាតិលាវនោះ ត្រូវទ័ពរាប់រយរបស់យួនអណ្ណាមវាយរុញច្រានមកវិញ ។ នៅចប់តាមផ្លូវដកថយ ទ័ពខ្មែរបានសម្លាប់គ្មានសល់នូវជនជាតិអណ្ណាម ដែលខ្លួនស្គាល់ថាជាយួន មិនថាពួកនេះជាទ័ព ឬជារាស្ត្ររបស់ស្ដេចអណ្ណាម ឬជារាស្ត្រយួនរស់តាំងពីយូរមកហើយ ដោយអាស្រ័យ

*(១) ខេត្តស្វាយទាប ដែលសព្វថ្ងៃក្លាយជាស្រុកស្វាយទាប នៅក្នុងខេត្តស្វាយរៀង ។*

ច្បាប់ខ្មែរឡើយ ។ ស្តេចខ្មែរបានធ្វើអន្តរាគមន៍ដើម្បីរៀបចំរបៀបរៀបរយនៅក្នុងប្រទេសជាថ្មី ។ ការសម្លាប់រង្គាលដែលមេទ័ពលាវ «កាប់មិនមុតដុតមិនឆេះ» ធ្វើនោះ បានផ្តល់ជាលេសមួយឲ្យស្តេចអណ្ណាមលើកទ័ពមកវាយប្រទេសកម្ពុជា ក្នុងបទថាជួយយួនរស់នៅក្រោមច្បាប់ខ្មែរ ។ ស្តេចអណ្ណាមបានបញ្ជូនទ័ពមួយមកច្បាំងទល់នឹងប្រទេសកម្ពុជា ប៉ុន្តែត្រូវទទួលបរាជ័យរត់ខ្ចាត់ខ្ចាយត្រឡប់ទៅវិញអស់ទៅ ។ ពួកយួនអណ្ណាមបាក់ទ័ពទាំងនោះ បានឆ្លងស្ទឹងមួយទៅជ្រកកោននៅកូសាំងស៊ីនទៀត ដូចដែលទ័ពមុនៗ ដែលបានមកជួយច្បាំងស្តេចខ្មែរបះបោរនោះដែរ ។ ក្រោយមក ស្តេចអណ្ណាមបានបញ្ជូនទ័ពជំនួយមកទៀត ប៉ុន្តែទទួលបរាជ័យទៀត ។ លោកមូរ៉ា បានបន្ថែមថា កាលប្រវត្តិ (Chronique) របស់យួនអណ្ណាមបានអះអាងថា ការសម្លាប់រង្គាលនៃជនជាតិអណ្ណាមនៅលើទឹកដីខ្មែរ ជាកិច្ចតម្រូវបញ្ជាក់ការចូលកាន់កាប់របស់យួន (Justifie la prise possession) នូវខេត្តពាមមេ-ស និងខេត្តលង់ហោ (វិញឡុង) ដែលជាសខេត្តចាស់របស់រាជាណាចក្រកម្ពុជា ។

ក្រោយពីសភាស្ងប់ស្ងាត់មួយរយៈ ការប្រយុទ្ធរវាងខ្មែរនិងយួនអណ្ណាមបានផ្តើមជាថ្មីទៀត ។ នៅឆ្នាំ១៧៤៣ អ្នកឧកញ៉ានរាគុក ចៅហ្វាយខេត្តបាសាក់ បានជួបឧបសគ្គយ៉ាងច្រើន ដោយសារយួនអណ្ណាមចូលជ្រៀតជ្រែកឥតឈប់ឈរ មកលើអំណាចនិងរាជការរបស់លោក ។ ការប្រយុទ្ធគ្នារវាងខ្មែរនិងយួនក៏ចាប់ផ្តើមឡើងភ្លាម ។ យួនអណ្ណាមបានបាក់ទ័ព រួចរត់ទៅពួននៅកោះកាហុង (Île Cahong) នៅខេត្តពាមមេ-ស (យួនហៅមេ-ថ) ។

នៅឆ្នាំ១៧៤៨ អធិរាជក្រុងអណ្ណាមបានបញ្ជូនទ័ពមកច្បាំងខេត្តសុកទ្រាំង ។

ព្រះអង្គម្ចាស់ខ្មែរខ្លះ ដែលបានរត់ភៀសព្រះអង្គចូលទៅកាន់ប្រទេសអណ្ណាមបានបញ្ជាក្បួនទ័ពយួនទាំងនោះ ដោយពួកយួនអណ្ណាមវាសន្យាថានឹងលើកខ្លួនឲ្យឡើងសោយរាជ្យ ឬឲ្យកាន់មុខការធំៗណាមួយ ។ ចៅហ្វាយខេត្តបាសាក់ បានតស៊ូទប់ទល់នឹងទ័ពយួន ប៉ុន្តែត្រូវទទួលបរាជ័យ ។ គាត់បានដកថយពីខេត្តរបស់គាត់ ។ ព្រះអង្គម្ចាស់ទាំងនោះ បានចូលជាមួយទ័ពអណ្ណាម រហូតមកជិតដល់រាជធានីឧដុង្គ

លោកចៅហ្វាឯក (ឈ្មោះមន្ត្រីខ្មែរម្នាក់) បានតទល់យ៉ាងខ្លាំងក្លាចំពោះការវាយលុកនោះ ប៉ុន្តែត្រូវទទួលបរាជ័យរត់ខ្ចាត់ខ្ចាយអស់ទៅ ។ សម្តេចព្រះបូទុមរាជាធិរាជ និងព្រះអង្គម្ចាស់អ៊ីង បានឡើងជាក្សត្រ និងជាឧបរាជប្រទេសកម្ពុជាក្នុងគ្រានោះ ។ ព្រះមហាក្សត្រនិងមហាឧបរាជពេញច្បាប់បានភៀសព្រះអង្គ ដោយមានព្រះអង្គម្ចាស់ស្រីជ័យជេដ្ឋារួមផង ទៅសុំជ្រកកោននៅក្នុងប្រទេសសៀម ។

លោកក្រឡាហោមអុក (Oc) និងចៅហ្វាយខេត្តពោធិសាត់ ដែលបានជូនក្បួនស្តេចចូលទៅជ្រកកោននៅប្រទេសសៀម បានត្រឡប់ចូលមកប្រទេសខ្មែរវិញ

ហើយរៀបចំបង្កទ័ពច្បាំងតទល់នឹងពួកអណ្ណាមដែលបានតាំងទីនៅក្នុងព្រះរាជាណាចក្រ ហើយដែលកំពុងតែដណ្តើមអំណាចនិងរៃអង្គាសទារពន្ធដារពីខ្មែរ ។ ចំបាំងបានប្រព្រឹត្តទៅនៅក្នុងតំបន់សាបអង្គាមនៃទន្លេធំ ។ កងទ័ពរបស់ខ្មែរបានវាយបំបែកទ័ពអាណ្ណាមឲ្យបរាជ័យ រួចបង្ខំឲ្យទ័ពនេះរត់ខ្ចាត់ខ្ចាយអស់ ប៉ុន្តែពួកទាំងនេះមិនត្រឡប់ទៅកាន់ប្រទេសអណ្ណាម ត្រឡប់ជាទៅពួននៅកូសាំងស៊ីន (កម្ពុជាក្រោម)ដូចដែលយួនអណ្ណាមធ្វើពីមុនមកដែរ ដោយមានទាំងព្រះបុទុមរាជាធិរាជទៅជាមួយផង ។ ក្រោយពីដេញកំចាត់យួនអណ្ណាមចេញពីប្រទេសអស់ លោកក្រឡាហោមអុកបានរៀបចំរបៀបរៀបរយនិងសន្តិសុខនៅក្នុងនគរឡើងវិញ ។

សម្តេចព្រះស្រីជេដ្ឋា បានយាងពីប្រទេសសៀមមកសោយរាជ្យនៅនគរកម្ពុជាវិញ ។

ពួកសៀមបានបញ្ជូនព្រះអង្គម្ចាស់ភៀសព្រះអង្គ (Princes fugitifs) ទាំងអស់ចូលមកក្នុងប្រទេសវិញ ដែលជាហេតុបង្កើតនូវវិបត្តិស្មុគស្មាញយ៉ាងខ្លាំងនៅក្នុងនគរ ព្រោះតែជម្លោះដណ្តើមបល្ល័ង្ករាជ្យ ។ នៅឆ្នាំ១៧៥៨ គេបានធ្វើពិធីរាជាភិសេកព្រះឧទ័យឲ្យឡើងសោយរាជសម្បត្តិ ។ រដ្ឋាភិបាលក្រុងអណ្ណាមបានទទួលស្គាល់ព្រះឧទ័យ ថាជាក្សត្រពេញច្បាប់របស់ប្រទេសកម្ពុជា ជាថ្នូរនឹងការប្រគល់ឲ្យខ្លួននូវផែនដីទាំងមូលនៃអាណាខេត្តខ្មែរពីរ នៅកូសាំងស៊ីនក្រោម (កម្ពុជាក្រោម) គឺខេត្តសុកទ្រាំង និងត្រាវិញ ។ បានប៉ុណ្ណឹងហើយ យួននៅតែមិនសប្បាយចិត្តទៀត ពួកវាបានលើកគោលសីមាព្រំដែនឆ្ពោះទៅទិសខាងជើងទៀត រហូតដល់ទៅខេត្តចូដុក ។ លោកមូរ៉ាបានបន្ថែមទៀតថា «ដើម្បីរ៉ាប់រងសន្តិសុខនៃការកាន់កាប់ដោយខុសច្បាប់នូវដែនដីដ៏ទូលំទូលាយរបស់ខ្មែរដែលខ្លួនដណ្តើម ឬបង្ខំឲ្យខ្មែរប្រគល់ឲ្យ ពួកយួនអណ្ណាមបានកសាងបន្ទាយនៅសាដែក គុយឡៅយៀង (Culao Gien) និងចូដុក (សុទ្ធតែជាឈ្មោះថ្មីដែលយួនលួចកែប្រែឲ្យហៅខេត្តខ្មែរដែលខ្លួនដណ្តើម)។

នៅឆ្នាំ១៧៦៨ ចៅហ្វាយខេត្តជាតិចិនម្នាក់នៃខេត្តមេ-ស (ហាទៀង) ឈ្មោះម៉ាក់តុង ដែលតាំងខ្លួនថាជាអាណាព្យាបាលស្តេចខ្មែរ បានលើកទ័ពយ៉ាងច្រើនចេញពីខេត្តមេ-ស ចូលទៅវ៉ៃយទ័ពសៀមមៅតាមមាត់សមុទ្រសៀម ហើយចូលរហូតដល់ខេត្តចាន់តាប៊ុន ។ ប៉ុន្តែទ័ពសៀមបានវាយទ័ពម៉ាក់តុង (Macton) ឲ្យបរាជ័យ បង្ខំទ័ពនេះឲ្យដកថយពីទឹកដីទាំងអស់ដែលខ្លួនដណ្តើមបាន រួចចូលទៅកាន់ខេត្តមេ-ស (ហាទៀង) វិញ ។

ដោយជោរនឹងជ័យជំនះនេះម្យ៉ាង ហើយម្យ៉ាងទៀតដោយមានគំនុំចំពោះស្តេចខ្មែរដែលពុំព្រមទទួលស្គាល់អំណាចរបស់ខ្លួនផង ស្តេចសៀមគឺព្រះបាទពញាតាក់ បានប៉ុនប៉ង វាយយកប្រទេសកម្ពុជាដាល់ជាចំណុះរបស់សៀម ។ ស្តេចសៀម

បានលើកទ័ពតាមទឹកនិងតាមដីគោគចូលមកវាយប្រទេសកម្ពុជា ដោយមានក្សត្រខ្មែរដែលរត់ភៀសខ្លួនទៅជ្រកនៅសៀម គឺព្រះអង្គនន់ព្រះរាម ជាជំនួយផង ។ កងទ័ពរបស់បញ្ជាតាក់ ដោយមានព្រះអង្គម្ចាស់ខ្មែរឈ្មោះព្រះអង្គនន់ព្រះរាមជូនដំណើរនោះ បានបើកការវាយប្រហារទៅលើកំពង់មេ-ស (ហាទៀង) ហើយដណ្តើមផៃនេះបាន ។

ឈ្មោះម៉ាក់តុងដែលជាចៅហ្វាយខេត្តមេ-ស ត្រូវបង្ខំចិត្តរត់ទៅជ្រកពួននៅក្នុងខេត្តទឹកខ្មៅ (យួនប្រែឈ្មោះជាខេត្តកាម៉ៅ) ។ ស្តេចខ្មែរ ក្រោយពីដឹងថាទ័ពខ្មែរនៅមេ-សចាញ់សៀមហើយ បានភៀសព្រះអង្គទៅពួនបាត់ក្នុងតំបន់មួយនៃប្រទេស ។ ព្រះចៅយ៉ាឡុង អធិរាជអណ្ណាមបានសំរេចចិត្តលើកទ័ពមកជួយស្តេចខ្មែរ ដោយពួកយួនភិតភ័យចំពោះអនុភាពកំពុងតែរីកដុះដាលយ៉ាងរហ័សរបស់សៀម។ ទ័ពយួនមួយចំនួនបានត្រូវស្តេចយ៉ាងឡុងបញ្ជូនចូលមកប្រទេសកម្ពុជា ហើយទៅ (ចាប់ដៃគ្នា) ជាមួយទ័ពរបស់ស្តេចខ្មែរ ដឹកនាំដោយយមរាជមួយរូប ។ ក្រោយពីច្បាំងគ្នាមិនចាញ់មិនឈ្នះជាយូរមក ទ័ពសៀមបានសុខចិត្តចុះចាញ់ទ័ពខ្មែរ ហើយដកថយចូលទៅកាន់ប្រទេសសៀមវិញ ដោយឆ្លងកាត់តាមខេត្តមេ-ស (ហាទៀង) និងដោយបានទុកទ័ពសៀមតែចំនួន៥០០នាក់ប៉ុណ្ណោះ ដើម្បីការពារព្រះអង្គនន់ព្រះរាម ស្តេចបះបោរដែលគង់នៅខេត្តកំពត ។

មហាក្សត្រខ្មែរបានសំរេចចិត្តទៅតាំងធានីនៅតំបន់មួយឈ្មោះមាត់កណ្តុរ (Moat Kandor) នៅក្នុងឆ្នាំ១៧៧១ ។ គឺនៅក្នុងសម័យកលិយុគនោះហើយដែលអធិរាជយ៉ាឡុងបានតែងតាំងទេសាភិបាលយួនម្នាក់ឲ្យមកធ្វើជាអាណាព្យាបាលខ្មែរ ដោយមានគោរម្យងារជាយួនថា បៅហូ (Boaho) ។

រហូតមកដល់ឆ្នាំ១៧៧៤ទៅហើយ នយោបាយរបស់ស្តេចខ្មែរ ក៏នៅតែឥតទាន់ប្រែប្រួលអ្វីសោះឡើយ ក៏វិបត្តិផ្ទៃក្នុងនិងអសន្តិសុខក៏ចេះតែបន្តជារហូតមកដែរ ។ ដោយទ្រង់ឈ្វេងយល់ថា អាណាប្រជានុរាស្ត្ររបស់ព្រះអង្គវិនាសអន្តរាយយ៉ាងធ្ងន់ធ្ងរ ដោយសារតែចំបាំងរាំងជល់និងការអត់ឃ្លាន រួមទាំងជម្ងឺផ្សេងៗ ស្តេចខ្មែរបានទ្រង់សុខចិត្តបញ្ឈប់សង្គ្រាមប្រជែងគ្នារវាងសន្តតិវង្សនោះ ដោយទ្រង់សុខចិត្តផ្ទេររាជបល្ល័ង្កទៅឲ្យស្តេចបះបោរ គឺព្រះរាម ដែលជាបងប្អូនជីដូនមួយរបស់ព្រះអង្គ ។ ព្រះរាមបានឡើងសោយរាជ្យនៅឆ្នាំ១៧៧៥ ដោយមានគោរម្យងារថា ព្រះបាទសម្តេចរាមរាជាធិរាជ ។

ពេលឡើងគ្រងរាជ្យភ្លាម ស្តេចថ្មីដែលទ្រង់ភ័យបារម្ភចំពោះយួនអណ្ណាម ដែលបានជំទាស់នឹងពិធីរាជាភិសេកឡើងគ្រងរាជ្យរបស់ព្រះអង្គនោះ បានរៀបចំចំបាំងភ្លាម ហើយទ្រង់បញ្ជាឲ្យកសាងកាំភ្លើងធំ និងសង់ប៉ូរីនៅភ្នំពេញ និងនៅមុខកំពូ-

ល (បច្ចុប្បន្នស្រុកមុខកំពូលនៅក្នុងខេត្តឧដុង្គមានជ័យ) ។ នៅក្នុងសម័យដដែល នោះ ពួកតៃសឺនបានបះបោរក្រោកប្រឆាំងនឹងចៅហ្វាយខេត្តយួននៅវ៉េ ហើយមេទ័ពនៃពួកតៃសឺន បានលើកទ័ពឆ្ពោះទៅរាជធានីវ៉េ ។ ចៅហ្វាយខេត្តអណ្ណាមនៅព្រៃនគរ បានសុំជំនួយពីខ្មែរ ប៉ុន្តែស្តេចខ្មែរបដិសេធពុំព្រមផ្តល់ជំនួយតាមពាក្យសុំនៃយួនឡើយ ។

នៅប្រទេសសៀមឯណោះ នៅក្នុងខែសីហា១៨០៥ សៀមបានរៀបអភិសេកព្រះអង្គច័ន្ទ ដែលបានភៀសខ្លួនទៅជ្រកកោននៅប្រទេសសៀមពីមុន ធ្វើជាស្តេចពេញច្បាប់របស់ខ្មែរ ដោយដាក់ព្រះនាមថា ព្រះបាទសម្តេចព្រះឧទ័យរាជាធិរាជ ។ រំពេចនោះ ស្តេចអណ្ណាមក៏ទទួលស្គាល់ព្រះអង្គច័ន្ទថាជាក្សត្រប្រទេសខ្មែរពេញលក្ខណៈច្បាប់ដែរ ។ លុះដល់ឆ្នាំ១៨១៣ ព្រះអង្គច័ន្ទបានរត់ភៀសខ្លួនទៅជ្រកនៅក្រុងព្រៃនគរ ។ អធិរាជយ៉ាឡុងបានបញ្ជាឧត្តមសេនីយ៍ឡេឌូយិត (Lê Tuyet) ឲ្យនាំព្រះអង្គច័ន្ទមកឡើងសោយរាជ្យវិញ ។ មេទ័ពយួននិងស្តេចអង្គច័ន្ទបានលើកទ័ព២០,០០០នាក់ ឡើងរហូតដល់រាបាធានីឧដុង្គ ដោយឥតមានរងការទប់ទល់ ។ ក្រោយពីធ្វើសង្គ្រាមជាមួយសៀមជាច្រើនលើក ស្តេចអង្គច័ន្ទបានយល់ព្រមចងស្ពានមេត្រីជាមួយប្រទេសសៀមនៅក្នុងឆ្នាំ១៨១៤ ។

នៅឆ្នាំ១៨៣៣ ស្តេចអង្គច័ន្ទបាននាំរាជវង្សនិងបរិពារ ចាកចេញពីរាជវាំងក្រុងភ្នំពេញ ទៅតាំងនៅខេត្តលង់ហោ (វិញឡុង) ក្រោយពីមានអន្តរាគមន៍របស់ទ័ពសៀម ដែលចូលមកជួយច្បាំងព្រះបាទសម្តេចរាមរាជាធិរាជ ដែលបានភៀសព្រះអង្គកាលពីពេលទប់ទ័ពព្រះអង្គច័ន្ទមិនឈ្នះ ។ កងទ័ពដឹកនាំដោយឧបរាជអែម និងព្រះអង្គម្ចាស់ឌួង ស្ថិតក្រោមបញ្ជាការមេទ័ពសៀមឈ្មោះបូឌិន បានចូលមកដល់ភ្នំពេញ ។ ព្រះអង្គអែមនិងព្រះអង្គឌួងបានគង់នៅភ្នំពេញ ចំណែកឧត្តមសេនីយ៍បូឌិនបានចុះនាវាតាមជើងទឹក ទៅវាយដណ្តើមបានខេត្តចូដុក ។ ប៉ុន្តែពេលនោះកងទ័ពសៀមមួយចំណែកទៀតបានទទួលបរាជ័យនៅក្នុងភូមិស្មោង (Smong) ក្នុងខេត្តព្រៃវែង ដោយសារការទប់ទល់និងវាយតបដ៏សាហាវរបស់កងទ័ពចក្រីឡុង និងយមរាជហ៊ុយ (Hu) ។ ទ័ពសៀមមួយកងទៀត បានធ្វើដំណើរទៅជាមួយទ័ពរបស់ឧត្តមសេនីយ៍បូឌិន ធ្វើឲ្យទ័ពឌិនដណ្តើមយកតំបន់វៀមណៅ (Viem-Nao) បាន ប៉ុន្តែត្រូវទ័ពយួនវាយឲ្យបាក់ទ័ពនៅខេត្តលង់ហោរ (វិញឡុង) ។ បូឌិន មេទ័ពសៀមបានលើកទ័ពត្រឡប់ចូលទៅក្នុងប្រទេសសៀមវិញ ចំណែកឯឧបរាជអង្គអែម និងអង្គឌួង បានដកថយទៅតាំងនៅខេត្តបាត់ដំបង ។ កងទ័ពរបស់យួនបានលើកចូលមកដល់ភ្នំពេញ ហើយបានចែកចេញជាពីរកងឯកភាព ។ កងទ័ពក្រុមទី១ ត្រូវធ្វើដំណើរឡើងតាមទន្លេមេគង្គ កងឯកភាពមួយទៀតធ្វើដំណើរឆ្ពោះទៅកាន់ប្រទេស

លាវ ក្នុងបំណងវាយកំចាត់ទ័ពសៀមឲ្យរត់ចេញពីចំណុចទាំងឡាយនោះ ដែលសៀមនៅកាន់កាប់នៅឡើយ ។

ក្រោយពីបានវាយកំចាត់ទ័ពសៀមរបស់មេទ័ពយួន ឈ្មោះអុង ចាងឡាន់បិន (Ong Chan LanhBinh) បានដង្ហែរស្តេចខ្មែរឲ្យត្រឡប់ចូលទៅសោយរាជ្យនៅភ្នំពេញវិញ ។ ពេលដែលមានសន្តិសុខបរិបូរហើយ អុងចាងឡាន់បិន បានលើកទ័ពចូលទៅតាំងទីនៅកូសាំងស៊ីនដូចពួកយួនអាណ្ណាម ដែលបានធ្វើពីលើកមុនដែរ ។ នៅផានីភ្នំពេញ មានមេទ័ពអណ្ណាមម្នាក់ ឈ្មោះអុងថុងជេ (Ong Thong Che) នៅការពារស្តេចខ្មែរ ។

នៅឆ្នាំ១៨៣៤ ស្តេចខ្មែរបានសុគត អធិរាជយួនអណ្ណាមបានបញ្ជូននាយទាហានអណ្ណាមជាច្រើននាក់ ឲ្យយកដង្វាយមកថ្វាយព្រះបរមសពក្សត្រាខ្មែរ ។ ក្រោមកិច្ចណែនាំរបស់មេទូតយួន ឈ្មោះ អុងខាំម៉ាង (Ong Kham Mang) ក្រុមប្រឹក្សារាជបល្ល័ង្កបានជ្រើសក្សត្រីអង្គម៉ី អភិសេកសោយរាជ្យបន្តព្រះអង្គច័ន្ទ ដែលជាហេតុមួយរារាំងមិនឲ្យព្រះអង្គអែមនិងអង្គឌួងឡើងគ្រងរាជ្យបាន ។

បន្ទាប់មកទ័ពយួនឈ្មោះអុងទូងស៊ុន (Ong Tung Xun) បានព័ទ្ធចាប់ឧបរាជអែម រួចបញ្ជូនទៅកាន់រាជធានីវ៉េ ហើយបញ្ជូនរដ្ឋមន្ត្រីខ្មែរទៅកាន់រាជធានីអណ្ណាមផង ដើម្បីជជែកគ្នាពីបញ្ហានយោបាយ ។ មេទ័ពយួនឈ្មោះអុងទូងស៊ុន បានទាំងចាប់បុត្រីទាំងបួនអង្គរបស់ព្រះអង្គច័ន្ទ គឺមហាក្សត្រីអង្គម៉ី ម្ចាស់ក្សត្រីអង្គពៅ និងអង្គស្ងួនទៅក្រុងវ៉េដែរ ។ ចំណែកម្ចាស់ក្សត្រីអង្គមែន ក៏ត្រូវយួនចាប់ច្រកទ្រុងនៅខេត្តលង់ហោរដែរ ។

នៅចំពោះមុខអំពើព្យាបាទប្រឆាំងនឹងរាជវង្សានុវង្ស ប្រជារាស្ត្រខ្មែរដែលរងទុក្ខវេទនាយ៉ាងក្រៃលែង ពីអំពើសង្កត់សង្កិន ធ្វើបាប និងកាប់សម្លាប់រង្គាលពីសំណាក់មេទ័ព និងទ័ពយួនអណ្ណាម បានក្រោកឈរបះបោរពេញប្រទេសប្រឆាំងនឹងយួន ហើយកាប់សម្លាប់យួនស្លាប់ពាសវាល មិនថាយួនស៊ីវិលឬយួនទាហានឡើយ ។ ពេលនោះ រាស្ត្រខ្មែរបានផ្ញើចុតហ្មាយទៅស្តេចសៀម សុំឲ្យបញ្ជូនព្រះអង្គឌួងចូលមកប្រទេសកម្ពុជា ។ ព្រះអង្គឌួងដោយមានមេទ័ពបូឌិនដង្ហែរអមផង បានលើកទ័ពចូលមកប្រទេសកម្ពុជា ហើយបានទទួលជោគជ័យនៅខេត្តពោធិសាត់ ។ ប្រជាពលរដ្ឋបានទទួលអបអរ នឹងកងទ័ពរបស់បូឌិន ដែលដង្ហែរព្រះអង្គឌួងដោយរីករាយបំផុត ហើយរាស្ត្រទាំងនោះថែមទាំងបានបង្កទ័ពជួយច្បាំងស្តេចរបស់ខ្លួនថែមទៀតផង ។

ព្រះចៅអធិរាជអណ្ណាមបានប្តូរនយោបាយមួយរំពេច ចំពោះក្សត្រីនិងរាជវង្សខ្មែរ ដែលយួនចាប់យកទៅឃុំឃាំងនៅក្រុងវ៉េ ក្រោយពីបានទទួលដំណឹងថា ទ័ព

ខ្មែរ-សៀមបានទទួលជោគជ័យ ។ យួនអណ្ណាមបានឲ្យបញ្ឈប់អំពើប្រមាថមើលងាយ និងទារុណកម្មសាហាវយង់ឃ្នងលើក្សត្រទាំងនោះ ពួកយួនបានទាំងសន្យាថានឹងជួយច្បាំងដណ្ដើមរាជ្យ ឲ្យឧបរាជដែលខ្លួនចាប់យកទៅនោះថែមទៀតផង ។ ស្ដេចយួនបានបញ្ជូនកងទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់ចូលមកកាន់ប្រទេសកម្ពុជា ដោយមានមេទ័ពអ៊ុងចាងឡាន់ប៊ិន ជាមេបញ្ជាការធំ ។ ទោះបីមានការធ្វើបាបយ៉ាងណាក្ដី និងទោះបីយួនល្បងលួងបញ្ឆោតដោយសំដីផ្អែមល្ហែមក្ដី ក៏ពួកខ្មែរមិនព្រមចុះចាញ់ និងចុះចូលយួនឡើយ ។ មេទ័ពអ៊ុងចាងឡាន់ប៊ិន ឥតហ៊ានចូលមកក្នុងប្រទេសកម្ពុជាឡើយ ចាបានដកទ័ពថយទៅវិញ ដោយនាំទាំងឧបរាជនិងម្ចាស់ក្សត្រីទាំងបួនអង្គរបស់ព្រះអង្គច័ន្ទ ដែលវាចាប់ពីមុនទៅវិញផង ។ នៅឆ្នាំ១៨៤២ ចៅ-ហ្វាយខេត្តយួននៅលង់ហោរ (វិញឡុង) បានធ្វើគតម្ចាស់ក្សត្រីម៉ែន ដោយសារវាក្ដៅក្រហាយនឹងបរាជ័យរបស់វា ។

ក្រោយពីទទួលជោគជ័យនៅពោធិសាត់ ទ័ពរបស់ឧត្ដមសេនិយបូឌិន បានលើកឆ្ពោះមកក្រុងឧដុង្គទៀត ។ ដោយទ្រង់បារម្ភចំពោះការវាយប្រហារនៃពួកយួនអណ្ណាមនោះ ព្រះអង្គឌួងបានលើរេហ៍ពលឆ្ពោះទៅខាងត្បូងនៃប្រទេស ហើយទៅតាំងទ័ពនៅទ្រាំង ។ នៅទីនោះព្រះអង្គឌួងបានទទួលទ័ពជើងគោករបស់សៀមមកជាជំនួសទៀត ទ័ពទាំងនោះចុះនៅខេត្តពាម ឬមួងខាំ (ហាទៀង) ។ ចំបាំងបានផ្ទុះឡើងយ៉ាងខ្លាំងក្លា ប៉ុន្តែមិនចាញ់មិនឈ្នះគ្នាឡើយ ។ ពេលនោះសៀមបានដកទ័ពរបស់ខ្លួនវិញ ដោយនៅប្រទេសសៀមក្នុងពេលនោះក៏មានចំបាំងយ៉ាងសាហាវដែរ ។ ឧបរាជអង្គអែមដែលគង់នៅកូសាំងស៊ីន ហើយដែលឥតបានចូលប្រឡូកក្នុងសង្គ្រាមនោះ បានសុគតនៅឆ្នាំ១៨៤៥ ប៉ុន្តែទ្រង់បានបង្សល់បុត្រមួយអង្គព្រះនាមភិម អាយុ២០ឆ្នាំ នៅក្នុងកណ្ដាប់ដៃយួនអណ្ណាម ដែលជាផ្ដាក់មួយសំរាប់ឲ្យយួនប្រើក្នុងសង្គ្រាមជាមួយព្រះអង្គឌួង ។ សង្គ្រាមក្រោយបំផុតបានប្រព្រឹត្តទៅនៅក្រុងលង្វែក ពេលនោះខ្មែរបានសម្លាប់មេទ័ពយួនអណ្ណាមឈ្មោះអ៊ុងចាងឡាន់ប៊ិនបានដូចបំណង ។ ទ័ពយួនអណ្ណាមខូចទឹកចិត្ត ក៏សំរេចដកថយវិញ ។ ទ័ពខ្មែរបានប្រើទ័ពដំរីឲ្យដេញតាមទ័ពយួនដែលដកថយនោះ ហើយអាចចាប់បានមេទ័ពយួនអណ្ណាមម្នាក់ ព្រមទាំងពលទាហានជាច្រើននាក់ថែមទៀតផង ។ ក្រោយពីបានទទួលបរាជ័យជាច្រើនដងមក យួនអណ្ណាមសុខចិត្តចុះហត្ថលេខាសន្តិភាពជាមួយខ្មែរ យួនអណ្ណាមត្រូវបង្ខំឲ្យដកទ័ពថយពីដីខ្មែរ នៅខែមិថុនា១៨៤៦ ក៏រីឯទ័ពឧត្ដមសេនីយ៍បូឌិន ក៏បានត្រឡប់ចូលទៅស្រុកវិញនៅឆ្នាំ១៨៤៨ដែរ បណ្ដាលឲ្យព្រះអង្គឌួងនៅតែមួយព្រះអង្គឯង កណ្ដាលវិបត្តិរាប់រយរាប់ពាន់ជំពូក ។

នៅពេលគ្រងរាជ្យ វាលេចឲ្យឃើញហាក់ដូចជាព្រះអង្គឌួងជាស្ដេចចំណុះយួន

អណ្ណាមផងនិងសៀមផង ពីព្រោះក្នុងពិធីរាជាភិសេកនោះ តំណាងស្តេចក្រុងវ៉េ និងតំណាងស្តេចសៀមជាអ្នក (ប្រគល់) មកុដរាជ្យឲ្យព្រះអង្គ ។ ពេលនោះគេឥតបានរវល់ដោះស្រាយបញ្ហានៃការទាមទារខ្មែរ ឬកំណត់ព្រំដែនរបស់កម្ពុជាដែលយួនអណ្ណាមនិងសៀមលួច ព្រមទាំងកកេរឲ្យរញ្ជួញក្រញូងប៉ុនបាតដៃនោះទេ ទោះបីនៅខាងចុងសតវត្សទី២០នេះហើយក្តី ក៏រឹងដីសល់ប៉ុនស្បែកក្របីសព្វថ្ងៃនេះ ដែលពុំអាចទាំងចិញ្ចឹមរាស្ត្របានផងនោះ ក៏មានលំនាំដូចដីកម្មសិទ្ធិ (ដូចជាដីស្រែចំការជួលពីរដ្ឋ...) ប៉ុណ្ណោះ ។ ព្រះអង្គឌួងឥតហ៊ានបើកចំណុចធំនេះសោះទេ ដោយទ្រង់ភ័យថា បើលើកបញ្ហាដ៏ធំនិងដ៏គ្រោះថ្នាក់នេះមកនិយាយ នោះនឹងនាំឲ្យមានវិបត្តិរវាងពួកគ្នាតក្រុងវ៉េនិងក្រុងបាងកក ។ ពួកមហាចោរទាំងពីរនេះបានបង្ខំឲ្យខ្មែរនិងអ្នកដទៃទុករឿងឲ្យនៅដូចដើម (Statu quo) ជាពិសេសកុំឲ្យខ្មែរ ឬប្រទេសណាតវ៉ាទាមទារឲ្យពួកវាបង្ហាញកិត្យានុកូលភាព Légitimité នៃការលួចប្លន់ដីគេរបស់ពួកវាឲ្យសោះ ។ ក្នុងពេលដដែលនោះ ព្រះអង្គឌួងថែមទាំងឥតហ៊ានធ្វើឲ្យពួនូវការទាមទារដីអ្វីបន្តិចបន្តួចសោះទេ ។ ព្រះអង្គគ្មានទាំងឱកាស គ្មានទាំងមធ្យោបាយអ្វីសោះឡើយ ទោះបីពេលជាខាងក្រោយមកហើយក្តី ហើយព្រះរាជាណាចក្ររបស់ព្រះអង្គ ក៏មានទំហំនិងទិដ្ឋភាពដូចដែលកម្ពុជាដែលយើងរស់នៅសព្វថ្ងៃនេះទៅ ។

ពួកយួនអណ្ណាមនិងសៀម បានតាំងនៅជាស្ថាពរលើខេត្តជាយដែនទាំងឡាយរបស់ខ្មែរ ដែលខ្លួនកាន់កាប់ក្នុងឱកាសអន្តរាគមន៍ទ័ពទាំងឡាយរបស់ខ្លួន មកក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ។ ពួកមហាចោរទាំងពីរនេះបានពង្រឹងកម្លាំងយ៉ាងមាំមួនហើយត្រួតត្រាខេត្តទាំងនោះដោយផ្ទាល់តែម្តង ។ ការវាតដីរបៀបនេះបានប្រព្រឹត្តទៅដោយស្ងាត់ស្ងៀមបំផុត ហើយឥតមានអនាធិបតេយ្យផង ។ ប្រជារាស្ត្រខ្មែរដែលលង់ទ្រនេស ដោយសារតែសង្គ្រាមបន្តបន្ទាប់គ្នាឥតឈប់ឈរ «បដិវត្តន៍» ដើម្បីមកុដរាជ្យ ដែលនាំឲ្យវិនាសប្រទេសនោះ ឥតរវល់អើពើចំពោះហេតុការណ៍អពមង្គលសោះឡើយ ។ ប៉ុន្តែនៅប៉ែកខាងក្រោមនៃប្រទេស គឺនៅក្នុងដីដែលយួនអណ្ណាមដណ្តើមកាន់កាប់ ខ្មែរយ៉ាងច្រើនបានរត់គៀសខ្លួនពីដីនោះ ទៅជ្រកកោននៅដីដទៃទៀត ដែលឋិតនៅក្រោមការត្រួតត្រារបស់ខ្មែរ ។ ការនេះពុំមែនបណ្តាលមកតែពីខ្មែរទាំងនោះ រងទុក្ខវេទនាពីអាជ្ញាធរឬពួកយួនអណ្ណាម ដែលមានប្រយោជន៍តែក្នុងការ (បង្កាត់ពូជខ្មែរ)នោះទេ ប៉ុន្តែមកពីខ្មែរ មានការឆ្មើងឆ្មៃដ៏ខ្ពង់ខ្ពស់មួយ មិនព្រមតាំងខ្លួននៅក្រោមការត្រួតត្រារបស់យួន ដែលគេធ្លាប់តែមើលងាយ និងដែលគេបានចាត់ទុកជាមហាចោររបស់គេ ។ ឆ្លៀតប្រហោងនេះ រដ្ឋាភិបាលក្រុងវ៉េបានរុញច្រានរាស្ត្ររបស់ខ្លួន ឲ្យដឹកកូនជញ្ជូនចៅទៅតាំងលំនៅៗលើដីនោះជាជំនួសខ្មែរវិញ ។ អាជ្ញាធរយួនបានផ្តល់កិច្ចសំរួលនិងបុព្វសិទ្ធិយ៉ាងទូលំទូលាយដល់ជន

បរទេស ដែលនៅកកូនពូនថៅនៅលើដីរបស់ខ្មែរដែលខ្លួនប្លន់នោះ ជាពិសេសចំ-ពោះជនជាតិចិន គ្រាន់តែមួយពព្រិចភ្នែកប៉ុណ្ណោះ ដែនដីសណ្តរដ៏ល្វឹងល្វើយនៃទន្លេមេគង្គ ត្រូវមហាចោរយួនកែឲ្យទៅជាស្រែគ្មានសល់ ។

ប៉ុន្តែក្រោយមកព្រះអង្គឌួង បន្ទាប់មកព្រះបាទនរោត្តម បានដណ្តើមយកដីដែលយួនកាន់កាប់នោះមកវិញ ដោយប្រើទាំងមធ្យោបាយយោធានិងនយោបាយផង

ជំហានទីមួយ ក្នុងន័យនេះត្រូវបានផ្តើមធ្វើឡើងនៅឆ្នាំ១៨៥៤ ដោយរាជវង្សាភិបាលបានបញ្ជូនបេសកជនខ្មែរមួយរូប ឲ្យទៅទាក់ទងកុងស៊ុលបារាំងនៅសឹង្ហបុរី ។ លោក ដឺម៉ុងទីញី (M. de Montigny) ដែលបានមកដល់កំពតនៅឆ្នាំ១៨៥៥ ដោយកាត់តាមក្រុងបាងកកនោះ បានបង្ហើបប្រាប់ស្តេចសៀមថា ខ្លួនមានបំណងចូលគាល់ស្តេចខ្មែរដែរ ។ សៀមបានប្រើកលល្បិចជាច្រើនប្រការ រារាំងរហូតទាល់តែពុំអាចឲ្យមានកិច្ចព្រមព្រៀងណាមួយ ជាមួយអ្នកតំណាងបារាំងនិងព្រះអង្គឌួងចុះហត្ថលេខាបាន ក្រោយពីវាបានដឹងបំណងរបស់ខ្មែរ ។

នៅឆ្នាំ១៨៥៦ ពួកខ្មែររស់នៅក្នុងខេត្តទាំងឡាយស្ថិតនៅតាមទន្លេក្រោម បានក្រោកបះបោរប្រឆាំងនឹងរដ្ឋការអណ្ណាម ។ ព្រះអង្គឌួងបានត្រាស់បញ្ជាឲ្យរៀបចំរេពល ហើយលើកទៅកាន់ជាយដែន ដើម្បីគាំទ្រចលនាបះបោរនោះ ។ ប៉ុន្តែមេទ័ពយួនបានធ្វើឲ្យគំរោងការណ៍នេះបរាជ័យទៅវិញ ដោយវាបានរៀបចំទ័ពនៅតាមជាយដែនជាស្រេច ដើម្បីទប់ទល់នឹងការវាយលុករបស់ខ្មែរ ។ ដោយគ្មានជំនួយអ្វីសព្វយ៉ាងបែបនេះ និងដោយស្ថិតនៅក្នុងសំណាញ់យួនបែបនេះផង ពួកខ្មែរបះបោរទាំងនេះបានខូចទឹកចិត្តអស់ ហើយត្រូវយួនសម្លាប់ចោលយ៉ាងរង្គាលព្រៃផ្សៃទៀតផង ។

នៅឆ្នាំ១៨៥៨ ពួកចាមខាងត្បូងឃ្មុំ បានបះបោរប្រឆាំងនឹងអាជ្ញាធរខ្មែរ ហើយបានសម្លាប់បេសកជនរាជបំរើរបស់ខ្មែរម្នាក់ ដែលទទួលភារៈទៅបង្ក្រាបពួកវា ។ អំពើបះបោរនោះ ត្រូវបានបង្ក្រាបទៅវិញ តែចាមមេបះបោររត់ចូលទៅជ្រកកោននៅក្នុងខេត្ត «ចូដុក» ។

នៅឆ្នាំ១៨៥៩ ព្រះអង្គឌួងបានគំរាមអាជ្ញាធរយួនអណ្ណាម ឲ្យប្រគល់ចាមនោះមកឲ្យខ្មែរវិញ ។ ពួកយួនបដិសេធជាដាច់អហង្កា ព្រះអង្គឌួងបានទ្រង់ត្រាស់បង្គាប់ឲ្យវាយលុកខេត្ត «ចូដុក» ដើម្បីយកពួកបះបោរទាំងនោះមកវិញ ។ ឧកញ៉ាកែប «Kep» ដែលជាប្រមុខទ័ពខ្មែរ និងជាចៅហ្វាយខេត្តទ្រាំងនោះ បានទទួលជោគជ័យ ហើយវាយរុញច្រានទ័ពយួន-ចាម រហូតទៅដល់ដីរបស់វា ។ ឧកញ៉ាកែបដែលកំពុងតែដេញតាមទ័ពយួននោះ បានចូលមកកាន់រាជធានីឧដុង្គវិញ ក្រោយពីបានទទួលដំណឹងថា ព្រះអង្គឌួងទ្រង់សុគត ។ កិច្ចការទាំងឡាយក៏នៅត្រឹមនោះឯងទៅ

នៅខែវិច្ឆិកា១៨៥៩ ព្រះអង្គម្ចាស់អង្គវត្តី មហាឧបរាជបានទទួលរាជាភិសេកជាស្តេចនគរខ្មែរ ។ បន្ទាប់ពីនៅការប្រយុទ្ធជាបន្តកន្ទុយគ្នា ទោះបីមានចន្លោះមិនទៀងក្តី ដើម្បីដណ្តើមដីទាំងនោះវិញបានធ្វើឥតឈប់ឈរ រហូតដល់បារាំងចូលកាន់កាប់ដីនោះវិញ ទើបការនេះត្រូវគេបង្ខំឲ្យ «ព្យួរ» ចោល ។ តាមហេតុការណ៍នេះ វិវាទខ្មែរ-យួន ត្រូវព្យួរចោលមកទល់សព្វថ្ងៃ ។

# ភាគទី២

## ការល្បងដណ្ដើមយកវិញ

~១~

### ការល្បងដណ្ដើមយកវិញ រៀបចំឡើងដោយក្សត្រខ្មែរ

នៅឆ្នាំ១៧៣៨ គឺក្នុងរយៈពេល២ឆ្នាំក្រោយពីឈ្មោះ ម៉ាក់គុយ ស្លាប់ទៅ ព្រះបាទធម្មោរាជាអង្គស្ងួ(១៧៣៨-១៧៤៧) ទ្រង់ឆ្លៀតឱកាសខ្មែរនិងយួនទាស់គ្នា បញ្ជូនទ័ពខ្មែរមួយចំនួនទៅច្បាំងដេញមេទ័ពសត្រូវឈ្មោះ ម៉ាក់តុង ចេញពីខេត្តពាម (ហាទៀង)។ ប៉ុន្តែទ័ពរបស់ព្រះធម្មោរាជាអង្គស្ងួទទួលបរាជ័យ ហើយត្រូវបង្ខំចិត្តដកថយមកវិញ ដោយហេតុក្រុងពាម ត្រូវទ័ពយួននិងចិនការពារមុតមាំខ្លាំងពេក (អញ្ជើញអានសៀវភៅ អាដេម៉ារ ឡឺក្លែរ A. Leclère ទំព័រ៣៧៨) ។ នៅឆ្នាំ១៧៣៨ដដែល ឧកញ៉ានិរិន្ទគុក ជាចៅហ្វាយស្រុកៗបាសាក់ក៏បានលើកទ័ពច្បាំងដេញយួនអណ្ណាមចេញពីតំបន់នេះដែរ ។

ដល់មកឆ្នាំ១៧៧៦ គឺក្នុងឱកាសដែលពួកតៃសឺនបះបោរប្រឆាំងនឹងស្ដេចក្រុងវេ ខ្មែរនៅកម្ពុជាក្រោម (ឬកូសាំងស៊ីន) បានក្រោកឡើងវាយកំចាត់យួនដែរ ។ ក្នុងពេលនោះ ព្រះបាទរាមរាជា (ព្រះអង្គនន់) បានបដិសេធមិនព្រមលើកទ័ពទៅជួយស្ដេចង្វៀងអាន (យ៉ាឡុង) តាមសេចក្ដីសុំនៃស្ដេចនេះសោះឡើយ ។ ស្ដេចយួនបានលើកទ័ពមកវាយខ្មែរភ្លាម តែត្រូវទ័ពខ្មែរវាយបាក់ទ័ព ហើយដេញតាមប្រកិត ។ ក្នុងឱកាសនោះ ព្រះអង្គនន់និងទ័ពខ្មែរបានដណ្ដើមបានមកវិញនូវខេត្តលង់ហោរ (វិញឡុង) និងពាមមេ-ស (មីថរ) ។ ព្រះអង្គនន់ទ្រង់លើកទឹកចិត្តដល់ការបះបោររបស់ខ្មែរ ហើយទ្រង់បានរៀបចំឲ្យគេសម្លាប់ដឹរង្គាលនូវជនជាតិអណ្ណាមទាំងអស់ដែលរស់នៅលើរដ្ឋទាំងឡាយរបស់ព្រះអង្គថែមទៀតផង ។ ប៉ុន្តែឧបរាជ ព្រះឧទ័យសុរិយា និងឧបរាជធម្ម (អង្គតន់) បានរារាំងនិងធ្វើឲ្យខូចខាតផែនការនេះអស់ (អា. ឡឺក្លែរ ទំព័រ៣៩០) ។

នៅក្នុងឆ្នាំ១៨៥៧ ព្រះបាទអង្គឌួង ព្រះចៅប្រទេសកម្ពុជាបានសុំតាមរយៈម៉ុងសេញ៉ូរមីស (Monseigneur Miche) ឲ្យព្រះចៅអធិរាជបារាំងណាប៉ូឡេអុងទី៣ បញ្ជូនទ័ពបារាំងមកវាយដណ្ដើមយកព្រៃនគរឲ្យខ្មែរ ។ ព្រះបាទអង្គឌួងបានសន្យាថានឹងប្រទានប្រាក់៥០០ណែនជាសគុណ បើកាលណាបារាំងវាយឈ្នះយកទីក្រុង

នេះបានមកឲ្យខ្មែរវិញ ។

ប្លង់វាយប្រហារនេះ បានរៀបចំឲ្យកងទ័ពខ្មែរវាយប្រហារខេត្តទ្រាំងត្រើយខាងត្បូងទន្លេបាសាក់ (សុកទ្រាំង), ព្រះត្រពាំង (ត្រាវិញ), ក្រមួន-ស (រ៉ាច់យ៉ា), មាត់ជ្រូក (ចូដុក) (សូមអានព្រះរាជពង្សាវតាដំកល់នៅព្រះរាជវាំង ទំព័រ៧៥៥ (Annales déposées au Palais Roral page 755) ។

លុះមកដល់ឆ្នាំ១៨៥៨ កងទ័ពបារាំងក្រោមបញ្ជាការរបស់ឧត្តមសេនីយ៍ ឌូដាត៏ ដឺឡាហ្គ្រេ (Doudart de Lagrée) បានវាយប្រហារក្រុងព្រៃនគរ ស្របពេលគ្នានឹងការវាយប្រហាររបស់ទ័ពខ្មែរទៅលើខេត្តទ្រាំងត្រើយខាងត្បូងទន្លេបាសាក់ ព្រះត្រពាំង ក្រមួនស និងមាត់ជ្រូក (ព្រះរាជពង្សាវតាដំកល់នៅព្រះរាជវាំង ទំព័រ៧៦០ ( Annales déposées au Palais Royal page 760 et A. Leclère p.447 ) ។

ប៉ុន្តែជាអកុសល ពួកចាមដែលបះបោរនៅត្បូងឃ្មុំ ក្នុងខេត្តកំពង់ចាម បានរត់ចូលទៅក្នុងខេត្តនៅកម្ពុជាក្រោម ដោយសារជនរួមឈាមរបស់វាមកពីមាត់ជ្រូក (ចូដុក) ជួយរំដោះ ។ មហាក្សត្ររបស់យើង ពីព្រះបាទសម្តេចហរិរក្សរាមាព្រះអង្គឌួង បានព្រមានឲ្យចៅហ្វាយខេត្តយួននៅមាត់ជ្រូក ប្រគល់ចាមបះបោរទាំងនោះមកខ្មែរវិញ ។ យួនបដិសេធ ព្រះអង្គឌួងបានបញ្ជាលោកឧកញ៉ាកែប ចៅហ្វាយខេត្តទ្រាំងលើកទ័ពទៅវាយប្រហារខេត្តមាត់ជ្រូក (ចូដុក) ជាបន្ទាន់ ។ ពួកយួនអណ្តាមនិងសម្ព័ន្ធមិត្តរបស់វា គឺពួកចាមបះបោររត់ទៅជ្រកនៅទីនោះ រៀបចំការវាយតបទប់ទ័ពខ្មែរ ប៉ុន្តែត្រូវបរាជ័យហើយដកថយ ជាឱកាសហុចឲ្យទ័ពខ្មែរលើកព្យុហយាត្រាចូ-លជ្រៅទៅៗក្នុងប្រទេសយួន ។ គឺក្នុងពេលនោះហើយ ដែលយួនអណ្តាមនិងចាមលង់ទ្រនេសបរាជ័យហិនហោចដល់បន្ទុក ។ តែក្រោយពីបារាំងដណ្តើមបានទូរ៉ាន (Tourane) នៅថ្ងៃទី១កញ្ញា១៨៥៨ នឹងក្រុងព្រៃនគរនៅថ្ងៃទី១៧កុម្ភៈ១៨៥៩មកព្រះបាទអង្គឌួងឈ្វេងយល់ថា គួរតែផ្អាកការវាយដណ្តើមដីកម្ពុជាក្រោមសិន (កូសាំងស៊ីន) ។ ព្រះអង្គឌួងទ្រង់ចូលសុវណ្ណកោដ្ឋនៅគ.ស.១៨៦០ (អា. ឡឺក្លែរ ទំព័រ៤៩៦) ។

## ~២~

## ការល្បងដណ្តើមវិញ
## រៀបចំឡើងដោយប្រជារាស្ត្រកូសាំងស៊ីន

នៅក្នុងរជ្ជកាលរបស់ស្តេចធម្មោរាជាអង្គសូ (ឆ្នាំ១៧៣៨ដល់ឆ្នាំ១៧៤៧) មាន

ការវាយប្រហារមួយរវាងទ័ពខ្មែរ ដឹកនាំដោយឧកញ៉ានិរិន្ទគុកនិងពួកយួនអណ្ណាម នៅខេត្តបាសាក់ (សុកទ្រាំង) ។ ពួកយួនត្រូវទទួលបរាជ័យ ដកថយទៅទៅកាន់កោះហុង នៅខេត្តពាមមេ-ស ដែលជាកោះមួយក្នុងទន្លេមេគង្គ ហើយបានធ្វើជាម្ចាស់ដីកោះនោះរហូតមក (អា. ឡឺក្លែរ ទំព័រ៣៧៥) ។

នៅក្នុងរជ្ជកាលព្រះអង្គចន្ទ (១៨០៦-១៨៣៨) នៅពេលដែលព្រះអង្គម្ចាស់អណ្ណាមង្វៀងអានបះបោរឡើងហើយប្រកាសខ្លួនជាក្សត្រប្រទេសអណ្ណាមនៅក្រុងព្រៃនគរ រួចច្បាំងជាមួយពួកតៃសឺននោះ មន្ត្រីជាន់ខ្ពស់ម្នាក់របស់ខ្មែរ ឈ្មោះឧកញ៉ាសួស បានកេណ្ឌជនរួមឈាមខ្លួននៅខេត្តព្រះត្រពាំង (ត្រាវិញ)ច្បាំងតទល់នឹងពួកយួន ។

ក្នុងរជ្ជកាលមហាក្សត្រីយានីអង្គម៉ី (១៨៣៨-១៨៤១) ដោយទ្រាំទ្រចំពោះអំពើសង្កត់សង្កិន ធ្វើបាប នៃមេទ័ពយួនឈ្មោះទ្រឿង-មិញយ៉ាង ព្រមទាំងមន្ត្រីរាជការខេត្តនានារបស់វាពុំបាន និងក្រោយពីដឹងថា យួនប៉ុនប៉ងបង្កាត់ទាំងខ្មែរលើ ទាំងខ្មែរក្រោមឲ្យទៅជាយួន ដោយពួកមហាចោរនេះបានលុបចំបាត់ដោយថោកទាបបំផុតនូវទំនៀមទម្លាប់ប្រពៃណីខ្មែរ ចៅហ្វាយស្រុកព្រះត្រពាំងម្នាក់ ឈ្មោះចៅហ្វាយគុយ បានដឹកនាំជនរួមជាតិរបស់ខ្លួនឲ្យក្រោកបះបោរតវ៉ាឡើង ។ លោកចៅហ្វាយស្រុកគុយ បានធ្វើ«ទុក្ខកិរិយា»សម្លាប់ខ្លួនដោយសោកនាដ្យកម្ម ដើម្បីដឹកនាំចលនាតស៊ូយ៉ាងប្ដូរផ្ដាច់ ក្នុងបំណងឲ្យយួនទុកឲ្យខ្មែរវិញ នូវប្រពៃណីខ្មែរនិងសាសនារបស់ខ្មែរ ។ ការតស៊ូនិងការទាមទារនេះ បានក្លាយមកជាប្រពៃណីនិងជាកាតព្វកិច្ចខ្មែរកម្ពុជាក្រោម (កូសាំងស៊ីន) រហូតមកដល់សព្វថ្ងៃ ។

នៅឆ្នាំ១៨៤៧ គឺក្នុងពេលព្រះអង្គឌួងទើបនឹងឡើងគ្រប់គ្រងរាជសម្បត្តិ (១៨៤៧-១៨៥៩) មេទ័ពខ្មែរម្នាក់ឈ្មោះ ឡោមសោម ដែលគេហៅរត់មាត់ថា តាសោម (Lom Som) បានក្រោកឡើងដឹកនាំការបះបោរនៅក្នុងស្រុកទាបភ្លើង (តំបន់កន់ចុង) ខេត្តព្រះត្រពាំង (ត្រាវិញ) ដើម្បីសងសឹកយួនចំពោះមរណភាពរបស់ចៅហ្វាយគុយ ជាពិសេសដើម្បីធ្វើការតស៊ូដេញកំចាត់យួនអណ្ណាមចេញពីដីខ្មែរ ក្នុងបំណងដណ្ដើមយកដីមរតកដូនតាមកវិញ ។ ដោយមានជំនួយពីមេទ័ពរងរបស់ខ្លួនឈ្មោះសេនាឯកប្រោញ និងលោកមឿងសោម ព្រមទាំងអាជ្ញាធរខ្មែរនៅក្នុងខេត្តនោះគាំទ្រផង លោកឡោមសោមបានវាយឈ្នះយួន ហើយលើកទ័ពចូលរហូតដល់តំបន់ផ្នូដោង (Phno Dong) ក្នុងខេត្តព្រះត្រពាំងដដែល ហើយបានបញ្ជាឲ្យសម្លាប់រង្គាលនូវយួនអណ្ណាមទាំងឡាយនិងអុងបូរ ចៅហ្វាយខេត្តរបស់វាផង ។ ប៉ុន្តែបន្ទាប់មក ទ័ពលោកឡោមសោមត្រូវបរាជ័យ ដោយយួនបានបញ្ជូនទ័ពជំនួយយ៉ាងច្រើនទៀត មកពីខេត្តខាងកើត ដើម្បីទប់ដំណើរនិងវាយប្រហារទ័ពខ្មែរ ។ យួន

បានចាប់មេទ័ពឡោមសោម ដាក់ទ្រុងបញ្ជូនទៅក្រុងវេ៉ ហើយត្រូវស្តេចយួនឈ្មោះធីវទ្រី (Thiev-Tri) បញ្ជាឲ្យសម្លាប់ចោល (អញ្ជើញអានសៀវភៅកូសាំងស៊ីន, ១៩-៣០ ទំព័រ២២ និងរឿងនិទានលើថ្ម) ។

នៅឆ្នាំ១៨៥៦ ពួកយួនអណ្ណាមបានស្ថាបនាបន្ទាយយ៉ាងធំនៅបាយសូវ (Bai Xou) សុកទ្រាំង (ទីរួមខេត្ត) និងនៅញូយ៉ា (Nhu Gia) ក្នុងបំណងធ្វើការវាតដីចុះចុះមកខាងលិចផង និងពង្រឹងស្ថានភាពរបស់យួនផង ។ ពួកយួនបានព្រមានលោកចៅហ្វាយស្រុកសុកឲ្យចុះចូលវា ប៉ុន្តែផ្ទុយទៅវិញ ចៅហ្វាយស្រុកសុកនិងខ្មែរបានក្រោកឡើងដោយមានលោកសេនាលឹមនៅបាសាក់ជាអ្នកដឹកនាំប្រឆាំងហើយសម្លាប់រង្គាលនូវយួនអណ្ណាមគ្រប់ប្រភេទ នៅក្នុងតំបន់ទំនប់និងកំពង់ត្រប់ ដែលសព្វថ្ងៃយួនហៅថា «ទួនវ៉ា» (Thuan Hoa) នៅក្នុងខេត្តសុកទ្រាំង ។

នៅឆ្នាំ១៨៥៩ យួនអណ្ណាមបានរៀបចំជាថ្មីទៀត ព្រមទាំងអន្ទងចាមនៅខេត្តមាត់ជ្រូក (ចូដុក) ឲ្យចូលជួយច្បាំងវាផង ។ ខ្មែរបានផ្តើមប្រតិបត្តិការសឹកជាថ្មីឡើងទៀត ។ លោកសេនាសួសព្រមទាំងរេហ៍ពលរបស់លោក បានរៀបចំទ័ពខ្មែរលើកទៅបង្ក្រាបយួនអណ្ណាមនៅមហាទុប (យួនហៅថាវ៉ាទួន Hoathuan) និងចុងបាឡាង (អាននិញ) ក្នុងខេត្តសុកទ្រាំង ។ នៅក្នុងកំឡុងពេល៣ឆ្នាំ ទ័ពខ្មែរបានប្រយុទ្ធគ្នាឥតឈប់ ប្រកបដោយជោគជ័យ សម្លាប់យួនអស់ជាច្រើន នៅក្នុងចំណោមនោះមានឧត្តមមេបញ្ជាការយួនពីរនាក់ផង ឈ្មោះអុងឡាន់សម (Ong Lanh Sam) និងអុងឡាន់ប៊ិនស៊ី (Ong Lanh Binh Si) ដែលមានផ្នូរនៅសុកទ្រាំសព្វថ្ងៃជាអនុស្សាវរីយ៍ស្រាប់ ។ តែលោកសេនាសួស ត្រូវពួកចាមដែលជាសម្ព័ន្ធមិត្តយួនអណ្ណាមបំពុលស្លាប់ក្នុងពេលជាខាងក្រោយមក (រឿងនិទានសរសេរលើថ្ម) ។

នៅឆ្នាំ១៨៦០ បងប្អូន២នាក់ឈ្មោះសេនាទា និងសេនាមាន់ បានក្រោកឡើងបះបោរនៅឡោមពួយ (Lom Pouyea) ប៉ុន្តែត្រូវបង្ខំចិត្តដកទ័ពទៅកាន់បាក់លីវ ក្នុងតំបន់ត្រខា (Tra Kha) ក្នុងភូមិឡុងថាន់សព្វថ្ងៃ ដោយពុំអាចទ្រាំទ្រនឹងយួនដែលមានទ័ពច្រើនលើសលប់បាន ។ ក្រោយមកសេនាទា សេនាមាន់ បានច្បាំងឈ្នះយួនវិញ ហើយលើកទ័ពដេញយួនរហូតដល់ពាមប៉ូលីវ (Péam Poliêv) ។ នៅទីនោះយួនបានទទួលជំនួយទ័ពចាមយ៉ាងច្រើន ហើយសេនាទាត្រូវទ័ពខ្មែរដឹកនាំយកទៅបញ្ចុះនៅក្នុងកូនកោះមួយ នៅក្បែរវត្តខ្មែរមួយនៅខ្វែងបូបិល (Khveng Bobel) ក្នុងភូមិបួនហៅហ៊ីងហួយ នៃខេត្តបាក់លីវ ។

□

## ~៣~

# ការទាមទារថ្មីមួយ
# របស់ព្រះបាទអង្គឌួង និង ព្រះបាទនរោត្តម

យើងបានឃើញនៅក្នុងវគ្គខាងលើ ស្តីពីការល្បងដណ្តើមដីវិញ ដែលព្រះបាទសម្តេចហរិរក្សរាមាព្រះអង្គឌួងបានរៀបចំឡើងនៅកម្ពុជាក្រោម (កូសាំងស៊ីន)ស្រេចអស់ហើយ ក្នុងគោលបំណងដេញយួនអណ្ណាមចេញពីរដ្ឋទាំងឡាយរបស់ព្រះអង្គ ។ ថ្វីបើព្រះអង្គជាក្សត្រធម៌ករុណានិងស្រឡាញ់សន្តិភាព ដោយហេតុអាណាប្រជានុរាស្ត្ររបស់ព្រះអង្គរងទុក្ខវេទនាមិនចេះចប់ក្តី ក៏ព្រះអង្គឌួងពុំអាចនៅព្រងើយកន្តើយចំពោះទុក្ខវេទនារបស់ប្រជារាស្ត្រព្រះអង្គ នៅប៉ែកខាងក្រោមដែលរងការសង្កត់សង្កិនបានដែរ ។ ព្រះអង្គទ្រង់បានត្រាស់បង្គាប់ឲ្យកសាងបន្ទាយយ៉ាងធំនៅក្នុងខេត្តមាត់ជ្រូក (ចូដុក) និងពាមឫស្សីខាំ (ហាទៀង) ដែលទុកដូចជាបន្ទាយមុខនៃការតស៊ូរបស់ខ្មែរ ។ ដោយសព្វព្រះទ័យម៉្យាងនឹងជោគជ័យដំបូងទាំងឡាយរបស់ព្រះអង្គ និងដោយឃើញបរាជ័យបន្តបន្ទាប់គ្នារបស់យួនអណ្ណាម ព្រះបាទអង្គឌួងបានទៅដល់ទីដៅយ៉ាងប្រាកដណាស់ ហើយពិតជានឹងបានជាសម្ព័ន្ធមិត្តដ៏ប្រាកដមួយរបស់ប្រទេសបារាំង ក្នុងការប្រឆាំងប្រទេសអណ្ណាម បំណងដណ្តើមយកដីសំបូរជីរជាតិរបស់ព្រះអង្គ ដែលយួនលួចយកទៅ បើសិនណាហើយព្រះអង្គពុំបានប្រឈួនរួចចូលសុវណ្ណកោដ្ឋនៅក្នុងឆ្នាំ១៨៦០ ដែលជាហេតុមួយធ្វើឲ្យផែនការរបស់ព្រះអង្គចប់ទេនោះ (អញ្ជើញអានសៀវភៅរបស់លោក អាដេម៉ាដ៍ឡឺក្លែរ ពីទំព័រ៤៤៥ដល់៤៤៧ A. Leclère pp.445-447) ។

ក្រៅពីចំបាំងទាំងឡាយដឹកនាំផ្ទាល់ព្រះអង្គប្រឆាំងនឹងយួនអណ្ណាម និងការសុំជំនួយនិងកិច្ចគាំទ្រផ្សេងៗពីព្រះចៅណាប៉ូឡេអុងទី៣ អធិរាជប្រទេសបារាំងនោះ ព្រះបាទអង្គឌួងទ្រង់បានធ្វើចុតហ្មាយយ៉ាងច្រើនទៅទូលអធិរាជអង្គនេះ ឲ្យជ្រាបអំពីសិទ្ធិលើទឹកដីនានារបស់ខ្មែរនៅកម្ពុជាក្រោម (ដែលយួននិងបារាំងហៅថាកូសាំងស៊ីន) ។ នៅខែវិច្ឆិកា១៨៥៥ ព្រះបាទអង្គឌួងបានសុំ (ម៉ុងសេញ៉ូរមីស) សរសេរចុតហ្មាយមួយ ផ្ញើទៅចងស្ពានមេត្រីជាមួយព្រះចៅណាប៉ូឡេអុងទី៣ ។ ចុតហ្មាយនោះបានផ្ញើទៅប្រទេសបារាំង តាមរយៈកុងស៊ុលបារាំងនៅសឹង្ហបូរី ដោយមានទាំងជង្វាយ (សួយសា) មួយហិបផង ។

ប៉ុន្តែក្នុងពេលលោកដឺម៉ុងទីញ៉ីអញ្ជើញមកដល់ប្រទេសកម្ពុជា ស្រាប់តែព្រះបាទអង្គឌួងភ្ញាក់ព្រះអង្គ ដោយលោកដឺម៉ុងទីញ៉ីទូលថា គេឥតបានទទួលឬដឹងដំ-

ដំណើងអ្វីបន្តិចទេ ពីរឿងចុតហ្មាយផ្ញើទៅព្រះចៅណាប៉ូឡេអុងនោះ (អញ្ជើញអាននសៀវភៅ អាណាចក្រទី២នៅឥណ្ឌូចិន របស់លោកសាលឡេនីយ៉ា ទំព័រ៣៥៩ ( Le second Empire Indochine par Charls Leyniard p.359) ។

នៅឆ្នាំ១៨៥៦ ព្រះបាទអង្គឌួងបានផ្ញើចុតហ្មាយនិងជង្វាយមួយទៀត ទៅថ្វាយព្រះចៅណាប៉ូឡេអុងទី៣ តាមរយៈកុងស៊ុលបារាំងនៅសឹង្ហបូរីដដែល ។ ចុតហ្មាយនេះគឺជាចុតហ្មាតតវ៉ា និងទាញអារម្មណ៍អធិរាជបារាំងដែលទើបនឹងចូលកាន់កាប់ខេត្តខាងកើតនានានៃកម្ពុជាក្រោម ឲ្យដឹងថាកម្ពុជាក្រោមគឺជាដីរបស់ខ្មែរ ។ ព្រះអង្គសុំព្រះចៅអធិរាជប្រទេសបារាំងកុំឲ្យទទួល «អំណោយដី» ទាំងអស់ណាពីស្តេចអណ្ណាម ព្រោះសុទ្ធតែជាដីដែលបានលួចខ្មែរកម្ពុជាក្រោម (កូសាំងស៊ីន) ។

នៅឆ្នាំ១៨៦៤ ក្នុងពេលយាងទៅជួបឧត្តមនាវីដឺឡាហ្រ្គង់ឌីយ៉េរ (Amiral de Lagrandière) នៅព្រៃនគរ ដោយមានលោកឌូដាដឺឡាប្រេ្គជូនដំណើរផង ព្រះបាទនរោត្តមបានទាមទារយ៉ាងម៉ឺងម៉ាត់ ឲ្យបារាំងប្រគល់ខេត្តធំគ្នាទាំងបីគឺ ៖ វិញឡុង (ដែលមានខេត្តលង់ហោរ ផ្សារដែក និងព្រះត្រពាំង / វិញឡុង សាដែក ត្រាវិញ) ចូដុក (ដែលមានរួមខេត្តមាត់ជ្រូក ឡុងសៀង កន់ថឺ និងសុកត្រាំង) ហើយនិងហាទៀង (ដែលមានខេត្តពាម រ៉ាច់យ៉ា និងបាក់លីវ) ប្រគល់មកខ្មែរវិញ ។ ខេត្តទាំងបីក្រុមនេះ ត្រូវសន្ធិសញ្ញាឆ្នាំ១៨៦២ រៀបចំប្រគល់ឲ្យយួនអណ្ណាម ។ សន្ធិសញ្ញានេះខុសច្បាប់ទាំងស្រុង ដោយហេតុថាវាធ្វើឡើង ស្តីពីរឿងខេត្តទាំងឡាយរបស់ខ្មែរ ដោយមិនឲ្យខ្មែរដឹងផង ហើយប្រគល់ឲ្យទៅយួន ដែលពុំមែនជាខេត្តរបស់យួនម្តងណាសោះថែមទៀតផង (le traîté de 1862 est nul de plein droit puisqu'il réglait le sort des provinces cambogiennes, jamais reconnues comme annamites, à l'insu du Cambodge, et laissait encore à l'Annam) ។ ព្រះបាទនរោត្តមបានយាងចូលក្នុងប្រទេសវិញ នៅក្នុងខែតុលា១៨៦៤ ដោយបានទទួលពាក្យសន្យាពីបារាំងថា នឹងប្រគល់ខេត្តផ្តាច់ (Provinces détachées) ទាំងនោះឲ្យខ្មែរវិញ (ក្នុងករណីនេះសូមអានសៀវភៅ «ខ្មែរនៅកូសាំងស៊ីន» របស់លោកបារ៉ូលី (Cambogiens de Cochinchine par G. Barrault) ។

# វគ្គទី២

## ការកាន់កាប់ដោយខុសច្បាប់នៃយួនអណ្ណាម

ការដកស្រង់ដោយសង្ខេប នូវហេតុការណ៍ជាប្រវត្តិទាំងឡាយ បង្ហាញឲ្យឃើ

ញយ៉ាងច្បាស់ថា យួនអណ្ណាមពុំបានធ្វើចំបាំងដណ្តើម (Conquête) ( កកន៖ សូម
អញ្ជើញអានច្បាប់ផង ដើម្បីជ្រាបន័យពាក្យ Conquête នេះ ពិសេសច្បាប់អន្តរជា
តិសាធារណៈ) នូវដីកម្ពុជាក្រោមឬដីនោះត្រង់ណាមួយដុំសោះឡើយ ការជ្រៀតចូ-
លនៃពួកយួនអណ្ណាមមកលើផ្នែកនៃព្រះរាជាណាចក្រកម្ពុជានេះបានត្រូវមានឡើង
ដោយសារតែចំបាំងក្នុងស្រុក រវាងព្រះរាជវង្សានុវង្សនិងក្សត្រគ្រប់គ្រងរាជ្យ គឺចំ-
បាំងនៃស្តេចបះបោរទៅពឹងយួន ក៏រីឯចំណែកស្តេចម្ខាងទៅពឹងសៀម ។

ជំហានទី១នៃការជ្រៀតចូលរបស់យួន ត្រូវផ្តើមឡើងនាពេលនោះ ដោយការ
ញុះញង់របស់ក្សត្រីអណ្ណាម មហេសីរបស់ស្តេចជ័យជេដ្ឋាទី២ជាមេគំនិត ។ ក៏ប៉ុន្តែ
ដំបូងឡើយ គឺគ្រាន់តែជាសេចក្តីអនុញ្ញាត (Autorisation) ដែលព្រះបាទជ័យជេដ្ឋា
ទី២ បានប្រទានឲ្យយួនអណ្ណាម តាំងហាងជំនួញនៅផ្នែកចុងខាងត្បូងបំផុតរបស់
ប្រទេសកម្ពុជា គឺជាកំពង់ក្របី (បច្ចុប្បន្នព្រៃនគរ) និងមួយស៊ុយ (Moi Xu) តែប៉ុ-
ណ្ណោះ ។ ដោយសេចក្តីអនុញ្ញាតនេះ ក្សត្រីយួនអណ្ណាមដែលពុំមែនគ្រាន់តែមានឥ
ទ្ធិពលលើសលប់លើព្រះបាទជ័យជេដ្ឋាទី២ តែរហូតដល់ក្សត្រតំណវង្ស (បុត្រនិង
ចៅ) របស់ជ័យជេដ្ឋាទី២ផងទៀត អាចដឹកនាំយួនឲ្យចូលមកកាន់កាប់ប្រទេសកម្ពុ-
ជាផ្នែកនោះ ហើយតាំងលំនៅដោយស្រួល ។

តាំងពីពេលនោះមក បញ្ហាកំពង់ក្របី និងមុយស៊ុយ ទៅជាបញ្ហាមួយដោះស្រា
យពុំរួច ។ តាមចុតហ្មាយរបស់ក្សត្រយួន ពេលនោះបានឲ្យដឹងថា ប្រទេសអណ្ណាម
បានសុំប្រើប្រាស់ដីនេះតែក្នុងរយៈពេល៥ឆ្នាំប៉ុណ្ណោះ ដោយប្រទេសអណ្ណាមបាន
អះអាងហេតុថា ខ្លួនត្រូវការទ័ពរបស់ខ្លួនសំចតដើម្បីស្លអាវុធ (អញ្ជើញអានពង្សាវ-
តាប្រទេសកម្ពុជា ក្បាលទី៣២) ។

បន្ទាប់មក ស្តេចប្រទេសខ្មែរបានសុំឲ្យស្តេចប្រទេសអណ្ណាមប្រគល់ដីកោះក្រ
បី និងមួយស៊ុយ មកឲ្យខ្មែរវិញអស់ពីរលើក លើកទី១នៅឆ្នាំ១៦៤៥ ធ្វើឡើងដោយ
ព្រះបាទអង្គតូ (ពង្សាវតារប្រទេសកម្ពុជា ច្បាប់ស្លឹករឹត ក្បាលទី៣២) និងលើកទី២
នៅក្នុងឆ្នាំ១៦៥៣ ធ្វើឡើងដោយព្រះអង្គច័ន្ទ ។ ចំពោះការឲ្យប្រគល់វិញលើកទីមួយ
ក្សត្រីជូជាតិយួនអណ្ណាមមេម៉ាយពីព្រះបាទជ័យជេដ្ឋាទី២ បានឆ្លើយវិញថា ប្រទេស
យួនអណ្ណាមកំពុងច្បាំងជាមួយប្រទេសចិន បានសេចក្តីត្រូវការជាចាំបាច់ចំពោះដី
នោះ ហើយអង្វរខ្មែរឲ្យទុកដីនោះឲ្យយួនប្រើប្រាស់សិន ។ ក្សត្រីអណ្ណាមឈ្មោះជូ
មេម៉ាយពីព្រះបាទជ័យជេដ្ឋាទី២ដដែលនេះ បានសន្យាយ៉ាងជាក់ស្តែងថា នឹងប្រគ
ល់ដីទាំងនោះមកឲ្យខ្មែរវិញ ពេលណាអធិរាជាណាចក្រអណ្ណាមលែងត្រូវការ ។
លើកទី២ក្សត្រីជូ យួនអណ្ណាមមេម៉ាយពីព្រះបាទជ័យជេដ្ឋាទី២ដដែលនេះទៀតបាន
អង្វរករសុំឲ្យព្រះអង្គច័ន្ទ ទុកដីកោះក្របី និងមួយស៊ុយ នេះជាចំណែកដាច់មុខដែ-

ត្រូវបានទៅនាង ក្នុងឋានៈព្រះនាងជាក្សត្រីយានីប្រទេសខ្មែរ (មហេសីក្សត្រសោ-យរាជ្យព្រះនាមជ័យជេដ្ឋាទី២) ដោយដូរជាមួយខេត្តទាំងប្រាំដែលឲ្យព្រះនាង ។

ក្នុងរឿងនេះ បើសិនណាហើយយើងសន្មត់ថា សេចក្តីអនុញ្ញាតកាន់កាប់ (l'autorisation d'occupation) កោះក្របី និងមួយស៊ុយ អាចកែប្រែទៅជាសិទ្ធិចំណែកដាច់មុខ ត្រូវបានទៅមនុស្សម្នាក់ (droit d'apanage) ក៏ដោយចុះ ក៏គេពុំត្រូវភ្លេចទេថា សិទ្ធិនេះនៅតែនិងជាសិទ្ធិបុគ្គល (droit personnel) ប៉ុណ្ណោះ ពុំអាចបង្កើតបានជាសិទ្ធិកម្មសិទ្ធិណាមួយ សំរាប់សាមីជនឡើយ តាមច្បាប់ខ្មែរ ។ សិទ្ធិនេះរលត់ទាំងស្រុងទៅតាមមរណភាពរបស់សាមីជន ។

ដូច្នេះ ដីទាំងពីរចំណែកដ៏ធំនោះ បានធ្លាក់ចូលទៅក្នុងដៃរបស់យួនអណ្ណាមដោយឧបាយកល ។ ស្តេចខ្មែរឥតដែលបានបោះបង់កម្មសិទ្ធិនេះទៅឲ្យយួនអណ្ណាមម្តងណាសោះឡើយ ។

ក្រោយមកទៀត ពួកយួនមានបញ្ហានេះពង្រីកដីនៅប៉ែកខាងក្រោមនេះឥតឈប់ឈរ ដោយពួកវាបានឆ្លៀតធ្វើការនេះនៅក្នុងពេលណាដែលស្តេចខ្មែរឈ្លោះទា-ស់ទេងច្បាំងដណ្តើមរាជ្យគ្នា ។

គឺតាមរបៀបនេះហើយទើបបានជានៅក្នុងឆ្នាំ១៧៨៩ យួនអណ្ណាមចំនួន២ម៉ឺននាក់ ដែលបានចូលមកជួយច្បាំងឧបរាជនន់ទល់នឹងព្រះអង្គសូនោះ បានចូលទៅតាំងលំនៅដោយស្រួលនៅកូសាំងស៊ីន (កម្ពុជាក្រោម) ក្រោយពីស្តេចខ្មែរជាមេទ័ពខ្លួនបរាជ័យ ។

ដូចគ្នានេះទៀត នៅឆ្នាំ១៨៩៩ ពួកយួនអណ្ណាម២០,០០០នាក់ទៀត ឋិតនៅក្រោមបញ្ជាឧកញ៉ាឧរិទ្ធអែម ដែលរៀបចំច្បាំងនឹងស្តេច ក៏បានរត់ទៅតាំងនៅយ៉ាង «វាហី» នៅបៀងហ្វា និងព្រៃនគរ ក្រោយពីច្បាំងចាញ់ទ័ពរបស់ស្តេចខ្មែរ ។ នៅពេ-លនោះទៀត ក៏ក្សត្រីយួនអណ្ណាមអង្គជូ ទទួលសេចក្តីអនុញ្ញាតឲ្យជនរួមជាតិរប-ស់ព្រះនាង តាំងនៅក្នុងដីទាំងនោះដោយល្បិចកល ។

ក្រោយពីគិតទៅដឹងថា ខ្លួនមានចំនួនច្រើនល្មមហើយ ខ្លាំងល្មមហើយ ពួកយួនទាំងនោះក៏ចាប់ផ្តើមចែកដីទាំងនោះ ជាស្រុកតូចៗ ស្ថិតនៅក្រោមការត្រួតត្រារបស់យួន ដែលធ្វើឡើងផ្ទាល់នៅក្រោមការត្រួតត្រារបស់យួន ដែលឡើងផ្ទាល់ទៅមេទ័ពយួនម្នាក់ កាន់កាប់ទាំងអំណាចស៊ីវិលនិងយោធា ទាំងនៅព្រៃនគរ ។ ទោះបីពេលនោះ នៅក្នុងខេត្តយ៉ាងច្រើនខ្លះ ជនជាតិខ្មែរកាន់កាប់ជាផ្លូវការដោយមានងារជាចៅហ្វាយស្រុក ឬក្រឡាពាស ដែលជាគោរម្យងារស្រដៀងគ្នានិងគោរម្យងារយួន ហៅទ្រីភូ និងទ្រីហៀង ក៏គង់តែចេញឃើញច្បាស់ណាស់ទៅហើយ អំពីការទ-ន្ទ្រានខាងនយោបាយនៃយួនមកលើខ្មែរដែរ ។ ព្រះរាជបល្ល័ង្កខ្មែរពុំអាចតបតការ

នេះបានឡើយ ដោយហេតុខ្លួនជាប់ចំបាំងក្នុងស្រុករវាងវង្សខ្លួន ។ ម្យ៉ាងទៀតនៅក្នុងរឿងនេះ យើងត្រូវនិយាយផងដែរ អំពីកម្មវិធីយួនធ្វើដីខ្មែរទៅជាដីអណ្ណាម នូវដីទាំងអស់ណាដែលខ្លួនគ្មានសិទ្ធិកាន់កាប់ ។ ឧបាយរបៀបទាំងនេះ យួនរំពុកយកមកប្រើក្នុងពេលថ្មីៗនេះទៀត ។

ឧទាហរណ៍ទី២នៃការវាតដីរបៀបនេះ ឋិតនៅក្នុងការចូលកាន់កាប់ (Prise possession) ឬដណ្ដើមយកខេត្តមីថរ និងវិញឡុង ។ យួនអណ្ណាមបានបន្លំធ្វើទ័ពខ្មែរ ចូលកាន់កាប់ខេត្តទាំងពីរនេះអស់ពីរលើក ។ លុះមិនសំរេច ត្រូវយួនប្រើទៀតក្នុងឆ្នាំ១៧៥៨ ក្នុងការដណ្ដើមយកខេត្តសុកទ្រាំង ។ កាលប្រវត្តិរបស់យួនបានបង្ហាញហេតុនៃការចូលកាន់កាប់ដីខេត្តទាំងពីរនោះ ថាមកពីខ្មែរសម្លាប់រង្គាល (Massacre) ជនជាតិយួនរស់នៅក្នុងប្រទេសខ្មែរ និងថាមកពីស្ដេចខ្មែរកាន់ជើងការសម្លាប់រង្គាលនោះ ដោយបញ្ជាឲ្យច្បាំងបង្ក្រាបយួនរស់លើដីខ្មែរ ។

រឿងបាត់ដីមួយទៀត គឺកើតឡើងនៅក្នុងឆ្នាំ១៧៥៨ ដោយស្ដេចឧទ័យ ធ្វើអនុប្បទានខេត្តសុកទ្រាំងនិងព្រះត្រពាំង (ត្រាវិញ) ទៅឲ្យប្រទេសអណ្ណាមតែម្ដង ដោយទុកថាជាសោហ៊ុយនៃការនឿយហត់របស់យួន ក្នុងការជួយច្បាំងដណ្ដើមបល្ល័ង្កឲ្យព្រះអង្គ ។ របៀបអប្រិយនេះ នាំឲ្យយួនបានចិត្ត ហើយលើកគោលសីមាទាំងកំពែរលឆ្ពោះមកទិសខាងជើង រហូតហ៊ានយកគោលសីមាទៅដាក់ព្រំដែនខេត្តចូដុក។ ដើម្បីបង្ការឲ្យការកាន់កាប់របស់ខ្លួននោះមានសន្តិសុខ យួនអណ្ណាមបានសាងបន្ទាយយ៉ាងមាំនៅសាដែក គុយឡៀយៀង និងនៅចូដុក ។

ដូច្នេះ ចាប់ពីដំណាក់ការមួយមកដំណាក់ការមួយជាបន្តបន្ទាប់គ្នា រហូតដល់ឆ្នាំ១៨៤៨ ពួកយួនអណ្ណាមបានតាំងទីជាស្ថាពរស្រេច នៅក្នុងខេត្តជាយដែនទាំងឡាយរបស់ខ្មែរ ដែលខ្លួនបានយកទ័ពទៅឲ្យកាន់កាប់ ក្នុងឱកាសខ្លួនចូលជួយធ្វើអន្តរាគមន៍នានាក្នុងរឿងផ្ទៃក្នុងរបស់ខ្មែរ ។

ចំបាំងទាំងឡាយនិងការបះបោរនានាប្រឆាំងនឹងយួនអណ្ណាម បញ្ជាក់យ៉ាងគ្រប់គ្រាន់ណាស់ទៅហើយថា គ្មានស្ដេចខ្មែរណាមួយអង្គ គ្មានរាស្ត្រខ្មែរមួយរូបណាសុខចិត្តកាលនោះ និងព្រមបោះបង់កម្មសិទ្ធិនៃទឹកដីកូសាំងស៊ីនទៅឲ្យពួករុករានឡើយ រហូតដល់ធ្វើឲ្យលោកមូរ៉ា (Moura) សរសេរយ៉ាងក្បោះក្បាយអំពីទឹកចិត្តខ្មែរ តាមបន្ទាត់ទាំងឡាយ ដែលយើងសូមដកស្រង់ខ្លះមកជូនជ្រាបដូចតទៅនេះ ៖

«ប៉ុន្តែ បើខ្មែរបានបណ្ដោយឲ្យគេពន្លះស្បែក (ដណ្ដើមដី) ដោយគ្មានពាក្យអ្វីនឹងនិយាយនៅពេលនោះ តើត្រូវយល់ថាខ្មែរបោះបង់ចោលសំរាប់ពេលនោះនិងក្នុងអនាគត នូវការទាមទារឬ ? វិធានស្ដីពីអាជ្ញាយុកាលផុតរលត់ពេល អាចឲ្យ(យួន)យកមកអនុវត្តដោយសមរម្យចំពោះរបៀបកំហែងយកដីកម្មសិទ្ធិរបស់អ្នកជិតខាងបា

នឬទេ?» ។

បន្ទាប់មក ក្រោយពីផ្តល់គំនិតខ្លះដែលនាំឲ្យរំខានដល់ការដណ្តើមយកមកវិញនូវអាណាខេត្តបាត់ដំបងនិងសៀមរាបអង្គរ ដែលសៀមប្លន់យកនោះ អ្នកនិពន្ធរូបដែលខាងលើនេះ គឺលោកមូរ៉ា បានត្រឡប់ទៅនិយាយពីដីកូសាំងស៊ីន (កម្ពុជាក្រោម)ម្តងទៀត ដោយលោកបានទាយ ហើយនេះប្រហែលអស់លោកខ្មែរ(ធំៗ) មិនទាំងនឹកឃើញ ឬហ៊ានហើបមាត់ថាផងទេថា ៖

«**...ហើយយើងសង្ឃឹមថាកាលៈទេសៈល្អនឹងមាននៅក្នុងថ្ងៃណាមួយពុំខាន ហើយយើងជឿទៀតថា រឿងក្តី(វិវាទ)នេះ នឹងអាចត្រូវបញ្ចប់ដោយសមធម៌ពុំខាន** » ។

ប្រទេសបារាំងពុំសូវភ្លេចឧត្តមគតិខាងលើនេះរបស់លោកមូរ៉ាណាស់ណាទេ តែចំពោះតែដីដែលសៀមកំហែងយកពីខ្មែរតែប៉ុណ្ណោះ ។ ថ្វីបើមានសេចក្តីស្នើការរបស់ព្រះអង្គច័ន្ទនិងព្រះបាទនរោត្តម ដែលបានទាំងសំរេចព្រះទ័យស្ថិតក្រោមអាណាព្យាបាលរបស់ខ្លួនក្តី ក្នុងគោលបំណងមិនត្រឹមតែដើម្បីបញ្ចៀសការទន្ទ្រានពួកសៀមនិងយួន ប៉ុន្តែដើម្បីចូលកាន់កាប់វិញនូវអាណាខេត្តធំៗទាំងប្រាំមួយដែលបង្កើតជាកូសាំងស៊ីន (កម្ពុជាក្រោម)ផងនោះក្តី ក៏ប្រទេសបារាំងឥតបានធ្វើអ្វីនៅក្នុងន័យនេះ ដើម្បីខ្មែរសោះទេ ប៉ុន្តែត្រឡប់ទៅជាសប្បាយចិត្ត និងបញ្ចូលជាសម្ព័ន្ធនូវដីនេះធ្វើជាដីអាណានិគម ដីចំណុះខ្លួនវិញ ដោយលបធ្វើសន្ធិសញ្ញាជាមួយយួនចុះថ្ងៃ៥មថុនា១៨៦២ម្តង និងថ្ងៃ១៥មិនា១៨៧៤ម្តងទៀត ។

ហេតុការណ៍ទាំងឡាយជាប្រវត្តិសាស្រ្តចង្អុលបង្ហាញថា ប្រទេសកម្ពុជាឥតដែលយល់ព្រមបោះបង់ចោលកម្មសិទ្ធិលើដីនោះ (កម្ពុជាក្រោម) ដែលលោកមូរ៉ា ព្រមទាំងអ្នកនិពន្ធប្រវត្តិវិទូធំៗ ទទួលស្គាល់ជាឯកច្ឆន្ទថា ជាដីរបស់ខ្មែរម្តងណាសោះទេ ។ លើសពីនេះទៀត នៅមុនពេលបារាំងចូលត្រួតត្រាដីនោះ វាពុំមានព្រំដែនខណ្ឌប្រទេសកម្ពុជាបច្ចុប្បន្ននិងកូសាំងស៊ីនបច្ចុប្បន្ន (កម្ពុជាក្រោម)សោះទេ ។ ហេតុនេះសឲ្យឃើញថា មកទល់នឹងបារាំងចូលមកត្រួតត្រា យួនពុំអាចធ្វើដីខ្មែរផ្នែកនេះជាដីខ្លួន ហើយនិងធ្វើខ្លួនឲ្យទៅជាម្ចាស់ផុតសិទ្ធិតវ៉ាបានឡើយ ។ ព្រែកជីកវិញតេ ដែលបារាំងយកធ្វើព្រំដែននោះ គឺត្រូវជីកឡើងដោយពួកយួននិងខ្មែរ សំរាប់សេចក្តីត្រូវការរួមនៅសម័យនោះ សោតឯចៅហ្វាយខេត្តយួនដែលត្រួតត្រាការដ្ឋាននោះ ក៏បានទទួលស្គាល់ខ្លួនឯងថា «គាត់ទទួលដាវអាជ្ញាសឹកមួយ និងព្រះសង្ការ (ត្រា) ដើម្បីជាសក្ខីភាពនៃអំណាចយោធានិងស៊ីវិលនៅប្រទេសកម្ពុជា» ដើម្បីធ្វើការស្ថាបនាព្រែកជីកនេះ ។ គឺរឿងព្រែកជីកវិញតេនេះហើយ ដែលនាំឲ្យខ្មែរបំភ្លេចមិនបានពីអនុស្សាវរីយ៍ (កំពប់តែអុង) ។ តាមលោកមូរ៉ា ចៅហ្វាយខេត្តយួនដែល

ត្រួតស្រុកខ្មែរនៅឆ្នាំ១៨១៣នោះ គ្មាននរណាក្រៅពីរូបអាណាព្យាបាយប្រទេសកម្ពុជា ដែលស្ដេចយួនអណ្ណាមចាត់ជាតំណាង មកត្រួតខ្មែរនោះឡើយ ។

ដូច្នេះទោះនៅក្នុងសម័យណាក៏ដោយ កូសាំងស៊ីនឬកម្ពុជាក្រោម នៅជាដីរបស់ខ្មែរជានិច្ច ។ យើងមិនដែលឈប់ការប្រយុទ្ធដើម្បីទាមទារដណ្ដើមយកដីនេះម្ដងណាសោះទេ រហូតលុះត្រាតែបារាំងចូលមកធ្វើចៅហ្វាយរួមរបស់យួននិងខ្មែរ ហើយយកដីនោះធ្វើជាដីកម្មសិទ្ធិខ្លួនដោយខ្លួនឯង រួចធ្វើជាដីចំណុះ ទើបការត្រូវព្យួរសិន ។

បើទោះជានៅក្នុងកាន់កាប់នោះ បញ្ហា«កូសាំងស៊ីន» ហាក់ដូចជាបានដោះស្រាយជ្រះស្រឡះហើយ រវាងប្រទេសបារាំងនិងប្រទេសកម្ពុជា ហើយដូចគ្នានេះដែរ រវាងប្រទេសកម្ពុជានិងយួនអណ្ណាម ក៏យើងបានទាមទារសិទ្ធិជាម្ចាស់ដីជាច្រើនសារដោយកម្លាំងអាវុធ បន្ទាប់មកដោយកិច្ចចរចា (ខកចិត្ត) ជាមួយប្រទេសបារាំង ។ នៅពេលថ្មីៗនេះ គឺក្រោយពីសៀមដណ្ដើមយកខេត្តបាត់ដំបងនិងសៀមរាបក្នុងឆ្នាំ១៩៤១ គណរដ្ឋមន្ត្រីខ្មែរបានទៅស្រុកបារាំង ដើម្បីទាមទារ«កូសាំងស៊ីន» ប៉ុន្តែត្រូវខកចិត្តទៀត ដោយសារតំណាងប្រទេសបារាំងនៅប្រទេសកម្ពុជារារាំង ។

⌘

⌘ ⌘

# ជំពូក៤
# ទល្ហិករណ៍ផ្នែកគតិយុត្ត

ចាប់ពីឆ្នាំ១៦២៣មក យួនអណ្ណាមផ្តើមតាំងទីបន្តិចម្តងៗលើដីប៉ែកខាងក្រោមរបស់យើង គឺកូសាំងស៊ីនឬកម្ពុជាក្រោមនេះឯង ។

តើការរុកទន្ទ្រានដណ្តើមនេះអាចបង្កើតជាសិទ្ធិនៃអធិបតេយ្យភាព (droit de souveraineté) ដល់ប្រទេសអណ្ណាមឬទេ ?

ក្នុងរឿងនេះគេនឹងឆ្លើយថាទេ ! មួយរំពេច ។

ប្រទេសអណ្ណាមដែលទទួលសំណាងពីហេតុជាប្រវត្តិសាស្ត្រនានា ដូចដែលបានវែកញែករួចមកហើយ ឥតមានមូលដ្ឋានអ្វីមួយសំរាប់បញ្ជាក់ពីរបៀបលទ្ធកម្មទទួលសិទ្ធិ (Modes d'acquisition) (១) នៃអធិបតេយ្យភាព (ឬទទួលអធិបតេយ្យភាព) ដែលចែងនៅក្នុងនីតិអន្តរជាតិសាធារណៈទ្បើយគឺ ៖

១- <u>ការកាន់កាប់</u> ៖

ការកាន់កាប់ដើម្បីឲ្យបានជាសិទ្ធិអធិបតេយ្យភាពលើដែនដីណាមួយ ទោះបីជាសិទ្ធិនោះនៅជាសិទ្ធិអចិរៈ (Précaire) គឺសិទ្ធិដែលគេអាចដកហូតវិញបានក្តី និងនៅក្នុងការតវ៉ាក្តី តំរូវឲ្យមានការចូលកាន់កាប់ (La prise en possession) នៃដីនោះ ដែលពុំមែនជាដីរបស់ជនឬប្រទេសណាមួយសោះ ឬរស់នៅដោយកុលសម្ព័ន្ធមនុស្សណាសោះ ហើយដែលម្ចាស់ដើម ឬជនព្រៃកុលសម្ព័ន្ធទាំងនោះលះបង់ចោលតាមកិច្ចសន្យា នូវសិទ្ធិអធិបតេយ្យភាពនោះ ទៅឲ្យបរទេសណាមួយ ដែលទទួលក្នុងនាមនៃស្តេចរបស់ខ្លួន (២) ។

ករណីនេះឥតមានសោះចំពោះប្រទេសកម្ពុជា ។ យ៉ាងច្រើនណាស់វាមានត្រឹមតែ «សេចក្តីអនុញ្ញាតឲ្យតាំងផ្ទះជំនួញ» តែប៉ុណ្ណោះ នៅក្នុងតំបន់ខ្លះ ដូចជានៅតំបន់ព្រៃនគរកាលពីឆ្នាំ១៦២៣ ។

២- <u>ការប្រគល់ធ្វើទ្បើងដោយសន្ធិសញ្ញា ឬអនុសញ្ញា</u> ៖

រវាងប្រទេសកម្ពុជានិងប្រទេសអណ្ណាម ពុំដែលមានកិច្ចជាផ្លូវទូត ឬអនុស-

(១) *សូមអញ្ជើញអាននីតិអន្តរជាតិសាធារណៈ:* International public *ស្តីពី* Modes d'acquisition de souveraineté ។

(២) *អញ្ជើញអាននីតិអន្តរជាតិសាធារណៈ និងឥផ្សាវតារខ្មែរ ។*

សញ្ញាណាមួយ ស្តីពីការប្រគល់ខេត្តទាំងឡាយនៅកូសាំងស៊ីន(កម្ពុជាក្រោម) ទៅឲ្យប្រទេសអណ្ណាមឡើយ ។

៣- ចំបាំងដណ្តើម ៖

និយាយពីចំបាំងដណ្តើមទៀត ក៏រ៉ារឹតតែគ្មានណាស់ទៅទៀត គ្រប់អន្តរាគមន៍ទ័ពរបស់ពួកយួនអណ្ណាមមកលើប្រទេសកម្ពុជា គឺសុទ្ធសឹងតែធ្វើឡើងដោយសេចក្តីសុំរបស់ស្តេចខ្មែរដែលបះបោរឡើង ប្រឆាំងនឹងស្តេចសោយរាជ្យ ដោយយកលេសថាខ្លួនជាអ្នកមានសិទ្ធិត្រូវគ្រងរាជ្យ ឬរបស់មេបះបោរណាមួយ ឬក៏ដើម្បីច្បាំងទប់ទល់ពួកសៀម ដូចដែលយើងបានឃើញនៅក្នុងឯកសារទាំងឡាយនៃពង្សាវតាខ្មែរ និងស្នាដៃរបស់អ្នកនិពន្ធបរទេសធំៗ ដូចជាលោលមូរ៉ា និងលោកអាដេម៉ារឡឺក្លែរ ។ល។

៤- អាជ្ញាយុកាល ឬការផុតកំណត់ច្បាប់ ៖

បើទោះបីទ្រឹស្តីនៃអាជ្ញាយុកាល ឬការផុតកំណត់ច្បាប់ (prescription) (៣) ដើម្បីឲ្យបានជាម្ចាស់កម្មសិទ្ធិ ត្រូវបណ្តាអ្នកគតិយុត្តបដិសេធចោលហើយក្តី សព្វថ្ងៃនេះក៏គេមិនអាចយកការនេះធ្វើជាទល្ហិករណ៍ (ការសំអាង) បានឡើយ ដោយហេតុថាពេលនោះប្រទេសខ្មែរពុំអាចធ្វើអ្វីបានឡើយ ក្នុងសម័យកាលយុគវិបត្តិផ្ទៃក្នុង និងក្នុងសម័យបិតក្រោមអាណាព្យាបាលរបស់បារាំង ។

គ្រប់តែពេល ស្តេចខ្មែរនានាបានបង្ហាញនូវសេចក្តីសំរេចចិត្តរបស់ព្រះអង្គ មិនបោះបង់ដីទាំងឡាយដែលយួនកាន់កាប់នោះ ដោយប្រើមធ្យោបាយស្នើការ និងការវាយដណ្តើមវិញ ។

ក- នៅឆ្នាំ១៦៤៥ ព្រះបាទអង្គតូ ទាមទារកោះក្របី និងមួយស៊ុយ ។

ខ- ឆ្នាំ១៦៥៣ ព្រះបាទអង្គច័ន្ទ បានទាមទារដីនេះជាថ្មីម្តងទៀត ។

គ- ឆ្នាំ១៨៥៤ ព្រះបាទអង្គឌួង បានរៀបចំទ័ពសម្ងាត់ទៅជួយទ័ពខ្មែរបះបោរនៅបាសាក់និងព្រះត្រពាំង ។ ការរៀបចំនេះត្រូវអាក់ដំណើរ ក្នុងពេលព្រះអង្គចូលសុវណ្ណកោដ្ឋ ។

ឃ- ខាងផ្នែកទាក់ទងពួកអឺរ៉ុប ព្រះបាទអង្គឌួងបានបញ្ជូនមន្ត្រីទូត ឬអ្នកតំណាងខ្មែរជាច្រើនលើកទៅកាន់ក្រុងសឹង្គបុរី ដើម្បីសុំជំនួយពីប្រទេសបារាំង ។ បេសកកម្មទូតចុងក្រោយបំផុតបានធ្វើឡើងក្នុងឆ្នាំ១៨៥៤ ។

ង- ព្រះបាទនរោត្តម ក្នុងពេលយាងទៅក្រុងព្រៃនគរ ខែតុលា ឆ្នាំ១៨៦៤ ក្រោយពីបានចុះហត្ថលេខាលើសន្ធិសញ្ញាដាក់ប្រទេសកម្ពុជា ក្រោមអាណាព្យាបា

---

*(៣) អញ្ជើញអានទ្រឹស្តីនៃអាជ្ញាយុកាលក្នុងនីតិបវេណីខ្មែរ និងទ្រឹស្តីនានារបស់អ្នកច្បាប់អន្តរជាតិចុះ ។*

លបារាំង ។ ទ្រង់បានស្នើការដោយបង្ខិតបង្ខំយ៉ាងខ្លាំងចំពោះអាជ្ញាធរបារាំង សុំឲ្យខ្មែរចូលកាន់កាប់ខេត្តទាំងឡាយនៅកូសាំងស៊ីន ។

ច- នៅពេលថ្មីៗនេះទៀត ជាពិសេសចាប់តាំងពីមានរឿងវិវាទក្នុងរឿងខេត្តបាត់ដំបង សៀមរាប រដ្ឋាភិបាលខ្មែរបានបញ្ចេញជាច្រើនលើក នូវបំណងរបស់ខ្មែរទាមទារខេត្តទាំងឡាយនៅកូសាំងស៊ីន ។ សមាជិកខ្មែរនៃក្រុមប្រឹក្សាសហព័ន្ធឥណ្ឌូចិន (Conseil fédéral Indochinois) ក៏បានបញ្ចេញបំណងទាមទារនេះដែរ ។

ម៉្យាងទៀត បើសិនជាគេពិនិត្យសន្ធិសញ្ញាឆ្នាំ១៨៨៤ ដាក់ប្រទេសកម្ពុជាក្រោមអាណាព្យាបាលបារាំង ដែលបណ្ដាលឲ្យប្រទេសកម្ពុជា «សង» (Aliéna) អធិបតេយ្យភាពខាងក្រៅរបស់ខ្លួន ជាផលប្រយោជន៍បារាំងអស់ទៅហើយនោះ គេនឹងយល់ថា ប្រទេសកម្ពុជាពុំអាចបញ្ចេញសេចក្ដីសំរេចចិត្តចូលកាន់កាប់ដីបាត់បង់ទាំងឡាយនៅកូសាំងស៊ីន ក្រៅពីសេចក្ដីស្នើការក្រៅផ្លូវការ និងដោយផ្ទាល់មាត់ទេ។

៥- <u>ការកំណត់ព្រំដែន</u> ៖

នៅមុនឆ្នាំ១៨៧០ ដែលជាកាលបរិច្ឆេទទីមួយនៃការកំណត់ព្រំដែន រវាងដែនដីកាន់កាប់ដោយប្រទេសបារាំងនិងប្រទេសកម្ពុជា វាពុំដែលមានការកំណត់ព្រំដែនរវាងដីកាន់កាប់ដោយប្រទេសអណ្ណាម និងព្រះរាជាណាចក្រកម្ពុជាឡើយ ។

៦- <u>មជ្ឈត្តការ</u> (៤) ៖

ពុំមានអន្តរាគមន៍ប្រទេសណាមួយបានចូលមកជួយដោះស្រាយមុខការអធិបតេយ្យភាពរបស់បារាំង នៅលើដែនដីកូសាំងស៊ីនឡើយ ក្រៅអំពីចំបាំងក្រៅប្រទេស (campagne d'expédition) បារាំង-អេស្ប៉ាញញ៉ុកឆ្នាំ១៨៥៨-១៨៦២ និងសន្ធិសញ្ញាចុះថ្ងៃទី៥មិថុនា១៨៦២ បន្ទាប់មកទៀតសន្ធិសញ្ញាចុះថ្ងៃទី១៥មិនា១៨៧៤ និងទី៣០មិថុនា១៨៩៤ ។

៧- <u>ប្រជាសិទ្ធិ</u> ៖

របៀបធ្វើប្រជាសិទ្ធិ (សុំសេចក្ដីសំរេចពីប្រជារាស្ត្រ) ត្រូវអនុវត្តជាលើកដំបូងនៅប្រទេសបារាំង ក្នុងសម័យបដិវត្តន៍បារាំង (ក្នុងករណីបញ្ចូលជាឧបសម្ព័ន្ធនូវដីអាវីញ៉ុង និង«កុមបាតឺ»វ៉ឺណេសហ្សាំង ឆ្នាំ១៧៩១) ។ ការធ្វើប្រជាសិទ្ធិនេះ តម្រូវឲ្យមានគោលការណ៍អធិបតេយ្យរបស់រាស្ត្រជាមុនសិន ។ ករណីនេះពុំអាចយកមកអនុវត្តនៅក្នុងទ្វីបអាស៊ីរបស់យើង ដែលធ្វន់ទៅដោយរបបផ្ដាច់ការនោះបានឡើយ ។

---

(៤) *មជ្ឈត្តការ* Arbitrage *សូមពិគ្រោះជាមួយអ្នកយុទ្ធសាស្ត្រផង៍ចុះ ។*

ការនេះបានសេចក្តីថា ខ្មែរពេលនោះដែលមានភាគច្រើនលើសលុបត្រូវគេហៅឲ្យសំរេចការជ្រើសរើសរបស់ខ្លួននូវប្រទេសឯណាមួយដែលខ្លួនពេញចិត្តចំណុះនោះសោះឡើយ ។

តែទោះបីជាយ៉ាងណាក៏ដោយ ក៏គេមិនត្រូវភ្លេចកត់ចំណាំថា នៅគ្រប់តែកាលសម័យដែលយួនបញ្ចូលជាឧបសម្ព័ន្ធ នូវខេត្តទាំងឡាយនៅកូសាំងស៊ីនខ្មែរ រាស្ត្រខ្មែរតែងតែបះបោរឡើងប្រឆាំងទល់នឹងការដណ្តើមយកដោយកម្លាំងបាយ និងការគ្របសង្កត់នៃពួកអណ្ណាមជានិច្ច ។ ក្នុងរឿងនេះ គេគ្រាន់តែអានទំព័រខ្លះនៃប្រវត្តិសាស្ត្រ ក៏គ្រប់គ្រាន់ល្មមដឹងណាស់ទៅហើយ ។

«ឥឡូវនេះទៀត យើងត្រូវតែរំលឹកថា ខ្មែរនៅកូសាំងស៊ីន (កម្ពុជាក្រោម) ថ្វីបើខ្លួនមានចំនួនតិចជាងយួនក្តី ក៏ឥតទាន់លែងទាមទារឲ្យចោរប្លន់នេះ ប្រគល់ដីនោះ (កូសាំងស៊ីន ទៅឲ្យមាតុប្រទេសរបស់ខ្លួន (កម្ពុជា) ឡើយ» ។

កត្តាចំនួនច្រើនលើសគេ (Supériorité numérique) ពុំអាចយកមកនិយាយបានទេ តាមផ្លូវច្បាប់ ដើម្បីនឹងចង្អុលថា មនុស្សច្រើននោះជាម្ចាស់រដ្ឋ ហើយមានអធិបតេយ្យភាពលើដីនោះ បើពុំនោះទេយើងត្រូវតែសន្និដ្ឋានថា ស្រុកលើកដែក (ខេត្តកណ្តាល) និងពាមជរ (ខេត្តព្រៃវែង) ជាស្រុករបស់យួន ពីព្រោះនៅក្នុងស្រុកទាំង២នោះ យួនមានចំនួនច្រើនជាងខ្មែរ ។

«សិទ្ធិអធិបតេយ្យភាពនៃយួនអណ្ណាម លើដីកូសាំងស៊ីនរបស់ខ្មែរសព្វថ្ងៃ ដែលជាផលនៃវត្តមានរបស់យួនលើដីកូសាំងស៊ីន គឺជាសិទ្ធិអថាវរៈ ដែលអាចដកយកវិញបាន និងអាចតវ៉ាបាន កិច្ចផ្លូវទូតទាំងឡាយធ្វើឡើងជាមួយប្រទេសបារាំង ដើម្បីទទួលស្គាល់ដីនោះ (កូសាំងស៊ីនឬកម្ពុជាក្រោម) ថាជាដីរបស់បារាំងសុទ្ធតែប្រឡាក់ទៅដោយអនិត្យានុកូលភាពទាំងស្រុង» ។

ការកាន់កាប់របស់បារាំងនូវដីកូសាំងស៊ីនបច្ចុប្បន្ន (កម្ពុជាក្រោម) ត្រូវបានធ្វើឡើងជាពីរដំណាក់ការ ។

<u>ដំណាក់ការទី១</u>- ធ្វើឡើងដោយសង្គ្រាមដណ្តើមដ៏ពិតប្រាកដមួយ អនុវត្តសមដៃគ្នាជាមួយប្រទេសអេស្ប៉ាញ នៅចន្លោះឆ្នាំ១៨៥៨ទៅ១៨៦២ គឺសង្គ្រាមដែលបានរំលត់អំណាចសច្ចាប័នរបស់ស្តេចអណ្ណាម លើសញ្ញាសន្តិភាព ចុះថ្ងៃទី៥មិថុនា១៨៦២ ស៊ីញ៉េជាមួយប្រទេសបារាំងនិងប្រទេសអេស្ប៉ាញម្ខាង ហើយនិងប្រទេសអណ្ណាមម្ខាងទៀត ។ មាត្រី៣នៃសន្ធិសញ្ញានេះបានបញ្ជាក់ថា ៖

«ខេត្តបៀងហ្វា យ៉ាឌិន និងឌិនទួង (មីថរ) ទាំងមូល ព្រមទាំងកោះពូឡូកុងឌ័រ ត្រូវប្រគល់តាមសន្ធិសញ្ញានេះ ដោយចេញអធិបតេយ្យ ទៅឲ្យព្រះចៅអធិរាជបារាំង» ។

ដំណាក់ការទី២- ដោយការកាន់កាប់ខេត្តវិញឡុង ចូដុក និងហាទៀង នៅខែមិថុនា១៨៦៧ ។

គួរកត់សំគាល់ថា ការកាន់កាប់នេះបានប្រព្រឹត្តឡើងក្រោយសន្ធិសញ្ញាអាណាព្យាបាល ស្តីពីប្រទេសកម្ពុជាឆ្នាំ១៨៦៣ ។

ការកាន់កាប់ដោយបារាំងនូវខេត្តមុំទាំងបីនោះ ហាប់ទើបនឹងបានត្រូវប្រទេសអណ្ណាមទទួលស្គាល់ ក្នុងរយៈពេល៧ឆ្នាំក្រោយមក គឺក្រោយពីបានចុះហត្ថលេខាលើសន្ធិសញ្ញាចុះថ្ងៃ១៥មិនា១៨៧៤ ។

មាត្រា៥នៃសន្ធិសញ្ញាបានសំដែងថា ៖ «ព្រះបាទសម្តេចប្រទេសអណ្ណាមទទួលស្គាល់ទាំងស្រុងនិងពេញទី អធិបតេយ្យរបស់ប្រទេសបារាំង លើដីដែលព្រះអង្គកាន់កាប់សព្វថ្ងៃ ហើយដែលតាំងនៅចន្លោះព្រំដែនដូចតទៅ ៖

★ ខាងកើតទល់នឹងសមុទ្រចិន និងរាជាណាចក្រអណ្ណាម ។

★ ខាងលិចទល់នឹងសមុទ្រសៀម ។

★ ខាងត្បូងទល់នឹងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រអណ្ណាម »

ប៉ុន្តែព្រំដែនប្រទេសកម្ពុជានិងកូសាំងស៊ីន (កម្ពុជាក្រោម) សព្វថ្ងៃនេះ ត្រូវបានគេគូសកំណត់ជាស្រេចនៅឆ្នាំ១៨៧០ និងឆ្នាំ១៨៧៣ ក្នុងវិសាលភាពទាំងមូលរបស់ខ្លួនតែម្តង (សេចក្តីសំរេចចុះថ្ងៃទី៩កក្កដា១៨៧០ និងការសំរុះសំរួមចុះថ្ងៃទី១៧កក្កដា១៨៧០) ។ ក៏ប៉ុន្តែក្នុងព្រំដែននោះ គេឥតមាននិយាយអ្វីមួយម៉ាត់ទេ ពីរឿងកោះទាំងឡាយនៅក្នុងសមុទ្រចិននិងសមុទ្រសៀម ដូចជាកោះពូឡូកុងឌ័រ កោះត្រល់ (ភូកុក) ជាដើម...។

មាត្រា៣នៃសន្ធិសញ្ញាចុះថ្ងៃ៥មិថុនា១៨៦២ ស្តីពីការប្រគល់សិទ្ធិរបស់អណ្ណាមលើខេត្តបៀងហ្វា និងមីថរទៅឲ្យបារាំង បានប្រឡាក់ដោយអនិត្យានុកូលភាពទាំងស្រុងដោយហេតុមោឃៈភាពនៃសិទ្ធិនោះ ។

ប៉ុន្តែសន្ធិសញ្ញាខាងលើនេះ ត្រូវជំនួសដោយសន្ធិសញ្ញាថ្ងៃ១៥មិនា១៨៧៤វិញ ដោយមាត្រា៥នៃសន្ធិសញ្ញានេះដៅចំពោះតែការទទួលស្គាល់តែមួយមុខគត់នូវអធិបតេយ្យបារាំងទៅលើកូសាំងស៊ីនបច្ចុប្បន្ន ។

ប្រទេសបារាំងអាចសំអាងភាពជាម្ចាស់កូសាំងស៊ីនត្រឹមតែដោយការច្បាំងដណ្តើមប៉ុណ្ណោះ តែពុំមែនដោយការប្រគល់សិទ្ធិនៃយួនអណ្ណាមទៅឲ្យខ្លួននោះទេ។

ដូច្នេះតាមផ្លូវច្បាប់ កូសាំងស៊ីនឬកម្ពុជាក្រោម នៅតែជាដីរបស់ខ្មែរជានិច្ច ។ សិទ្ធិអធិបតេយ្យរបស់ប្រទេសខ្មែរទៅលើដីផ្នែកនេះ គ្រាន់តែត្រូវគេផ្អាកប៉ុណ្ណោះ ពុំមែនត្រូវផុតអាជ្ញាយុកាល (Interrompu et non prescrit) ឡើយ ដោយសារតែការកាន់កាប់របស់ចៅហ្វាយរួមយួនអណ្ណាមនិងខ្មែរ គឺប្រទេសបារាំង ។

# ជំពូក៥

# ទល្ហិករណ៍រដ្ឋបាល

គ្រប់ទីកន្លែងដែលវាត្រួតត្រា ពួកយួនអណ្ណាមបានរៀបចំអង្គការរដ្ឋបាលទាំងឡាយ ទៅតាមរបៀបរបស់វា ដោយឥតខ្វល់នឹងរដ្ឋបាលខ្មែរ ដែលមានស្រេចហើយនោះសោះទេ ។ ពួកយួនបានរើសនាយចៅហ្វាយវាដោយខ្លួនវា និងក្នុងចំណោមពួកវា តែងតាំងមន្ត្រីទាំងឡាយឡើងទៅកាន់មេទ័ពរបស់វានៅក្រុងព្រៃនគរ តែងតាំងឲ្យធ្វើជាចៅហ្វាយខេត្ត អស់អ្នកឯណាដែលបំរើផលប្រយោជន៍របស់វា (ឧទាហរណ៍មានករណីចិនរត់ចោលស្រុកម្នាក់ឈ្មោះ ម៉ាក់គុយ ជាដើម) បំពាក់មេដាយ ឬឲ្យគោរមងារដល់មន្ត្រីខ្មែរទាំងឡាយ ដែលវាពុំអាចរើសជំនួសបានដោយជាតិរបស់វា ។

នៅអមព្រះរាជបល្ល័ង្កខ្មែរឯណោះវិញ រឿងរាល់តែអន្តរាគមន៍របស់វាមកលើស្រុកខ្មែរ ប្រកបដោយជោគជ័យ តាមពាក្យសុំរបស់ស្តេចខ្មែរ ឬស្តេចទាមទាររាជ្យ ស្តេចប្រទេសអណ្ណាមបានតែងតាំងទេសាភិបាលម្នាក់ របៀបជាអ្នកសង្កេតការណ៍ តែតាមពិតគឺជាអាណាព្យាបាលត្រួតត្រាខ្មែរតែម្តង (ឧទាហរណ៍តែងតាំង «ប៉ៅហូ Baoho» នៅឆ្នាំ១៧៧១ ក្នុងរជ្ជកាលព្រះអង្គនន់ព្រះរាម «អុងថុងជេ Ong Thong Che» នៅឆ្នាំ១៨៣៣ ក្នុងរជ្ជកាលព្រះអង្គច័ន្ទ ) ។

ដោយទុកដាក់ខ្លួនថាជាមេទ័ពសង្កេតការណ៍នៅស្រុកខ្មែរ យួនឈ្មោះទ្រឿងមិញយ៉ាង មេទ័ពដែលតែងតាំងឡើងដោយស្តេចអណ្ណាម «អម»ព្រះរាជបល្ល័ង្កខ្មែរ បានទាំងហ៊ានលើកម្ចាស់ក្សត្រីអង្គម៉ី ដែលជាព្រះរាជបុត្រីច្បងរបស់ព្រះបាទអង្គច័ន្ទ ឲ្យឡើងគ្រងរាជសម្បត្តិ រួចខ្លួនចាត់ចែងការជួសខ្មែរថែមទៀតផង ។

ប៉ុន្តែដីទាំងឡាយនេះ ទោះបីយួនបានតាំងទីនៅលើក្តី ក៏នៅតែស្ថិតក្រោមអំណាច និងសមត្ថកិច្ចរបស់ខ្មែរដែរ ។ មន្ត្រីទាំងឡាយដែលស្តេចអណ្ណាមបានតែងតាំងឲ្យត្រួតដីទាំងនោះ ពុំដែលអាចទៅជំនួសមន្ត្រីរបស់ខ្មែរបានឡើយ ។ ខ្មែរគ្រប់រូបឥតដែលព្រមទទួលស្គាល់ ឬទទួលព្រមឲ្យមន្ត្រីយួនទាំងនោះ ត្រួតត្រាខ្លួនសោះឡើយ ។ ការប្រយុទ្ធទាំងឡាយដែលខ្មែរដឹកនាំ និងធ្វើឡើងប្រឆាំងយួនជាអ្នករុករានខ្លួន ត្រូវផ្អាកក៏ព្រោះតែបារាំងចូលកាន់កាប់ដីរបស់ខ្លួនទាំងនោះតែប៉ុណ្ណោះ ។

នៅឆ្នាំ១៨៦៧ ក្នុងពេលខ្លួនកំចាត់ពួកយួនអណ្ណាមចេញពីដីនោះ ដើម្បីរំដោះពីកណ្ដាប់ដៃចោរយួន បារាំងបែរជាយកដីនោះធ្វើជាអាណានិគមរបស់ខ្លួនទៅវិញ ។ ប៉ុន្តែពេលនោះ បារាំងត្រឡប់ជាទុកមន្ត្រីយួនឲ្យកាន់កាប់ ទោះបីបារាំងដឹងថាយួនអនុវត្តទ្រឹស្តីអណ្ណាមតុងកឹង ដេញខ្មែរឲ្យចុះទៅលិចក្តី ។

ជាអំពើថោកទាបក្រៃលែងទៅទៀត គឺនៅពេលដែលខ្លួនកំហែងយកខ្មែរដាក់ក្រោមអាណាព្យាបាលទៅហើយ បារាំងបានយកដីខ្មែរដែលមិនទាន់ធ្លាក់ក្នុងកណ្ដាប់ដៃយួន ទៅបញ្ចូលក្នុងអាណានិគមកូសាំងស៊ីនថែមទៀត ដោយធ្វើឲ្យបាត់បង់ទឹកដីខ្មែរអស់យ៉ាងធំ ។

នៅក្រោមរដ្ឋការបារាំង ខ្មែរកម្ពុជាក្រោមហាក់ដូចជាទទួលសិទ្ធិទូលំទូលាយបន្តិច ។ ទោះបីបារាំងចង់បញ្ចូលដីនោះក្នុងអាណានិគមរបស់ខ្លួន ដោយឆាប់រហ័សយ៉ាងណាក្តី ក៏ប្រទេសបារាំងនៅរាប់អានខ្មែរស្មើយួនអណ្ណាមដែរគឺ ៖

១/ ខ្មែរមានបុគ្គលិកភាព លំនៅ និងទ្រព្យដែលទទួលការគោរពពីអ្នកដទៃ ។

២/ ខ្មែរមានសិទ្ធិទទួលលទ្ធកម្មនិងកម្មសិទ្ធិ (droit d'acquisition et de propriété) ដែលច្បាប់បញ្ញត្តិ ។

៣/ រដ្ឋបាលបង្កើតឡើង និងទទួលចំណាយសំរាប់តែខ្មែរទាំងនោះ ។ សាលារៀនដែលមានបង្រៀនជាភាសាខ្មែរ ហើយដោយគ្រូបង្រៀនសញ្ជាតិខ្មែរនោះ បានទទួលចំណាយពីថវិកាសាធារណៈ ។

៤/ រដ្ឋបាលនោះបានផ្តល់អាហារូបករណ៍ចំពោះសិស្សនិងនិស្សិតខ្មែរ សិក្សានៅទីរួមខេត្តនានា នៅក្រុងព្រៃនគរ ភ្នំពេញ ឬទីដទៃនានាផ្សេងទៀត ។

៥/ ខ្មែរអាចបង្កើតសមាគមដើម្បីការពារផលប្រយោជន៍របស់ខ្លួន ដើម្បីអភិវឌ្ឍន៍វប្បធម៌និងសុរុំឱ្យកម្មជីវភាពរបស់ខ្លួន ។

៦/ ខ្មែរអាចប្រើភាសាខ្មែរជាទូទៅនិងគ្រប់កាលៈទេសៈ ទោះបីនៅក្នុងការទាក់ទងជាអាជ្ញាធរក្តី ហើយអាជ្ញាធរនេះទៀតក៏បានប្រើភាសាខ្មែរ ឬជួលអ្នកបកប្រែខ្មែរ ក្នុងការទាក់ទងជាមួយរាស្ត្រខ្មែរ ។

៧/ ខ្មែរអាចធ្វើចរាចរដោយសេរី ទៅមករវាងកម្ពុជានិងកូសាំងស៊ីន ។

៨/ ខ្មែរមានសេរីភាពខាងធ្វើពាណិជ្ជកម្មនិងសហគ្រាស ដោយមានសិទ្ធិទទួលអាជ្ញាប័ណ្ណនិងសេចក្តីអនុញ្ញាតផ្សេងៗ ។

៩/ មានសិទ្ធិចូលព្យាបាលក្នុងមន្ទីរពេទ្យសាធារណៈដោយឥតបង់ថ្លៃ ។

១០/ អាចប្រារព្ធធ្វើពិធីគ្រប់យ៉ាងដោយសេរី តាមប្រពៃណីរបស់ខ្លួន ហើយមានសិទ្ធិឈប់សំរាកក្នុងឱកាសបុណ្យជាតិ ដោយទទួលប្រាក់បំណាច់ ដូចជាបុណ្យមាឃបូជា វិសាខបូជា ចូលឆ្នាំ ភ្ជុំបិណ្ឌ អកអំបុក ។ល។

១១/ អាចគោរពដោយសេរីនូវជំនឿសាសនា ទំលាប់ និងទំនៀមរបស់ផងខ្លួន

១២/ អាចសាងផ្នួសនិងលាចាកសិក្ខាបទតាមពុទ្ធប្បញ្ញត្តិ ។

១៣/ មានសេរីភាពបង្រៀនសាសនាខ្មែរ ជាភាសាខ្មែរ ។

១៤/ ព្រះសង្ឃខ្មែរអាចរៀបចំអង្គការសាសនាតាមព្រះទ័យព្រះអង្គ ហើយបង្កើតស្ថាប័ននានាដែលព្រះអង្គយល់ថាមានប្រយោជន៍ ។

១៥/ ព្រះសង្ឃនិងអ្នកកាន់ព្រះពុទ្ធសាសនាខ្មែរ មានសិទ្ធិបង្ខំឲ្យគេគោរពខ្លួន

១៦/ ពុំមាននរណាមួយអាចចាប់ហើយឃុំឃាំងព្រះសង្ឃបានឡើយ ។

១៧/ អាជ្ញាធរស៊ីវិលក្តី យោធាក្តី ពុំអាចផ្សឹកព្រះសង្ឃបានឡើយ ។

⌘

⌘ ⌘

# ជំពូក៦

# ឧក្រិដ្ឋកម្មផ្ដែកជាតិពូជ

«ដោយបំពេញចំណង់ដណ្ដើមដី ពួកយួនអណ្ណាមបានជ្រៀតចូលទៅក្នុងប្រទេសកម្ពុជា ដែលជាប់នឹងព្រំដែនរបស់ខ្លួន ជាពិសេសតាំងទីនៅក្នុងតំបន់បារៀ និងបៀងហ្វា ជាក្រុមតូចៗ របៀបដូចជាអ្នកនាំមុខរបស់ជាតិឈ្លានពានដូច្នោះ...

«បើនិយាយទៅតាមផ្លូវចិត្តសាស្ត្រ ពួកអ្នកដើរចោលស្រុកទាំងនោះ ពុំមែនជាមនុស្សគួរឲ្យរាប់អានទេ ប៉ុន្តែភាគច្រើនជាពួកចោរប្លន់ ឆក់កណ្ដៀត តែនាំមកជាមួយនូវគុណសម្បត្តិម៉្យាង ពីដូនតារបស់វា គឺពុតនិងភាពស៊ូ» ។

«ដោយធន់នឹងការគាបសង្កត់ជាលំដាប់នៃពួកយួនចោរហាមេយ្យំទាំងនោះ ដែលជាជនថោកទាបរបស់ប្រទេសអណ្ណាម តែត្រឡប់ទៅជាកុលសម្ព័ន្ធនៅប្រទេសកម្ពុជា ដោយរក្សាឋានៈជារាស្ត្រស្ដេចក្រុងវើពុំបាន ពួកខ្មែរនៅនគរបារៀ និងដូនណាយក្រោម ត្រូវបង្ខំចិត្តរត់ចោលដីទាំងនោះ រួចត្រូវយួនអណ្ណាមយកទៅធ្វើជាដីខ្លួនជាលំដាប់» ។

នៅក្នុងរជ្ជកាលរបស់ក្សត្រីយានីអង្គម៉ី (១៨៣៥-១៨៤១) ទេសាភិបាលអណ្ណាមអមព្រះរាជបល្ល័ង្កខ្មែរ បានបង្ខំមន្ត្រីខ្មែរឲ្យស្លៀកពាក់តាមយួន បួងសក់ដូចយួនដែរ ។ វាបានដូរឈ្មោះតំបន់នានាកែប្រែខេត្តខ្មែរឲ្យហៅជាឈ្មោះយួនវិញ ។ ទ្រឿង-មិញយ៉ាង ទេសាភិបាលយួនអណ្ណាមអមព្រះរាជបល្ល័ង្កក្សត្រីយានីអង្គម៉ី បានរិះរកមធ្យោបាយបំបាត់បុណ្យប្រពៃណីខ្មែរ ដោយយកបុណ្យប្រពៃណីយួនមកជំនួសវិញ បង្ខំព្រះសង្ឃខ្មែរឲ្យនិមន្តចេញពីវត្ត រួចវាបញ្ជាឲ្យវាយបំបាក់ព្រះពុទ្ធរូបជាសក្ការៈរបស់ខ្មែរ ។

នាសម័យដែលសៀមនិងយួនយល់ព្រមព្រះអភិសេកព្រះអង្គឌួង ជាក្សត្រប្រទេសកម្ពុជា ដោយវាច្បាំងគ្នាមិនឈ្នះមិនចាញ់ ប្រជារាស្ត្រខ្មែរក៏រឹតតែរស់នៅលំបាកក្រៃលែងណាស់ទៅទៀត ។ ដោយត្រូវចោរលួចប្លន់ កាប់សម្លាប់ ខ្មែរត្រូវរត់ចោលភូមិលំនៅ ចូលទៅជ្រកពួន គេចពីការលុកលុយរបស់ពួកសៀមក្នុងរដូវប្រាំង លុះដល់រដូវវស្សា ត្រូវរងគ្រោះនឹងការប្លន់នៃនាវាយួនទៀតក្នុងពេលរាត្រី។ ពួកសៀមដើររកចាប់ខ្មែរធ្វើទាសកម្មកររបស់វា ហើយកៀរអ្នកស្រុកខ្មែរឲ្យទៅកាប់គាស់ដីឲ្យវា នៅក្នុងតំបន់ទន្លេមេណាម ។ រីចំណែកឯពួកយួនបានដេញបំបរខ្មែរ

ឬសម្លាប់រង្គាលជនទាំងនេះ ដើម្បីលួចដី ។

នៅប៉ែកខាងត្បូងប្រទេស ខ្មែរមួយក្រុមធំបានចាកចោលភូមិដ្ឋានរបស់ខ្លួន ដោយខ្មែរមានការឆ្មើងឆ្មៃយ៉ាងខ្ពង់ខ្ពស់ម៉្យាង គឺមិនឲ្យយួនត្រួតត្រា ។ ការនេះជាឱកាសល្អបំផុតសំរាប់ឲ្យយួនយកវាស្រុករបស់វាទៅកាន់កាប់ដីដែលខ្មែររត់ចោលនោះ ។

ទោះបីមកដល់ពេលខ្មែរឋិតក្រោមអាណាព្យាបាលរបស់បារាំងហើយក្តី ក៏ពួកយួនស្រេកឃ្លានខាងលួចប្លន់នោះ នៅតែឆ្លៀតដណ្តើមដីខ្មែរ ដោយឧបាយបំបាត់ពូជខ្មែរ ដកហូតទ្រព្យនិងដីខ្មែរទៀត ដើម្បីឲ្យខ្មែរវិនាស វានឹងយកជាតិរបស់វាមកជំនួស ។

មកដល់ចុងបញ្ចប់ ខ្មែរនៅសល់ត្រង់តែតំបន់ខាងលិចទន្លេបាសាក់ (Fleuve antérieur) តែប៉ុណ្ណោះ គឺក្នុងខេត្តបាក់លីវ រ៉ាចយ៉ា ហាទៀង ចូដុក ឡុងសៀង វិញឡុង កន់ថឺ សុកទ្រាំង ត្រាវិញ និងខេត្តតាយនិញនៃកូសាំងស៊ីនប៉ុណ្ណោះ (១) ។

ក្នុងឋានៈជាពលរដ្ឋបារាំង ខ្មែរកម្ពុជាក្រោមអាចផ្តើមរស់នៅតាមជីវភាពខ្លួនបាន អាចប្រើប្រាស់អារ្យធម៌របស់ខ្លួនដែលមានរាប់ពាន់ឆ្នាំមកហើយបាន ជាពិសេ-សពង្រីកបុគ្គលិកភាពរឹងប៉ឹងរបស់ខ្លួន រហូតដល់សម័យជប៉ុនចូលកាន់កាប់ (១៩៤១-១៩៤៥) សង្គ្រាមឥណ្ឌូចិនទី១ (១៩៤៥-១៩៥៤) ផ្ទេរកូសាំងស៊ីនទៅឲ្យយួន

ព្រឹត្តិការណ៍ខាងលើនេះ ទំលាក់ទម្ងន់ទៅលើខ្មែរនៅកូសាំងស៊ីនធ្ងន់បំផុតដោយហេតុពួកយួនសំរេចតាំងពីដូនតាវាថានឹងបំបាត់ពូជខ្មែរឲ្យអស់ពីដីនោះ ។ មិនថាវាជាអ្នកផ្អៀងទៅខាងជប៉ុន មិនថាវាជាអ្នកផ្អៀងទៅខាងបារាំង មិនថាវាជាវៀតមិញ ឬមិនវៀតមិញ មិនថាវាជាវៀតកុង ឬអ្នកជាតិនិយម យួនទាំងអស់សុទ្ធតែឆ្លៀតឱកាសដណ្តើមដីខ្មែរ បំបាត់ពូជខ្មែរ ដកហូតទ្រព្យនិងដីខ្មែរ សម្លាប់ខ្មែរ លុបបំបាត់ស្នាមតឹកតាងតាំងឡាយរបស់ខ្មែរ ៖ បំផ្លាញវត្ត ផ្លាស់ឈ្មោះមនុស្ស និងឈ្មោះតំបន់ ស្រុក ខេត្តនានា ហាមមិនឲ្យខ្មែរប្រើភាសាខ្មែរ ។ល។

ថ្វីបើមានសកម្មភាពដេញកំចាត់បញ្ចូលជាតិយ៉ាងនេះ និងមានឃាតកម្មឧក្រិដ្ឋកម្មលើខ្លួនក្តី ក៏ខ្មែរកម្ពុជាក្រោមមានចំនួនបួនលានកន្លះនៅឡើយដែរ គឺមានព្រះសង្ឃ មន្ត្រី ទាហាន អ្នកជំនួញ កសិករ រស់នៅរាយប៉ាយពេញយៀកណាមខាងត្បូងបច្ចុប្បន្ន ។

ភាពជាអ្នកសិល្បៈពីកំណើត ជាអ្នកចំបាំងអង់អាចដែលខ្លាំងនិងប្រកបដោយទេពកោសល្យដូចដូនតាខ្លួន ជាអ្នកកសាងអង្គរ ជាមនុស្សល្អទៀងត្រង់ ពួកខ្មែរ

---

*(១) សូមកត់សំគាល់ថា ឈ្មោះទាំងនេះគឺជាឈ្មោះភាសាយួនដែលយួនប្រែ ហើយឲ្យហៅជាជំនួសឈ្មោះខេត្តខ្មែរនៅកូសាំងស៊ីន ។*

ទាំងនោះបានរក្សាលក្ខណៈជាតិរបស់ខ្លួនឲ្យនៅតែល្អដដែល ឥតឲ្យយួនប៉ះប្រឡាក់បានឡើយ ដូចជាភាសា ទំនៀមទំលាប់ សាសនា ពិធីបុណ្យ អក្សរ ដែលខុសស្រឡះពីយួន ។

បណ្ដាខ្មែរទាំងនោះ ភាគច្រើនៗតែជាកសិករ ដែលបន្តធ្វើអាជីវកម្មលើដីដូនតារបស់ខ្លួន ក្នុងខេត្តទាំងឡាយដែលយួនឲ្យហៅជាភាសាយួនសព្វថ្ងៃថាខេត្តអានសៀង បាក់លីវ ជួងធៀន កៀងយ៉ាង ចូដុក អានយ៉ាង វិញឡុង ភុងឌិន បាសៀង វិញបិញ និង តាយនិញ ។

ឈ្មោះតំបន់ទីកន្លែងនានា និងមណ្ឌលដីភូមិសាស្ត្រក៏សុទ្ធតែជាឈ្មោះរបស់ខ្មែរដែរ ។ បើយោលទៅតាមធនធានធម្មជាតិ ឬភិនភាគទេសភាព ឈ្មោះទាំងនោះមានន័យជ្រៅល្អណាស់ ។ ឈ្មោះមណ្ឌលខ្លះ ដូចយ៉ាងខេត្តថ្មីៗដែលយួនយកឈ្មោះជាភាសាយួនឲ្យហៅជំនួស ជាពិសេសឲ្យសរសេរក្នុងផ្លូវការ តាមភាសាយួនឬបារាំងនោះ សុទ្ធតែជាពាក្យដែលបញ្ចេញគំនិតបួងសួង សុំឲ្យមានការរីកចំរើន សុភមង្គល ឬភោគទ្រព្យតាមស័ព្ទនិយមនៃពួកចិនកាត់យួន ។ ឈ្មោះមណ្ឌលតំបន់ឬខេត្តខ្លះទៀត ត្រូវយួនបកប្រែទៅជាភាសាយួន ដើម្បីប្រើក្នុងផ្លូវរដ្ឋបាលដូចជា ៖

| | | |
|---|---|---|
| កំពង់ឫស្សី | យួនបកប្រែថា | បិនត្រេ |
| កំពង់ក្របី | | បែនញ៉ៅ |
| ឈើទាល១ដើម | | ធុយដូម៉ូក |
| ព្រៃនគរ | | សៃហ្គង ។ល។ និង ។ល |

ឈ្មោះខ្លះទៀតត្រូវយួនកែប្រែឲ្យទៅតាមសូរសៀងយួនដូចជា ៖

| | |
|---|---|
| ផ្សារដែក | សាដែក |
| ស្រុកទ្រាំង | សុកត្រាំង ឬសុកទ្រាំង |
| ទឹកខ្មៅ | កាម៉ៅ |
| មេ-ស | មីថវ |
| ពៃះត្រពាំង | ត្រាវ៉ាំង (រួច) ត្រាវិញ ។ល។ និង ។ល។ |

ភូមិខ្មែរនាំឲ្យគេសម្គាល់បានភ្លាមៗ ជាពិសេសបើគេធ្វើដំណើរតាមយន្តហោះដោយក្នុងភូមិនោះតែងមានវត្តជានិច្ច ដែលមានទ្រង់ទ្រាយដាច់ដោយឡែក ហើយដូចគ្នាបេះបិទទៅនឹងវត្តទាំងឡាយនៅនាកម្ពុជា (កណ្ដាល) យើងនេះ ។ ថ្វីបើពួកយួនដុតបំផ្លាញឬវាយប្រហារកំទេចយ៉ាងណាក្ដី (ក៏មកទល់ឆ្នាំ១៩៦៥) វត្តខ្មែរនៅកម្ពុជាក្រោមមានចំនួនលើសពី៥០០ដែរ ហើយបណ្ដាវត្តខ្លះមានលំអក្រៃលែងទៀតផង ។ ខ្មែរកម្ពុជាក្រោមគោរពពុទ្ធសាសនាហិនយាន ដែលត្រូវតាមពុទ្ធសា-

សនាលទ្ធិដើមរបស់ព្រះពុទ្ធជាបរមគ្រូ ដោយប្រើភាសាបាលីជាភាសាសក្ការៈ ក៏រីឯយួនវិញគោរពលទ្ធិពុទ្ធសាសនាទីបេ (ដែលរាស្ត្រមុងហ្គោលលីនិងចិនគោរព) សំរាប់យួនណាដែលមិនគោរពសាសនាកាតូលិក កៅដាយ ឬហូហ្វាទេនោះ ។

ចំពោះពួកយួននិយមបួងសក់វ័ណ្ណឈ្នួត ស្លៀកខោជើងវែងនិងពាក់អាវផាយ ក៏ចំណែកឯខ្មែរវិញ និយមទុកសក់ខ្លី និងស្លៀកពាក់សំលៀកបំពាក់របស់ជាតិខ្លួន ទៅតាមភេទនិងលំដាប់គឺ ៖ សំពត់សូត្រពណ៌តែមួយសំរាប់បុរស ហើយចំរុះព-ណ៌សំរាប់ស្ត្រី អាចក្តោបសាច់ (តឹងក្លំ) ក៏មានកត្រង់ មានឡេវធ្វើអំពីលោហធាតុ ឬកែវចំរុះពណ៌សំរាប់បុរស និង«អាវបំពង់វែង»សំរាប់ស្ត្រី ដែលជាប្រភេទអាចចង្អៀតក្លំម៉្យាង រិតត្រង់ចង្កេះនិងកដៃ ដោយមានករៀលជារាងព្រះច័ន្ទពេញបូណ៌មីបញ្ចេញសាច់ក ។

របៀបបួងសក់និងស្លៀកពាក់ខោអាវយួន ត្រូវយួនបង្ខំឲ្យខ្មែរអនុវត្តច្រើនលើកច្រើនគ្រាណាស់ ទាល់តែធ្វើឲ្យឥទ្ធិពលនេះជ្រួតជ្រាបទៅក្នុងតំបន់ខ្លះ ប៉ុន្តែមិនមែនមានន័យថា ខ្មែរទទួលឬនិយមជាស្ថាពរនោះឡើយ ។

នៅក្រោមអាណាព្យាបាលរបស់បារាំង យួនអណ្ណាមនិងខ្មែរកូសាំងស៊ីនដើរឆ្ពោះទៅរកសភាពដូចគ្នាខាងក្រៅខ្លះទៅហើយ ដោយហេតុថាខ្លួនជាពលរដ្ឋបារាំងដូចគ្នា ។ ក៏ប៉ុន្តែ ក្រោយពីប្រទេសទាំងឡាយនៅអតីតឥណ្ឌូចិនបានឯករាជ្យ ពួកខ្មែរបានវិលត្រឡប់ទៅរកលក្ខណៈពិសេសដោយឡែករបស់ខ្លួនវិញ ក្នុងឋានៈជាប្រជាជាតិមានអារ្យធម៌និងជាម្ចាស់ដី ដែលជាហេតុមួយនាំឲ្យយួនបន្ត ហើយរឹតតែសង្កត់ពួនឃោបាយសម្លាប់រង្គាលខ្មែរខ្លាំងឡើងៗ ហើយថែមទាំងរើរៀបចំដីជាថ្មី ប្តូរឈ្មោះខេត្តនិងទីប្រជុំជន ទីក្រុង បង្ខំឲ្យប្រើភាសាយួនជាដើម ។

⌘

⌘ ⌘




ដំណើរសម្រុកចុះមកទិសខាងត្បូង
១១១ មុនគ.ស. មក ១៨៤០
តើយួនសម្រុកទៅទិសណាទៀត?

# ផ្នែកទី២

# ការតស៊ូតវល់
# នឹងសង្គ្រាមឈ្លានពានសម័យថ្មី

# ជំពូក២
# សង្គ្រាមឥណ្ឌូចិន-សង្គ្រាមខាងជើ

នៅរាត្រីទី៩មិនា១៩៤៥ ពួកជប៉ុនបានវាយប្រហារបន្ទាយបារាំងដែលមានសភាពរខេករខាក កំព្រឹកកំព្រួកស្រេចទៅហើយនោះ នៅអតីតឥណ្ឌូចិន ហើយជប៉ុនបានលុបអំណាចអាណានិគមបារាំងនៅទីនោះ តែក្នុងរយៈពេលមួយប៉ប្រិចភ្នែកប៉ុណ្ណោះ គឺអំណាចត្រួតត្រាប្រទេសតុងកឹង (យួនខាងជើងបច្ចុប្បន្ន) អណ្ណាម (អតីតនគរចំប៉ា) និងកូសាំងស៊ីន (កម្ពុជាក្រោមបច្ចុប្បន្ន) ។

ការវាយប្រហារនេះ គឺជាការចាប់ផ្តើមនៃសង្គ្រាមឥណ្ឌូចិនដ៏ពិតប្រាកដមួយ។ សង្គ្រាមនេះបានធ្វើឲ្យរបបអធិរាជនៅយួនរលំរលាយ បង្កើតឡើងនូវរបបសង្គមនិយមមួយ គឺសាធារណរដ្ឋប្រជាធិបតេយ្យយៀកណាម ដឹកនាំដោយហូ-ជីមិញ, ផាំ-យ៉ាងដុង ដែលជាប្រធានាធិបតី និងនាយករដ្ឋាភិបាល ព្រមទាំងយ៉-ង្វៀងយ៉ាប មេទាហានទ័ពព្រៃ (យៀកមិញ) ។ គឺនៅក្នុងសំណាញ់អធិរាជបៅដាយនោះហើយ ដែលនាំឲ្យអាណាចក្រទី២ (Second Empire) និងសាធារណរដ្ឋទី៣ (IIIè République) របស់បារាំងរហែកធ្លុះធ្លាយ ។

អ្នកដឹកនាំបារាំងបានខិតខំប៉ះប៉ុនរង្វះរហែកនេះ ប៉ុន្តែនាពេលដែលអ្នកប៉ះប៉ុនខិតខំប៉ះណាស់ វាត្រឡប់ជាបានផលបដិលោមទៅវិញ គឺហាក់ដូចជាខិតខំហូតសរសៃសូត្រពីសំណាញ់នោះរឹតតែខ្លាំងណាស់ទៅវិញ ។ គារណ៍នេះបណ្តាលឲ្យប្រទេសបារាំងអស់កម្លាំងនយោបាយនិងចិត្តសាស្ត្រទៅហើយនេះម៉្យាង ម៉្យាងទៀតដោយសារការងើបឡើងនៃប្រជាជនត្រូវគេជិះជាន់ដើម្បីឯករាជ្យ បានទទួលលក្ខណៈជាចលនាទប់មិនឈ្នះ ដែលជាផលនៃការវិវត្តន៍នៃប្រវត្តិសាស្ត្រ ។

បរាជ័យរបស់បារាំងនៅឥណ្ឌូចិន គឺជា(ថ្មសីមា)នៃការរលំសាបសូន្យរបស់អាណាចក្របារាំង ។ បរាជ័យបារាំង គឺជាឡូរំលាយឬកន្លែងពិសោធន៍ខាងកងទ័ពខាងចំបាំងថ្មី ជាពិសេសគឺការបញ្ចេញចំបាំងទ័ពព្រៃ ដែលធ្វើឲ្យទ្រឹស្តីនៃចំបាំងចាស់តាមរបៀបទ័ពរៀបរយ ទ្រឹស្តីចេញពីសាលា ទៅជាឥតប្រយោជន៍ «ចាស់ហួសស

ម័យ» ។

បរាជ័យរបស់បារាំង «យក្សជើងដីឥដ្ឋ» បាននាំឲ្យមានការពន្យា «សង្គ្រាមអាមេរិកាំង» ដែលទើបនឹងចូលខ្លួនទៅក្នុងបច្ចុប្បន្នភាព គឺសង្គ្រាមដែលបារាំងដឹកនាំក្នុងល្បិច ធ្វើឲ្យឯករាជ្យឥណ្ឌូចិនអាចសំរេចបានជាគុណាប្រយោជន៍ដល់ពិភពលោកសេរី ។

គឺនៅក្នុងបរិបទ (Contexte) ខាងលើនេះឯង ដែលអ្នកនយោបាយអ្នកដឹកនាំប្រទេសនានា យល់ចំពោះសង្គ្រាមឥណ្ឌូចិន ។ ប៉ុន្តែចំពោះយើង យើងយល់ថាការយល់បែបនេះ វាដូចជាខ្លួសហួសការពិតពេកណាស់ ហើយពួកស្បែកសដូចជាពុំទាន់មានសម្បទានធួនល្មមនឹងយល់ការរាក់ៗ រឿងរបស់ជនជាតិដែលខ្លួនថា «ស្បែកលឿង» ឬ «ជនជាតិពណ៌សម្បុរ» នៅឡើយទេ ។ ពីព្រោះសំរាប់យួនសង្គ្រាមឥណ្ឌូចិន គឺជាសង្គ្រាមវាតដីក្នុងទំរង់ថ្មីមួយ ស្របទៅតាមការវិវត្តន៍នៃន-យោបាយសម័យ គឺសង្គ្រាមដែលទាំងកុម្មុយនិស្ត ទាំងលោកសេរីសុទ្ធតែចាញ់បោកយួន បំរើមូលហេតុចោរឧក្រិដ្ឋរបស់យួន ។

កញ្ញា លោកស្រី លោក និងមិត្តអ្នកអាន នឹងឈប់សង្ស័យភ្លាម កាលណាខ្ញុំយកសេចក្តីថ្លែងការណ៍របស់លោកង្វៀង-កុកឌិន ប្រធានគណៈប្រតិភូយួនខាងត្បូង ក្នុងសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ដែលបានថ្លែងបញ្ជាក់អំពីមូលហេតុពិតរបស់យួន ក្នុងការបង្កើតនូវចលនា (យៀកមិញ) និងសង្គ្រាមដែលជនជាតិនេះធ្វើ ។ ប៉ុន្តែមុននឹងចូលទៅក្នុងវគ្គនេះ ខ្ញុំសូមអនុញ្ញាតពណ៌នារបស់ដែលហៅថា «ប្រទេសឥណ្ឌូចិន»សិន ។

⌘

⌘ ⌘

# វគ្គទី១

# ឥណ្ឌូចិន

ឥណ្ឌូចិន គឺជា«សហព័ន្ធ»មួយ ដែលឋិតនៅក្រោមអំណាចអគ្គទេសាភិបាល (Gouverneur Général)ម្នាក់ ទទួលខុសត្រូវចំពោះរដ្ឋមន្ត្រីខាងអាណានិគមនៅប៉ារីស ។ នៅឆ្នាំ១៩៤៥ (មុនសង្គ្រាមឥណ្ឌូចិន) សហព័ន្ធឥណ្ឌូចិនចែកចេញជាដែនដី៥ ដែលសុទ្ធតែមានលក្ខន្តិកៈនយោបាយផ្សេងៗពីគ្នាគឺ ៖ កូសាំងស៊ីន, ប្រទេសអណ្ណាម, ប្រទេសតុងកឹង, ប្រទេសកម្ពុជា និងប្រទេសលាវ គឺថា «ប្រទេសយួនអណ្ណាម»បី និង«ប្រទេសកាត់ឥណ្ឌា»ពីរ ។ ឥណ្ឌូចិនមានទំហំរួម ៧៣៧,០០០គីឡូម៉ែត្រក្រឡា និងមានប្រជាជនរស់នៅចំនួន២៥លាននាក់ (កាលនៅឆ្នាំ១៩៤៥)។

# កូសាំងស៊ីន

កូសាំងស៊ីន គឺជារដ្ឋឥណ្ឌូចិនមួយដែលមានផ្ទៃតូចជាងគេ ៦៥,០០០ គីឡូម៉ែត្រក្រឡា ។ ប្រទេសនេះត្រូវរដ្ឋការបារាំងនៃអធិរាជណាប៉ូឡេអុងទី៣ ដណ្ដើមជាក់ជាចំណុះនៅឆ្នាំ១៨៦៤ ។

កូសាំងស៊ីនជាប្រទេសមួយសំបូរធនធាន និងភោគទ្រព្យធម្មជាតិជាងគេ ដោយសារប្រទេសនេះសន្ទឹងតាមដងទន្លេមេគង្គ ដែលជាវាលល្បប់សំខាន់សំរាប់ដំណាំស្រូវនិងកៅស៊ូ ។ គឺជាប្រទេសចុងដៃនៃមហាចក្រខ្មែរដ៏សំបូរ ។

ព្រៃនគរ ដែលយួនហៅតាមសូរសៀងវាថា សៃហ្គន ជារដ្ឋធានីនៃប្រទេសកូសាំងស៊ីន ហើយជាទីស្នាក់ការនៃរដ្ឋបាលកណ្ដាលរបស់អាណានិគមបារាំងនៅអាស៊ីនេះ ។

សំរាប់ប្រទេសបារាំង កូសាំងស៊ីនគឺជារដ្ឋមួយក្នុងបណ្ដារដ្ឋចំណុះទាំង៥ដែលមានសារៈសំខាន់បំផុត ជឿនលឿនបំផុត ស្រឡាញ់បារាំងបំផុត ហើយងាយការពារនិងត្រួតត្រាបំផុត ។

⌘

# ប្រទេសកម្ពុជា

តាមភិនភាគធម្មជាតិ ប្រទេសកម្ពុជាគឺជាដីដើមដៃនៃកូសាំងស៊ីនតែម្តង (Pro longement direct) ចំណែកកូសាំងស៊ីនជាដែនដីសំបូរវាលល្វឹងល្វើយ កីឯប្រទេសកម្ពុជាវិញ មានទិដ្ឋភាពផ្សេង គឺច្រើនសំបូរដោយភ្នំនិងព្រៃ ។ ប្រទេសកម្ពុជា «មានប្រយោជន៍និងសំបូរ»ជាងគេនោះគឺប្រទេសកម្ពុជាដែលលាតសន្ធឹងបណ្តោយទន្លេមេគង្គ ចាប់ពីក្រចេះ កំពង់ចាម រហូតដល់ទន្លេនៅកូសាំងស៊ីន បន្ទាប់មកគឺតំបន់នៅខាងលិចនិងខាងត្បូងបឹងធំ (ទន្លេសាប) ហើយទីបំផុត គឺដីចន្លោះទន្លេសាបនិងព្រំដែនសៀម (វាលស្រែនៅបាត់ដំបង) ។

ប្រទេសកម្ពុជាបានធ្លាក់ទៅក្រោមអាណាព្យាបាលបារាំងនៅឆ្នាំ១៨៦៣ ។

⌘

# ប្រទេសអណ្ណាម

ប្រទេសអណ្ណាមក៏ជាប្រទេសស្ថិតក្រោមអាណាព្យាបាលនេះនៅឆ្នាំ១៨៨៤ ។ ប្រទេសនេះ តាំងនៅចន្លោះជួរភ្នំអណ្ណាមនិងសមុទ្រចិន និងខ្លង់រាបដែលបានសន្ធឹងជួរភ្នំនេះរហូតដល់សមុទ្រ ។ ប្រទេសអណ្ណាមមានទំហំ១៤៨,០០០គីឡូម៉ែត្រក្រឡា ។

នៅឆ្នាំ១៩៤៥ ប្រទេសអណ្ណាមមានពលរដ្ឋប្រហែល៦លាននាក់ ដែលក្នុងនោះមានជនជាតិអឺរ៉ុប៥,០០០នាក់ផង ។ ជាតិយួនដែលមានចំនួនច្រើនជាងគេតាំងនៅក្នុងវាលទំនាប ចំណែកនៅកណ្តាលប្រទេសវិញ គេប្រទះឃើញសុទ្ធតែជនព្រៃភ្នំនៃកុលសម្ព័ន្ធកំណើតឥណ្ឌូណេស៊ី ឬ(អូស្ត្រាណេស៊្យែន) ដូចជាពួកហ្សើរ៉ៃបាសណារ រ៉ាដេ (Joraî, Bahnar, Rhadé) ដែលយួនហៅថាម៉ុយមនុស្សព្រៃ ។

អណ្ណាមនេះគឺជាអតីតនគរចំប៉ា (នគរចាម) ដែលទើបនឹងវិនាសសាបសូន្យ ហើយធ្លាក់ទៅក្នុកណ្តាប់ដៃយួននៅសតវត្សទី១៧ ។ រដ្ឋធានីនៃប្រទេសអណ្ណាមគឺក្រុងវេ ។ ពួកបារាំងបានទុកក្រុងនេះថា ជាធានីរដូវរំហើយរបស់ឥណ្ឌូចិន ។ ស្តេចដែលសោយរាជ្យនៅក្រុងនេះ កាលពីឆ្នាំ១៩៤៥ គឺស្តេចបាវដាយ ចុះមកពីសន្តតិវង្សង្វៀង ដែលជាមេនៃត្រកូលប្លន់ប្រទេសជិតខាង ។

⌘

# ប្រទេសតុងកឹង

ប្រទេសតុងកឹង គឺជាគូប្រជែង ឬជាចោរហនេយ្យរំរបស់កូសាំងស៊ីនតែម្តង ។ តាមពិត តុងកឹងជាប្រទេសយួនដែលទើបនឹង«លួចរត់»ចេញពីមហាប្រទេសចិន ហើយពួកចិនតែងទុកដាក់ពួកយួននេះថាជា «ពួងចិន» ។

ប្រទេសតុងកឹងមានទំហំ១០៣,០០០គីឡូម៉ែត្រក្រឡា ។ ទន្លេក្រហមដែលហូរចុះពីយុណ្ណាន (ប្រទេសចិន) បានចែកប្រទេសតុងកឹងជាពីរ និងផ្តល់ជាធនធាន ដល់ប្រទេសនេះថែមទៀតផង ។

ប្រទេសតុងកឹង គឺជាប្រទេសឋិតក្រោមអាណាព្យាបាលបារាំងមុនគេនៃអតីតឥណ្ឌូចិន ហើយទើបនឹងផ្តាច់ចេញពី «អាណាព្យាបាលអណ្ណាម» នៅឆ្នាំ១៨៨៦ រួចហើយត្រូវស្ថិតក្រោមការត្រួតត្រារបស់បារាំងដដែល តែត្រូវបានទទួលលក្ខន្តិកៈថ្មីមួយបែបទៀត របៀបជាប្រទេសឋិតក្រោមអាណាព្យាបាលផង និងជាប្រទេសចំណុះផង ។

ភោគទ្រព្យប្រទេសតុងកឹង ពុំមានគ្រប់គ្រាន់អាចនឹងចិញ្ចឹមពលរដ្ឋរបស់ខ្លួនបានឡើយ សោតឯផលដំណាំកសិកម្មក៏ពុំសូវជាសំបូរណាស់ណាដែរ ពីព្រោះប្រទេសនេះមានជម្ងឺប្រចាំសតវត្សរ៍ពីរយ៉ាង គឺទឹកជំនន់និងរាំងហួតហែង ។ ដូច្នេះទុរ្ភិក្ស ការអត់ឃ្លាន គឺជាគ្រោះថ្នាក់អចិន្ត្រៃយ៍ចំពោះយួន និងជម្ងឺអត់ឃ្លាននេះអាចនឹងដោះស្រាយយួន ក៏ដោយសារតែជង្រុកស្រូវរបស់កម្ពុជាក្រោម ឬកូសាំងស៊ីននេះដែរ ។ គឺមូលហេតុចំបងនេះហើយ ដែលតំរូវសង្គ្រាមវាតដីនៃពួកយួនទៅលើប្រទេសកម្ពុជា ប្រទេសចំប៉ា ប្រទេសលាវ ប្រទេសសៀម ។

ហាណូយជារដ្ឋធានីនគរតុងកឹង ហើយជាអតីតរដ្ឋធានីនយោបាយនិងរដ្ឋបាលនៃឥណ្ឌូចិនបារាំង ។ ធានីនេះត្រូវស្តេចត្រកូលង្វៀងលើកទៅតាំងនៅក្រុងវ៉េកាលពីឆ្នាំ១៨០២ ។

⌘

# ប្រទេសលាវ

ប្រទេសលាវ ជាប្រទេសមួយធំជាងប្រទេសឯទៀតនៃសហព័ន្ធ ដោយមានទំហំដល់ទៅ២៣៦,០០០គីឡូម៉ែត្រក្រឡាឯណោះ ក៏ប៉ុន្តែជាប្រទេសរហោស្ថាន ក្រទាំងភោគទ្រព្យធម្មជាតិ ក្រទាំងមនុស្ស (មានតែ១លាននាក់ប៉ុណ្ណោះ) ។

សហព័ន្ធឥណ្ឌូចិន ដែលខ្ញុំជំរាបដោយសង្ខេបខាងលើនេះ បានផុតជីវិតទៅវិញ ស្របគ្នានឹងការផុតរលត់នៃអំណាចអាណានិគមបារាំងដែរ ។ សន្និសិទមួយស្តីពីសន្តិភាពឥណ្ឌូចិន បានបើកឡើងនៅក្រុងហ្សឺណែវ រដ្ឋធានីនៃប្រទេសស្វីសនៅថ្ងៃទី៨ឧសភា១៩៥៤។ ផលវិបាកនៃសន្និសិទនេះគឺត្រង់ការពន្យានិងប្តូរឈ្មោះ

# ជំពូក២

# សង្គ្រាមឥណ្ឌូចិន-សង្គ្រាមខាតដី

គេធ្លាប់និយាយនិងនាំគ្នាជឿថា មូលហេតុនៃសង្គ្រាមឥណ្ឌូចិន គឺការកំចាត់ចក្រពត្តិជប៉ុននិងអាណានិគមបារាំង ចេញពីប្រទេសទាំងឡាយនៅឥណ្ឌូចិននេះ ។ ហើយនៅក្នុង«សង្គ្រាមរំដោះ»នេះ គេក៏បានសរសើរចលនាវៀតមិញស្ទើរតែមិនដាច់ពីមាត់ដែរ ។ តើមូលហេតុពិតនៃសង្គ្រាមឥណ្ឌូចិនស្ថិតនៅក្នុងនិក្ខេបបទដូចដែលអ្នកយល់ខាងលើនេះឬទេ ? ខ្ញុំឆ្លើយថា ទេ ! ។

## វគ្គទី១

## សេចក្ដីសារភាព របស់យួនក្នុងរឿងកូសាំងស៊ីន

ក្នុងវគ្គនេះ ខ្ញុំសូមលើកយកសេចក្ដីថ្លែងការណ៍ខ្លះរបស់លោកង្វៀង-កុកឌិន ប្រធានគណប្រតិភូយួនខាងត្បូង ដែលបានថ្លែងនៅក្នុងទិវាទី២ នៃសន្និសិទហ្សឺណែវឆ្នាំ១៩៥៤ មកជូនជ្រាប ។ លោកង្វៀង-កុកឌិន បាននិយាយថា ៖

«គឺជាការព្រួយណាស់ ការដែលប្រជាជាតិយួនមួយបែកបាក់គ្នា ហើយត្រូវចែកគ្នានេះ...» ។

«យើងមានការឈឺចាប់ជាងពួកយួន ដែលចូលប្រជុំក្នុងបន្ទប់នេះទៅទៀត ពីព្រោះពួកនេះពីដើមធ្លាប់ប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយយើង ដើម្បីការពារផលប្រយោជន៍ខ្ពស់របស់ជាតិ ហើយដែលសព្វថ្ងៃនេះបែកបាក់ពីយើង...» ។

«សំរាប់រាស្ត្រយួន សេរីភាពមានន័យថា ឯករាជ្យនិងប្រជាធិបតេយ្យក្នុងក្របខ័ណ្ឌនៃប្រជាជាតិមួយ ស្ថាបនាជាថ្មីនៅក្នុងព្រំដែនជាប្រវត្តិរបស់ខ្លួន (!?) ។

«ឯកភាព ឯករាជ្យ និងសេរីភាពនៅក្នុងសន្តិភាពទាំងនេះ ហើយដែលថានឹងនៅជាសេចក្តីប៉ងប្រាថ្នាដ៏ជ្រាលជ្រៅ ជាមូលដ្ឋានដ៏ទៀងទាត់របស់រាស្ត្រយួន ។

«សេចក្តីប៉ុងប្រាថ្នាទាំងនេះ ពួកយៀកមិញដែលកាលណោះជាក្រុមអង្គការនយោបាយរួបរួមចំរុះមួយដែរ បានសន្យាយ៉ាងឧឡារិកថានឹងដឹកនាំប្រយុទ្ធរួម ឆ្ពោះទៅរកការធ្វើឲ្យសំរេចឡើងនូវសេចក្តីប៉ងប្រាថ្នាទាំងនោះ...» ។

«ដើម្បីធ្វើឲ្យមានឯកភាពជាតិទាំងស្រុង នៅក្នុងប្រយុទ្ធដើម្បីឯកភាព ឯករាជ្យ និងប្រជាធិបតេយ្យ ព្រះចៅបៅដាយបានបូជាដោយឥតស្តាយស្រណោះនូវស្វេតច្ឆ័ត្រ ដែលជាកេរ្តិ៍ដូនតាព្រះអង្គ» ។

«ដូច្នេះរាស្ត្រយួនទាំងអស់បានទុកឲ្យយៀកមិញ ធ្វើឲ្យសំរេចឡើងនូវឯកភាពឯករាជ្យ និងលទ្ធិប្រជាធិបតេយ្យដោយសេរី និងទូលំទូលាយបំផុត» ។

«ដោយបានទទួលការគាំទ្រពីគ្រប់ស្រទាប់ប្រជារាស្ត្រផង ព្រះចៅបៅដាយនិងរដ្ឋវៀតណាមបានធ្វើឲ្យសេចក្តីប៉ងប្រាថ្នាជាសារវ័ន្តរបស់ប្រទេសសំរេចឡើងតាំងពីឆ្នាំ១៩៤៩មក ។

«ឯកភាពដែនដីត្រូវបានធ្វើឲ្យសំរេចស្រេចហើយ ។ មាត្រា២នៃច្បាប់បារាំងចុះថ្ងៃទី៤មិថុនា១៩៤៩ បានបញ្ជាក់ជាពិសេសថា ដែនដីកូសាំងស៊ីនត្រូវភ្ជាប់ទៅរដ្ឋវៀតណាម (យួនខាងត្បូង)... ដូច្នេះកូសាំងស៊ីនឈប់មានលក្ខន្តិកៈជាដីឯនាយសមុទ្រ (ដីខ្មែរ) ទៀតហើយ» ។

ហេតុដែលខ្ញុំនិយាយអំពីសហព័ន្ធឥណ្ឌូចិន អំពីសង្គ្រាមឥណ្ឌូចិន គឺនៅក្នុងគំនិតតែមួយ ចង់ជំរាបថា មូលហេតុក្តី ល្បិចក្តីនៃសង្គ្រាមឥណ្ឌូចិន សុទ្ធសឹងជាឆាកនយោបាយវាតទឹកដីនៃពួកយួនតែប៉ុណ្ណោះ ។ យួនធ្វើជាទាស់គ្នាបោកយក្សក្រហម-យក្សខៀវ ដើម្បីឲ្យជួយប្លន់ដីឥណ្ឌូចិនឲ្យវា ។

តើសេចក្តីសារភាពរបស់តំណាងយួនខាងលើប៉ុណ្ណោះ នឹងទុកអ្វីខ្លះទៀតសល់សំរាប់ឲ្យយួន ឲ្យបារាំង ដោះសារថា កូសាំងស៊ីនពុំមែនជាដីខ្មែរ ថាខ្លួនពុំបានរំលោភច្បាប់ប្រគល់ដី ដែលពុំមែនជារបស់ជាតិខ្លួន ទៅលើជនជាតិដទៃ !?

បញ្ហាធំស្ថិតនៅត្រង់ថា តែបារាំងដែលជាអាណាព្យាបាលខ្មែរពេលនោះ មានសិទ្ធិអំណាចធ្វើបែបនេះ (ផ្ទេរដីខ្មែរឲ្យយួន) បានឬទេ ??

⌘

⌘ ⌘

# វគ្គទី២

# ឆ្ពោះទៅរកការប្រយុទ្ធខាងនយោបាយ សន្និសិទប្រជារាស្ត្រឥណ្ឌូចិន ថ្ងៃ១មិនា១៩៦៥

សន្និសិទហ្សឺណែវឆ្នាំ១៩៥៤ ស្ដីពីឥណ្ឌូចិនបានរំលត់ភ្លើងសង្គ្រាមអស់មួយរយៈដែរចំពោះប្រទេសកម្ពុជា ។ ក៏ប៉ុន្តែនៅប្រទេសលាវនិងប្រទេសយួនឯណោះវិញ សង្គ្រាមបានបន្តទៅទៀត ពីព្រោះមានទំនាស់ក្នុងការរៀបចំនយោបាយសំរាប់ប្រទេសលាវ ពីព្រោះបំណងធំរបស់យួន គឺបង្រួបបង្រួមវៀតណាមខាងត្បូងទៅជាមួយនឹងវៀតណាមខាងជើង ពុំអាចធ្វើកើតចំពោះយួន ។ គួរកត់សំគាល់ថា សន្និសិទហ្សឺណែវឆ្នាំ១៩៥៤ បានចែកប្រទេសយៀកណាមជាពីរ ហើយគ្រោងឲ្យបង្រួបបង្រួមវិញតាមវិធីបោះឆ្នោត ប៉ុន្តែការបោះឆ្នោតសកលស្ថិតនៅក្រោមកិច្ចត្រួតពិនិត្យអន្តរជាតិ ពុំអាចធ្វើទៅកើតឡើយដោយអតីតប្រធានាធិបតីង៉ោ-ឌិនយីម មិនព្រមចុះចាញ់ល្បិចរបស់កុម្មុយនិស្តហូ-ជីមិញ ។

តាមហេតុខាងលើ ដីកម្ពុជាក្រោមរបស់យើង ពុំទាន់ត្រូវយួនលេបបានពេញលក្ខណៈច្បាប់នៅឡើយទេ ។ យួនបានខិតខំធ្វើការនេះដោយប្រញាប់បំផុត តាមគ្រប់មធ្យោបាយ ដោយវាបានបោកប្រាស់ពិភពលោកសេរីថា វាច្បាំងទប់ការជ្រៀតចូលនៃលទ្ធិម៉ាក់ស៊ីស្ត-ឡេនីនិស្ត និងថារំដោះប្រជារាស្ត្រអាស៊ី ឥណ្ឌូចិន ចេញពីក្រញាំចក្រពត្តិនិយមលោកសេរី មានអាមេរិកាំងជាមេ ។ ក៏រីឯមហាអំណាចក្រហមនិងខៀវ ក៏បានចូលខ្លួនបំរើមូលហេតុចោរប្លន់នៃពួកយួននេះ ដោយឥតដឹងខ្លួនដូច្នេះទៅ ។

ក្នុងគោលបំណងរារាំងការបញ្ចូលដីក្រោមរបស់ខ្មែរទៅជាមួយយួន សន្និសិទមួយក៏បានត្រូវអតីតប្រមុខរដ្ឋខ្មែរផ្ដួចផ្ដើមឡើង គឺសន្និសិទប្រជារាស្ត្រឥណ្ឌូចិនឆ្នាំ១៩៦៥ ធ្វើនៅក្រុងភ្នំពេញ ។

ខ្ញុំយល់ថា គួរជំរាបកញ្ញា លោកស្រី អស់លោក និងមិត្តអ្នកអានតែត្រួសៗចុះហើយដោយសើៗចុះ អំពីជំរៅនៃសន្និសិទប្រជារាស្ត្រឥណ្ឌូចិន និងអំពីការចូលខ្លួនទៅក្នុង «ចំបាំងវៀតណាម» នៃប្រទេសខ្មែរ ពីព្រោះសេរីភាពយើងអនុញ្ញាតឲ្យ

និយាយបានតែត្រឹមនេះនិងតែរបៀបនេះ ។

សន្និសិទប្រជារាស្ត្រឥណ្ឌូចិនឆ្នាំ១៩៦៥នៅក្រុងភ្នំពេញ បានចាប់ផ្តើមបើកពីថ្ងៃ១៨កុម្ភៈដល់ថ្ងៃទី១មិនា១៩៦៥ គឺ ៖ សន្និសិទរៀបចំ (Conférence préparatoire) ចាប់ធ្វើពីថ្ងៃទី១៨ដល់១៧កុម្ភៈ និងសន្និសិទពេញអង្គ (Conférence plénière) ចាប់ពីថ្ងៃ២៥កុម្ភៈដល់ថ្ងៃទី១មិនា១៩៦៥ ។

១- <u>អំពីប្រទេសដែលចូលរួមក្នុងសន្និសិទប្រជារាស្ត្រឥណ្ឌូចិនឆ្នាំ១៩៦៥</u> ៖

ក្រោយពីសម្តេចនរោត្តម-សីហនុ ប្រមុខរដ្ឋនៃប្រទេសកម្ពុជាបានអំពាវនាវក្នុងទិវាទីសវិច្ឆិកា១៩៦៤ សុំឲ្យបើកសន្និសិទប្រជារាស្ត្រឥណ្ឌូចិន ដើម្បី«បង្រួបបង្រួមប្រជារាស្ត្រឥណ្ឌូចិន និងពង្រឹកការប្រយុទ្ធទល់នឹងចក្រពត្តិអាមេរិកាំង»នោះមក អង្គការនយោបាយចលនារំដោះនានាយ៉ាងច្រើនបានប្រកាសថា ខ្លួនមានចំណងចូលរួមក្នុងសន្និសិទនេះដែរ ។ ការសុំចូលច្រើនពេកបែបនេះ បានធ្វើឲ្យប្រទេសខ្មែរដែលជាអ្នកផ្តើមគំនិតមានការព្រួយបារម្ភ ដល់ការលំបាកនានាខាងបច្ចេកទេស ហើយទីបញ្ចប់គណៈប្រតិភូ៤០ ដែលមានឈ្មោះដូចខាងក្រោមនេះ ត្រូវបានទទួលសេចក្តីអនុញ្ញាតពីសន្និសិទ រៀបចំឲ្យចូលរួមក្នុងសន្និសិទពេញអង្គ ។

★ <u>ប៉ែកខាងប្រទេសកម្ពុជា</u> ៖

មានគណៈប្រតិភូបួនគឺ ៖

១- ពុទ្ធិកសមាគមវៀតណាមនៅប្រទេសកម្ពុជា (A.B.V.C)

២- គណៈកម្មការនៃសហភាពយួននៅប្រទេសកម្ពុជា (C.U.R.V.C.)

៣- ក្រុមជនជាតិយួននៅប្រទេសកម្ពុជា (G.V.C.)

៤- សង្គមរាស្ត្រនិយម (S.R.N.)

★ <u>ប៉ែកខាងប្រទេសលាវ</u> ៖

គណៈប្រតិភូប្រាំ ត្រូវបានទទួលសេចក្តីអនុញ្ញាតគឺ ៖

១- ពុទ្ធិកសមាគមមាតុភូមិនិយម (A.B.P.)

២- សហព័ន្ធយុវបញ្ញវ័ន្ត (F.J.I.)

៣- កងកម្លាំងពព្យាក្រិតមាតុភូមិនិយមលាវ (F.N.P.L.)

៤- ណេអូឡៅហាក់សាត (N.L.H.) (ប៉ាថេតឡាវ)

៥- គណៈបក្សសន្តិភាព និងអព្យាក្រិតភាព (P.P.N.)

★ <u>ប៉ែកខាងយួនខាងជើង</u> ៖

គណៈប្រតិភូនានាចំនួន១១ បានទទួលសេចក្តីអនុញ្ញាតគឺ ៖

១- ពុទ្ធិកសមាគមបង្រួបបង្រួមប្រទេសវៀតណាម (A.B.U.V.)

២- គណៈកម្មការកណ្តាលនៃរណសិរ្សមាតុភូមិយៀកណាម (C.C.F.P.V.)

៣- សង្ព័ន្ធកណ្តាលនៃយុវជនយៀកណាម (C.F.J.V.)
៤- គណៈកម្មការជាតិនៃការទាក់ទងកាតូលិកមាតុភូមិនិយម (C.N.L.C.P.)
៥- គណៈកម្មការសន្តិភាពយៀកណាម (C.P.V.)
៦- គណៈកម្មការយួននៃសាមគ្គីភាពប្រជារាស្ត្រអាស៊ីអាហ្វ្រិក(C.V.S.P.A.A.)
៧- សហព័ន្ធសហជីពវៀតណាម (F.S.V.)
៨- គណបក្សប្រជាធិបតេយ្យវៀតណាម (P.D.V.)
៩- គណបក្សសង្គមនិយមយួន (P.S.V.)
១០- សហភាពកៅដាយវៀតណាម (U.C.V.)
១១- សហភាពស្ត្រីវៀតណាម (U.F.V.)
★ ប៉ែកខាងយួនខាងត្បូង ៖

អង្គការនយោបាយចលនារំដោះចំនួនម្ភៃ ដែលជាចំនួនច្រើនជាច់គេនៅប្រទេសយួនខាងត្បូង ត្រូវបានសន្និសិទរៀបចំអនុញ្ញាតឲ្យចូលរួមក្នុងសន្និសិទពេញអង្គគឺ ៖

១- ពុទ្ធិកសមាគមយួនខាងត្បូង (A.B.S.V.N.)
២- សមាគមសាមគ្គីព្រះសង្ឃមាតុភូមិនិយមតំបន់ណាំបូខាងលិច (A.S.B.P.R.O.N.)
៣- គណៈកម្មការអូស្ត្រីយាងសាមគ្គី នៃប្រជារាស្ត្រអាហ្វ្រិក-អាស៊ីវៀតណាមខាងត្បូង (C.A.S.A.A.S.V.N.)
៤- គណៈកម្មការការពារព្រះពុទ្ធសាសនាទល់នឹងរបបឱននិយម (C.D.B.C.S.D.)
៥- គណៈកម្មការនៃរណសិរ្សរំដោះកម្ពុជាក្រោមប៉ែកខាងជើង (C.F.L.K.K.P.N.)
៦- គណៈម្មការសេរីការខ្ពង់ខ្ពស់នគរចំប៉ា (C.L.H.P.P.C.)
៧- គណៈកម្មការដើម្បីសន្តិភាពនិងបុនក្ការវៀតណាមខាងត្បូង (C.P.P.L.R.S.V.N)
៨- កងកម្លាំងតស៊ូអាវុធនៃសាធារណរដ្ឋវៀតណាម (F.D.A.R.V.N.)
៩- រណសិរ្សតស៊ូនៃកម្ពុជាក្រោម (F.L.K.K.)
១០- រណសិរ្សសេរីការជាតិវៀតណាមខាងត្បូង (F.N.L.)
១១- រណសិរ្សតស៊ូនៃជាតិត្រូវគេជិះជាន់ (F.U.L.R.O.)
១២- ក្រុមនាយទាហានមេរដ្ឋប្រហារថ្ងៃ១១វិច្ឆិកា១៩៦០ (G.O.A.C.E.)
១៣- ក្រុមប្រយុទ្ធដើម្បីសហវិជ្ជមានដោយសន្តិវិធី (G.C.P.)

១៤- ចលនាយុវជនអ្នូស្ត្រីយ៉ាងនៅវៀតណាម (M.J.A.S.V.N.)

១៥- ចលនាអព្យាក្រិតវៀតណាម (M.N.V.N.)

១៦- ចលនាដើម្បីស្វ័យភាពនៃប្រជាជន (M.P.A.P.)

១៧- តំណាងខ្មែរឥស្លាមនៅកម្ពុជាក្រោម (R.K.I.K.K.)

១៨- តំណាងព្រះសង្ឃពុទ្ធនិយមខ្មែរក្រោម និងពុទ្ធិកវិទ្យាស្ថានកម្ពុជាក្រោម (R.M.B.K.K.I.B.K.K.)

១៩- សហភាពស្ត្រីអ្នូស្ត្រីយែននៅវៀតណាមខាងត្បូង (U.F.A.S.V.N.)

២០- សហភាពស្ត្រីរំដោះវៀតណាមខាងត្បូង (U.F.L.S.V.N.)

២- <u>របៀបវារៈ</u> ៖

សន្និសិទពេញអង្គបានពិភាក្សាយ៉ាងល្អិតល្អន់ ដោយសម្ងាត់នូវរបៀបវារៈធំៗពីរយ៉ាងរបស់ខ្លួនគឺ ៖

ក/ បញ្ហាសន្តិភាពក្នុងឯករាជភាពនៃឥណ្ឌូចិន ៖

ក្នុងបញ្ហានេះ បានប្រកាន់យកសេចក្តីសំរេចដូចខាងក្រោម ៖

ក១- ចំពោះប្រទេសវៀតណាម ៖ គោរពនិងប្រតិបត្តិដោយត្រឹមត្រូវបំផុតនូវកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៥៤ ពោលគឺតម្រូវឲ្យអាមេរិកាំងនិងសម្ព័ន្ធមិត្តដកទ័ពចេញពីឥណ្ឌូចិន ព្រមទាំងឈប់ជ្រៀតជ្រែកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសទាំងនោះ ។

- រំដោះប្រទេសវៀតណាមខាងត្បូង និងផ្តល់សន្តិភាពឲ្យប្រទេសនេះ ។

- បញ្ចប់សកម្មភាពសង្គ្រាម និងការរករឿងនៃ«ចក្រពត្តិ»អាមេរិកហើយនិង«ខ្ញុំកញ្ជះ» គឺវៀតណាមខាងត្បូង ទៅលើវៀតណាមខាងជើង ។

ក២- ចំពោះប្រទេសខ្មែរ ៖ ទទួលស្គាល់និងគោរពអព្យាក្រិតភាពនិងបូរណភាពដែនដីរបស់ប្រទេសកម្ពុជា - កោះប្រជុំសន្និសិទហ្សឺណែវថ្មីមួយទៀត ដើម្បីធានាអព្យាក្រិតនិងបូរណភាពដែនដី ។

- បញ្ចប់អំពើឈ្លានពាន ។

ក៣- ចំពោះប្រទេសលាវ ៖ ធ្វើឲ្យមានសន្តិភាពឡើងវិញ គោរពកិច្ចព្រមព្រៀងហ្សឺណែវឆ្នាំ១៩៦២ ស្តីពីលាវ ។

-គោរពឯករាជ្យ អព្យាក្រិត អធិបតេយ្យ និងបូរណភាពដែនដីរបស់លាវ ។

ខ- សាមគ្គីភាព ៖

ដើម្បីពង្រឹងចំណងសាមគ្គីភាពរវាងប្រទេសទាំងអស់នៅអតីតអណ្ឌូចិន និងសំរបសំរួលការប្រយុទ្ធនៃអង្គការចលនារបស់ប្រទេសទាំងនោះ សន្និសីទបានសំរេច ៖

- បង្កើតអង្គការឬលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ក្នុងបំណងបង្កើនសហប្រតិបត្តិការរវាងប្រជារាស្ត្រឥណ្ឌូចិន ។
- ចាត់វិធានការផ្សេងៗដែលត្រូវប្រកាន់យក ឬត្រូវស្នើក្នុងបំណងពង្រឹងសហប្រតិបត្តិការ និងការយោគយល់គ្នាទៅវិញទៅមក ។

ទាំងនេះឯងហើយ សំបកនៃសន្និសិទប្រជារាស្ត្រឥណ្ឌូចិនឆ្នាំ១៩៦៥ ។

ក៏ប៉ុន្តែ ក្រោយសន្និសិទនេះ ស្រាប់តែយួនខាងជើងប្រកាសទទួលស្គាល់និងគោរពបូរណភាពដែនដីរបស់ខ្មែរក្នុងព្រំដែនបច្ចុប្បន្ន (!?) ជាកិច្ចតបទៅនឹងការទទួលស្គាល់នៃព្រះរាជាណាចក្រកម្ពុជា នូវរដ្ឋាភិបាលបណ្ដោះអាសន្នវៀតណាមខាងត្បូង (វៀតកុង) ។

គួរកត់សំគាល់ជាពិសេសថា នៅមុនសន្និសិទប្រជារាស្ត្រឥណ្ឌូចិន កិច្ចចរចាស្ដីពីព្រំដែនខ្មែរ-យួន បានប្រព្រឹត្តទៅកាលពីថ្ងៃ១៥មករា១៩៦៥ នៅប៉េកាំង ។ ក្នុងសន្និសិទនោះ គេបានសង្កេតឃើញខាងខ្មែរ ឯកឧត្ដមទ្រឿង-កាង ឯកអគ្គរាជទូតខ្មែរប្រចាំក្រុងប៉េកាំង ខាងយួនខាងជើង ឯកឧត្ដមត្រាំង-ទុយប៊ិន ឯកអគ្គរដ្ឋយៀកណាមខាងជើង និងសាស្ត្រាចារ្យ ង្វៀង-យ៉ាំងហ៊ីវ ជាមេគណប្រតិភូយៀកកុង ។ លោកសេនាប្រមុខចេន-យី នៃប្រទេសចិនក្រហម ក៏បានទទួលគណប្រតិភូនេះដែរ ។

ខ្ញុំសូមបញ្ជាក់ថា សន្និសិទប្រជារាស្ត្រឥណ្ឌូចិន ហាក់ដូចពុំមានទាក់ទងអ្វីទៅនឹងការទាមទារមកវិញនូវដីកម្ពុជាក្រោមនៃយើងនោះទេ ។ ក៏ប៉ុន្តែចំពោះខ្ញុំ ខ្ញុំយល់ថា បើយ៉ាងហោចណាស់ក៏គង់សន្និសិទនេះបានយកយួនទាំងពីរឲ្យទៅជល់គ្នាជាអង្វែងឆ្នាំដែរ (ព្រោះយើងបានធ្វើឲ្យមានយួនពីរ) ហើយតាមន័យនេះ បានបាំងបានបង្អាក់ការបង្រួបបង្រួមនៃយួនដែរ ពីព្រោះការបង្រួបបង្រួមនោះបំពានលើសិទ្ធិទាំងឡាយរបស់រាស្ត្រយួនខាងត្បូងផង និងខ្មែរកម្ពុជាក្រោម ព្រមទាំងកុលសម្ព័ន្ធនានានៅវៀតណាមខាងត្បូងនោះផង ។

⌘ ⌘
⌘

-

# វគ្គទី៣

# ភ័ស្តុតាងដែលពុំអាចប្រកែកបាន

ខ្ញុំបានជំរាបរួចហើយថា យួនមានគំនិតតែមួយ គឺវាតដីចុះទៅទិសខាងត្បូងតាមបណ្តោយសមុទ្រចិន និងឆ្ពោះទៅទិសខាងលិច ដោយឆ្លងកាត់ទន្លេមេគង្គ ។ មកដល់សព្វថ្ងៃ សង្គ្រាមវាតដីនៃពួកយួនបានរងការវាយប្រហារតបវិញយ៉ាងខ្លាំងពីសំណាក់ប្រទេសដែលវាប៉ុនប៉ងបំរុងលេប ។ ឃើញហេតុការណ៍បែបនេះ យួនបានខិតខំអូសទាញប្រទេសខ្លះឲ្យចូលភ្ជក់ភ្លើងរបស់ខ្លួន ហើយខិតខំបោកប្រាស់មតិអន្តរជាតិយល់ថា ខ្លួនធ្វើសង្គ្រាមដើម្បីរំដោះមនុស្សជាតិ ចេញពីក្រញាំចក្រពត្តិអាមេរិក (អស្ចារ្យ!) ។ ក្នុងសង្គ្រាមបោកប្រាស់នេះ យួនប្រើល្បិចខូចសព្វបែបយ៉ាង ដើម្បីសម្លាប់សម្ព័ន្ធមិត្តរបស់ខ្លួន មានប្រទេសខ្មែរនេះជាដើម ។

ក្នុងវគ្គនេះ ខ្ញុំសូមអនុញ្ញាតយកសេចក្តីសង្កេតតែពីរយ៉ាងមកបញ្ជាក់ជូនចុះថា តើយួនណាក៏ដូចយួនណាមែនឬមិនមែន ។

១- <u>គេកំពុងទាក់ទាញសៀមនិងម៉ាឡាយូ ឲ្យវាយប្រហារខ្មែរ</u> ៖

វិទ្យុផ្សាយសម្លេងសាធារណរដ្ឋវៀតណាម ផ្សាយជាភាសាវៀតណាម ថ្ងៃទី៧មករា១៩៧៣ ពីម៉ោង២១:០០ដល់២១:០៥នាទី បានផ្សាយដូច្នេះថា ៖

«ក្នុងកិច្ចពិភាក្សាគ្នាផ្ទាល់ជាមួយអ្នកវដ្តការនៃសហរដ្ឋអាមេរិក លោកប្រធានាធិបតីង្វៀង-វ៉ាន់ធីវ បានឲ្យដឹងថា ៖ កងកម្លាំងកុម្មុយនិស្តធ្វើការវាយប្រហារទៅលើសាធារណរដ្ឋខ្មែរនៅពេលថ្មីៗនេះ អាចនឹងបណ្តាលឲ្យមានការវាយប្រហារមួយថ្មីទៀតកើតឡើងនៅឥណ្ឌូចិនទាំងមូល ។

តាមប្រភពដំណឹងពីក្រសួងការបរទេសសហរដ្ឋអាមេរិក លោកប្រធានាធិបតីង្វៀង-វ៉ាន់ធីវ បានសំដែងការព្រួយបារម្ភចំពោះការវាយប្រហាររបស់ខ្មាំងកុម្មុយនិស្ត ដែលអាចនឹងវាយចណ្តើមយកបានសាធារណរដ្ឋខ្មែរ ហើយយកប្រទេសនេះធ្វើជាឈ្នាន់សំរាប់វាយប្រហារប្រទេសថៃនិងប្រទេសម៉ាឡេស៊ីថែមទៀតផង

ក្នុងពេលជាមួយគ្នានោះ លោកឧត្តមនាវីម៉ាសម៉ូរ៉ រ ប្រធានក្រុមអគ្គសេនាធិការនៃសហរដ្ឋអាមេរិកបានឲ្យដឹងថា កុម្មុយនិស្តវៀតណាមខាងជើងប្រើប្រាស់ដែនដីនៃសាធារណរដ្ឋខ្មែរ ដើម្បីរៀបចំកងពលរបស់ខ្លួននៅភាគខាងត្បូងវៀតណាម»

សេចក្តីសង្កេត ៖ តាមន័យនេះ និងមានអន្តរាគមន៍ទ័ពមួយជៀសមិនរួច ហើ

យខ្មែរនឹងទៅជាសំបុកប៉េស្តិ (គឺប៉េស្តិយួន) ដែលយួននឹងហៅឲ្យសៀម ម៉ាឡេយូជួយបំផ្លាញ ។

តើប្រទេសយួនខាងត្បូង ដែលយៀកកុងបានតាំងនៅជងពាក់កណ្ដាលនគរនោះ ម្ដេចលោកធីវមិនថាជាសំបុកប៉េស្តិផង ??

២- រ៉ុកកែ្កត ឬណាប៉ាល ជំនួស«តែអុង» ៖

ចំណាន់ក្សត្រីអង្គម៉ី ឧត្ដមសេនិយយួនឈ្មោះទ្រឿង-មិញយ៉ាង បានទុកអនុស្សាវរីយ៍យ៉ាងចុកចាប់បំផុត និងព្រៃផ្សៃបំផុតឲ្យខ្មែរ គឺប្រយ័ត្នកំពុបតែអុង ។ កាលណាគេនិយាយរឿងនេះ គេនឹងនឹកដល់រឿងយួនយកខ្មែរកប់ដីត្រឹមក យកក្បាលធ្វើចង្ក្រានដាំតែ ។

សម័យនេះ របៀបធ្វើដូច្នេះ អាចកើតមានការផ្ដន្ទាទោសយ៉ាងខ្លាំងខាងផ្លូវចិត្ត ។ ដូច្នេះ យួនបានប្រើរបៀបផ្សេងទៀត គឺគេបាញ់ផ្គក់ ឬលួយឆ្មក់វាយប្រហារ ឬទម្លាក់គ្រាប់បែកទៅលើភូមិខ្មែរ ឬជំរំខ្មែរ រួចហើយគេថា «សត្រូវ» ជាអ្នកធ្វើ ។

ខ្ញុំសូមយករឿងបាញ់ផ្គក់ ឬរបៀបសម្លាប់ត្រីក្នុងអង្រុត ដែលយួនធ្វើលើខ្មែរភៀសខ្លួន នៅស្រុកយួនខាងត្បូងពីរកន្លែងមកជំរាប ដើម្បីបញ្ជាក់ទល្មឹករណ៍របស់ខ្ញុំ ដែលថាយួនណាក៏ដូចយួនណា មានបំណងតែមួយ គឺដណ្ដើមដីខ្មែរនិងសម្លាប់បំបាត់ពូជខ្មែរ ។

នៅក្នុងសេចក្ដីរាយការណ៍លេខ១១ហ.ស. ចុះថ្ងៃទី២៦មិនា១៩៧៣ ជូនប្រធានព្រឹទ្ធសភា ស្ដីពីបេសកកម្មរបស់លោក (...) នៅស្រុកយួនខាងត្បូង ដើម្បីពិនិត្យរឿងជនភៀសខ្លួនជាតិខ្មែរ ។ លោកហង់-សារុន សមាជិកព្រឹទ្ធសភាតំណាងសេត្យានុភាព បានបញ្ជាក់ថា ៖ «ដោយការបំភ្លឺពីក្រសួងមានសមត្ថកិច្ច (យួន) ជនភៀសខ្លួនជាតិខ្មែរយើងបានតាំងនៅភូមិខ្ញុំ (ខេត្តរោងដំរី) ចំនួន៤៦២គ្រួសារ គឺមានមនុស្សប្រុសស្រីក្មេងចំនួន២,៥១៧នាក់... ប៉ុន្ដែមានថ្ងៃមួយ ជនរងគ្រោះទាំងនោះត្រូវអន្តរាយដោយខ្មាំងផ្គក់រ៉ុកែ្កតចំកន្លែងភូមិខ្ញុំនោះ បណ្ដាលឲ្យមានស្លាប់និងរបួសជាច្រើន (គឺស្លាប់អស់១,០១០នាក់) ។ ចំនួនស្លាប់១,០១០នាក់នេះ គឺបានដឹងត្រឹមតែខ្មែរដែលភៀសខ្លួនពីកំពង់ចាម, ព្រៃវែង និងស្វាយរៀង ចូលទៅរស់នៅខេត្តរោងដំរី (យួនហៅថាតាយនិញ)ប៉ុណ្ណោះ ។ នៅសល់ជនភៀសខ្លួនពីខេត្តតាកែវទៅរស់នៅខេត្តមាត់ជ្រូក (ចូដុក) ក្នុងតំបន់តាន់ចូវមួយផ្នែកទៀតក៏ត្រូវយួនសម្លាប់ដែរ ហើយបានទាំងរស់នៅដោយវេទនាបំផុតទៀតផង ។

លោកហង់-សារុនបញ្ជាក់ថា «នៅកន្លែងតាន់ចូវដែលជនភៀសខ្លួន (ទៅពីតាកែវ)ជ្រកនោះ បានទទួលរងគ្រោះដោយគ្រាប់រ៉ុកែ្កតផ្លោងចូលម្ដងទៀត បណ្ដាលឲ្យស្លាប់មនុស្សចំនួន៨០នាក់ និងរបួសច្រើនទៀត ។ («សួរថា តើខាងណាផ្លោង

រ៉ុក្កែតម្តងជាពីរដង នៅកន្លែងដដែល») ។

ប៉ុន្តែ នៅខាងលើនេះបន្តិច លោកហង់-សារុនបានឲ្យដឹងថា «នៅយប់ថ្ងៃអង្គារ២០មិនា១៩៧៣ មានគ្រាប់រ៉ុក្កែតផ្លោងចូលទីជំរំ (តាន់ចូវ) ប៉ុន្តែគ្មានត្រូវមនុស្សទេ ពួករងគ្រោះចង់រត់ចេញពីជំរំ ប៉ុន្តែរដ្ឋការនៅទីនោះឃាត់ពុំឲ្យចេញ» ។

សួរថា បើយួនខាងត្បូងគ្មានបំណង ឬថាជាអ្នកសម្លាប់ខ្មែរទេ ហេតុដូចម្តេចក៏ហាមមិនឲ្យខ្មែររត់គេចពីគ្រាប់រ៉ុក្កែត ដែល(សត្រូវ)ផ្លោងទៅលើ ??

ឧត្តមសេនិយង្វៀង-កៅគី អតីតអនុប្រធានាធិបតី និងជាសត្រូវធំសព្វថ្ងៃរបស់ប្រធានាធិបតីង្វៀង-យ៉ាំងធីវ បានអួតអាងប្រាប់មហាជនយួន ក្នុងកិច្ចឃោសនាគណបក្សរបស់ខ្លួន (គឺគណបក្សបី ដែលកើតតាមកិច្ចព្រមព្រៀងក្រុងប៉ារីសថ្ងៃ២៧មករា១៩៧៣)ថា យួនខាងជើងវាយប្រហារខ្មែរនោះត្រូវហើយ ព្រោះធ្វើឲ្យខ្មែរចុះខ្សោយ ហើយយកជាចំណុះបាន ក៏រីឯយើង (វៀតណាមខាងត្បូង) ដែលចូលទៅជួយខ្មែរនោះក៏ត្រូវដែរ ពីព្រោះយើងអាចសម្លាប់ខ្មែរបានងាយស្រួល ដោយគ្រាន់តែថាខ្មែរចូលយៀកកុង តែប៉ុណ្ណឹងក៏ល្មណាស់ទៅហើយ ! គេនិយាយទៀតនៅក្នុងកិច្ចឃោសនាជាភាសាយួនដដែលនោះ ឧត្តមសេនិយង្វៀង-កៅគីបានប្រដូចថា ខ្មែរបានយកក្រមាទៅចងកខ្លួនឯង រួចហុចចុងម្ខាងឲ្យយួនហាណូយ ចុងម្ខាងទៀតឲ្យយួនព្រៃនគរទាញសម្លាប់ ។

ភស្តុតាងនិងពាក្យឧត្តមសេនិយពីរខាងលើនេះ គឺបំបាត់ការសង្ស័យគ្រប់បែបយ៉ាងជាយថាហេតុ ដែលគេនាំឲ្យថា យួនបានចោលពុត ហើយនឹងនាំឲ្យកញ្ញា អស់លោក លោកស្រី និងមិត្ត ថ្លឹងនិងវាយតម្លៃថា តើមិត្តភាពខ្មែរយួនធ្ងន់ប៉ុណ្ណាថ្លៃប៉ុណ្ណា ???

❁ ❁

❁

# យោបល់

កម្ពុជាក្រោមឬកូសាំងស៊ីន ជាដែនដីរបស់ខ្មែរពិតឥតប្រកែកបាន ដែលយួនត្រូវតែប្រគល់ឲ្យខ្មែរវិញ ។

មតិសកលគួរតែឈប់យល់ច្រឡំពីចំបាំងឥណ្ឌូចិនចំបាំងវៀតណាម ថាជាចំបាំងមនោគមវិជ្ជាទៀត ពីព្រោះមកទល់ថ្ងៃនេះ(ខែមិថុនា១៩៧៣) យួនបានបង្ហាញតឹកតាងគ្រប់គ្រាន់ហើយ ថាសង្គ្រាមរបស់គេ ជាសង្គ្រាមវាតដីស្របតាមប្លង់វៀតមិញ និងសេចក្តីសំរេចនៃសន្និសិទល្អាងប៉ាក់បូ ឆ្នាំ១៩៤០-៤១ របស់ខ្មោចហូ-ជីមិញ ។

សង្គ្រាមឥណ្ឌូចិននឹងរលត់ លុះត្រាតែដីកម្ពុជាក្រោមធ្លាក់ក្នុងដៃខ្មែរវិញ លុះត្រាដីទាំងឡាយរបស់ខ្មែរ របស់លាវ របស់ភូមា ត្រូវយួន សៀម ប្រគល់ឲ្យម្ចាស់ដើមទាំងបីនេះវិញ ។

សហរដ្ឋអាមេរិក នឹងពុំអាចត្រូវប្រជាជាតិមានអារ្យធម៌ណាមួយចោទប្រកាន់បានឡើយ បើសិនណាហើយមហាអំណាចនេះដកដៃចេញពីយួនមហាចោរ ដែលបានបោកប្រាស់សហរដ្ឋឲ្យចូលការពារមូលហេតុឧក្រិដ្ឋរបស់វា ។ លទ្ធិកុម្មុយនិស្តនឹងឥតសៅហ្មងទេ បើសិនណាហើយសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងសាធារណរដ្ឋប្រជាមានិតុចិនឈប់ (ឲ្យបាយឲ្យទឹក) ដល់ចោរឧក្រិដ្ឋហាណូយ ដែលបានកសាងវិនាសកម្មពេញអាស៊ី ព្រោះតែចង់ប្លន់ដីប្រទេសទាំងនោះ ។

សន្តិភាពឥណ្ឌូចិននឹងកើតឡើងវិញភ្លាម សិទ្ធិមនុស្សនឹងត្រូវគេគោរព លទ្ធិប្រជាធិបតេយ្យនឹងធ្លាក់ដល់ដៃប្រជាជាតិនានានៅអាស៊ីអាគ្នេយ៍នេះភ្លាម បើសិនណាហើយអាមេរិក មហាមិត្ត យកគ្រាប់បែកបរមាណូទៅទម្លាក់កំទេចក្បាលយួនមហាចោរប្លន់អន្តរជាតិដូចដែលសហរដ្ឋធ្លាប់បានស្រោចស្រង់ពិភពលោកពីក្រញាំចក្រពត្តិជប៉ុន ។ នៅសល់តែមធ្យោបាយនេះមួយទេ ហើយប្រជាជាតិរងគ្រោះទាំងអស់នឹងផុតទុក្ខ ផុតភ័យ ព្រមទាំងចាត់ទុកសហរដ្ឋថាជាមេនៃលទ្ធិប្រជាធិបតេយ្យ ប្រជាជាតិចំបង ស្រោចស្រង់ប្រទេសតូច ទន់ខ្សោយ ឥតរើសអើង និងមិនគិតផលប្រយោជន៍ផ្ទាល់ខ្លួនហួសហេតុ...។៚

~ ចប់ ~